ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម

# ភូមិវិទ្យា





៨





គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៨

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង វ៉ាត់ | លោក ស៊ុន ណាត្រី |
| | លោក មួង សុផាត | លោកស្រី មាស សុគន្ធខន |
| | លោក តែម គឹមគុន | លោកស្រី បៃន នាង |
| **អ្នកខាយអត្ថបទ** | លោក ហៃ វីរៈ | លោក ប៉ាន់ ជាតិ |
| **វិចិត្រករ** | លោក ឡុង សុវណ្ណា | |
| **អ្នករៀបរៀង** | លោក លឹម ហ៊ិន | លោក ខាត់ ធី |
| | លោក ប៊ី សុផល | លោក ឃ្លោក វីរ៉ា |
| **អ្នករចនាទំព័រ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោក សុខ សំបូរ | លោក ត្រីណាវិទ្ធ |
| | លោក រស់ ភិរុណ | លោកស្រី ធិក ផារី |
| **គណៈកម្មការពិនិត្យ** | លោកស្រី កៅ សុខអណ្ដែត | លោកស្រី មុំ មេត |
| | លោក មាស ផុតិមា | លោកស្រី ស្វាយ ធឿម |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២២២៨ អយក.ប្រក. ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-001-247

# អារម្ភកថា

សៀវភៅសិក្សាសង្គមថ្នាក់ទី ៥ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2009) របស់ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គម មានមុខវិជ្ជារងចំនួនបួន ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា។

ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះនឹងជួយប្អូនៗឱ្យដឹងអំពី ស្ថានភាពប្រជាជន ប្រទេសរបស់ខ្លួន ប្រទេសក្នុងតំបន់មួយចំនួន ប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍ ដឹងពីប្រវត្តិសាស្ត្រពិភពលោក ប្រវត្តិសាស្ត្រកម្ពុជា ប្រវត្តិសាស្ត្រក្នុងតំបន់ និងមានចំណេះដឹងបន្ថែមទៀតទៅលើចំណងទាក់ទងជាមួយអ្នកដទៃ ចំណងទាក់ទងក្នុងគ្រួសារ ការរស់នៅជាសហគមន៍ និងជំនឿផ្សេងៗ ជាពិសេសគឺបានដឹងពីវិជ្ជាធ្វើម្ហូប និងវិជ្ជាកាត់ដេរ ប៉ាក់ជាដើម។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះ គឺមានទម្រង់ដូចៗគ្នាទាំងអស់ដូចជាការកំណត់វត្ថុបំណងនៃមេរៀន សម្រាប់ឱ្យប្អូនៗដឹងពីអ្វីដែលត្រូវសិក្សាក្នុងមេរៀននីមួយៗ ពិសេសនៅចុងបញ្ចប់នៃជំពូកនីមួយៗមានតេស្តបញ្ចប់ជំពូក សម្រាប់វាយតម្លៃលើចំណេះដឹងនៅពេលរៀនចប់ជំពូកនីមួយៗ។ តាមរយៈខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូនៗនឹងទទួលបានចំណេះដឹង បំណិនឥរិយាបថ ការសង្កេតរូបភាព ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូ ឬជាក្រុមនិងតាមការសិក្សាស្រាវជ្រាវជាដើម។ ជាមួយនេះដែរ ការរៀបចំសៀវភៅនេះក៏មានការចូលរួមផ្តល់យោបល់ កែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូនៅតាមបណ្តាខេត្តក្រុងមួយចំនួនផងដែរ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅសិក្សាសង្គមថ្នាក់ទី ៥ នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន។ ទន្ទឹមគ្នានោះគណៈកម្មការនិពន្ធរីករាយនិងទទួលយករាល់មតិកែលម្អពីសំណាក់ លោកគ្រូ អ្នកគ្រូនិងគ្រប់មជ្ឈដ្ឋាន។

**គណៈកម្មការនិពន្ធ**

ជំពូក 1 : ប្រទេសអាស៊ីអាគ្នេយ៍ (ភូមិវិទ្យា)

1. ប្រទេសកម្ពុជា ........................ 2
2. ប្រទេសឡាវ ........................ 12
3. ប្រទេសថៃ ........................ 18
4. ប្រទេសឥណ្ឌូណេស៊ី ........................ 24
5. ប្រទេសហ្វីលីពីន ........................ 30
6. ប្រទេសវៀតណាម ........................ 36
7. ប្រទេសទីម័រខាងកើត ........................ 42

ជំពូក 2 : ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ

1. ប្រទេសកំពុងអភិវឌ្ឍ ........................ 50
2. ប្រទេសអភិវឌ្ឍ ........................ 64

# ជំពូកទី 1 ប្រទេសអាស៊ីអាគ្នេយ៍




*ផែនទីប្រទេសអាស៊ីអាគ្នេយ៍*

អាស៊ីអាគ្នេយ៍ ជាផ្នែកមួយដ៏សំខាន់នៃទ្វីបអាស៊ីលាតសន្ធឹងពីខ្សែស្រប 28°30′ ខាងជើងទៅ11° ខាងត្បូង និងពីខ្សែបណ្ដោយ 92°20′ ទៅដល់ 140° ខាងកើតលើផ្ទៃដីទាំងអស់ជាង 20 លាន $km^2$ ។ តាមលក្ខណៈទីតាំង គេអាចចែកភូមិភាគអាស៊ីអាគ្នេយ៍ជាពីរក្រុមធំៗគឺអាស៊ីអាគ្នេយ៍ដីគោក (កម្ពុជា វៀតណាម ឡាវ ថៃ និងមីយ៉ាន់ម៉ា) និងអាស៊ីអាគ្នេយ៍ដីកោះ "ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ឥណ្ឌូណេស៊ី ព្រុយនេ និងទីម័រខាងកើត (ទីម័រលេស)" ។

អាស៊ីអាគ្នេយ៍មានប្រជាជនទាំងអស់ចំនួន 555 814 លាននាក់ (ឆ្នាំ 2005) បង្កើតបានជាកំណុំរងមួយនៃប្រជាជនក្នុងពិភពលោក ដែលជាតំបន់សម្បូរទៅដោយទំនាស់នយោបាយ (ការប្រយុទ្ធប្រឆាំងនឹងនយោបាយអាណានិគម សង្គ្រាមត្រជាក់ និងទំនាស់ផ្ទៃក្នុងប្រទេស) និងជាតំបន់សេដ្ឋកិច្ចមួយដែលកំពុងអភិវឌ្ឍឈានឡើង(ប្រទេសមួយចំនួនមាននាមថា នាគ ឬកូននាគ) ។

តទៅនេះ យើងនឹងលើកយកតែលក្ខខណ្ឌធម្មជាតិ និងសង្គមរបស់ប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍មកសិក្សាតែប៉ុណ្ណោះ ។ ចំណែកផ្នែកសេដ្ឋកិច្ច យើងនឹងសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត ។

មេរៀនទី

# 1 ប្រទេសកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីលក្ខខណ្ឌធម្មជាតិ : សណ្ឋានដី អាកាសធាតុ ផ្លូវទឹក របបនយោបាយ និង ស្ថានភាពប្រជាជនកម្ពុជា ។

ក្រោយពីមានការផ្លាស់ប្តូររបបនយោបាយជាបន្តបន្ទាប់ចាប់ពីឆ្នាំ 1970 មក តាមរដ្ឋធម្មនុញ្ញថ្មី (24 កញ្ញា 1993) ប្រទេសកម្ពុជាមាននាមជាផ្លូវការថា "ព្រះរាជាណាចក្រកម្ពុជា" ដែលមានទីក្រុងភ្នំពេញជារាជធានី ។

ប្រទេសកម្ពុជា ជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដែលស្ថិតនៅក្នុងតំបន់ឧបទ្វីបឥណ្ឌូចិនចន្លោះខ្សែស្របទី 10° និងទី 15° នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី 102° និងទី 108° នៃរយៈបណ្តោយខាងកើត ។

កម្ពុជាមានផ្ទៃដីទំហំ 181 035km² និងមានរាងពហុកោណស្ទើរស្មើជ្រុងដែលមានចំណុចកណ្តាលក្បែរក្រុងកំពង់ធំ បណ្តោយពីលិចទៅកើត 560km ទទឹងពីត្បូងទៅជើង 440km ព្រំប្រទល់ទាំងអស់ 2 600km (5/6 ជាដីគោកនិង 1/6 ជាឆ្នេរសមុទ្រ) ។

ប្រទេសកម្ពុជា មានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសថៃ និងឡាវ ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងត្បូងជាប់នឹងប្រទេសវៀតណាម និងឈូងសមុទ្រថៃ ខាងលិចជាប់នឹងប្រទេសថៃ ។

លក្ខខណ្ឌធម្មជាតិកម្ពុជា ផ្តល់ភាពអនុគ្រោះច្រើនដល់ការរស់នៅរបស់ប្រជាជនយើង ។ ប៉ុន្តែលក្ខខណ្ឌសង្គមមួយចំនួន បានបង្កគ្រោះមហន្តរាយដល់ប្រទេសជាតិ និងប្រជាជាតិដូចជា ចម្បាំងក្នុងស្រុក ចម្បាំងឈ្លានពាន សង្គ្រាមត្រជាក់ របបប្រល័យពូជសាសន៍ខ្មែរក្រហមប៉ុលពត ... ។

## 1. លក្ខខណ្ឌធម្មជាតិ

### 1.1. សណ្ឋានដី

សណ្ឋានដីប្រទេសកម្ពុជា ផ្នែកកណ្តាលជាទំនាបមួយដ៏ធំប្រហែល 1/3 នៃផ្ទៃប្រទេស ព័ទ្ធស្ទើរជុំវិញដោយតំបន់ខ្ពស់(ភ្នំនិងខ្ពង់រាប) ។ គេចែកសណ្ឋានដីប្រទេសកម្ពុជាជា 4 តំបន់ធម្មជាតិធំៗគឺ




## តំបន់ធម្មជាតិ

មាត្រដ្ឋាន 1/4 000 000

ព្រំប្រទល់ | ទំនាបកណ្ដាល | ខ្ពង់រាបទាប | កំពូលភ្នំសំខាន់ៗ | ជួរភ្នំ - ខ្ពង់រាបខ្ពស់ | តំបន់ទួលភ្នំ

*ផែនទីសណ្ឋានដីប្រទេសកម្ពុជា*

## ក. តំបន់មាត់សមុទ្រ

តំបន់នេះស្ថិតនៅប៉ែកនិរតីប្រទេសមាន ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ហើយចែកជាបីផ្នែក មានទំនាបឆ្នេរ ឆ្នេរ និងឈូង ។ ទំនាបឆ្នេរ តូចចង្អៀត សម្បូរផ្លូវទឹកខ្លីៗ និងព្រៃកោងកាង ។ ឆ្នេរប្រវែង 440km ពីចាំយាម(ព្រំដែនថៃ)ដល់ហាទៀង(ព្រំដែនវៀតណាម) ។ ឈូងសមុទ្រកម្ពុជាសម្បូរកោះដូចជា កោះកុង កោះរ៉ុង កោះរ៉ុងសន្លឹម កោះថ្មី កោះទន្សាយ កោះតាង កោះពូលូវ៉ៃ(កោះអាចម៍សេះ) ...ជាដើម ។ កោះត្រល់ ជាកោះភ្នំដ៏ធំមួយនៅបាំងពីមុខខេត្តកំពត ពីដើមជាផ្នែកមួយនៃទឹកដីខ្មែរ បច្ចុប្បន្នកាន់កាប់ដោយប្រទេសវៀតណាមដែលហៅថា ' កោះភូកុក (Phu-Quoc) ។

## ខ. តំបន់ប្រជុំភ្នំ

ជួរភ្នំក្រវាញ : សណ្ឋូកតាមបណ្តោយឆ្នេរពីខេត្តកោះកុងដល់ខេត្តកំពត ចែកជាបីផ្នែក មានក្រវាញខាងលិច ក្រវាញកណ្តាល និងក្រវាញខាងកើត ។ ក្រវាញខាងលិច សណ្ឋូកពីប៉ៃលិនដល់ផងស៊ីងពោធិ៍សាត់មានកំពូលខ្ពស់គឺ ភ្នំទំពរ (1 563m) ។ ក្រវាញកណ្តាលមានផ្ទៃរាងទេរ ពីមោងមកកោះកុងមានកំពូលខ្ពស់គឺ ភ្នំសំកុះ (1 744m) ។ ក្រវាញខាងកើត ចែកជាប្រជុំភ្នំបី គឺប្រជុំភ្នំខ្មោល ប្រជុំភ្នំអូរម្លូ និងប្រជុំភ្នំដំរី ។ ប្រជុំភ្នំខ្មោល ស្ថិតនៅចន្លោះខេត្តពោធិ៍សាត់ និងកំពង់ស្ពឺ(ភ្នំឱរ៉ាល់ ខ្ពស់ជាងគេនៅកម្ពុជា 1 813m) ។ ប្រជុំភ្នំអូរម្លូ ស្ថិតនៅចន្លោះស្រែអំបិល និងកំពង់ស្ពឺ មានខ្ពង់រាបគីរីរម្យ(700m) ។ ប្រជុំភ្នំដំរី ដាច់ចេញពីអូរម្លូដោយច្រកពេជ្រនិល និងបញ្ចប់ដោយមុខចំណោតភ្នំបូកគោ (1 075m) ។

ជួរភ្នំនេះ មានច្រកសំខាន់បីគឺ ច្រកវាលវែង ច្រកតាសី និងច្រកពេជ្រនិល ភ្ជាប់ទំនាបកណ្តាលមកតំបន់មាត់សមុទ្រ ។ តំបន់កូនភ្នំ ស្ថិតនៅព័ទ្ធជុំវិញជួរភ្នំក្រវាញ មានកូនភ្នំនៅដាច់ៗពីគ្នា មានកម្ពស់មិនលើសពី 800m មានភ្នំសំខាន់ៗដូចជា ភ្នំវែង ភ្នំកំវែង ភ្នំពិស ភ្នំទូកមាសជាដើម ។ កោះទាំងឡាយរបស់យើងក៏ស្ថិតនៅតំបន់កូនភ្នំដែរ ។

ជួរភ្នំដងរែក : បង្កើតបានជាព្រំដែនធម្មជាតិរវាងកម្ពុជា-ថៃជាគែមខាងត្បូងនៃខ្ពង់រាបនគររាជ ដែលមានមុខចំណោតខ្លាំងមកខាងកម្ពុជា សណ្ឋូកពីទិសខាងកើតទៅលិច ចាប់ពីជ្រលងទន្លេមេគង្គដល់ជ្រលងទន្លេចៅជ្រះយ៉ានៃប្រទេសថៃ ។ វាមានបណ្តោយប្រហែល 300km និងរយៈកម្ពស់ចុះជាលំដាប់ពីកើតទៅលិច គឺពី 700m ទៅ 200m ។

## គ. តំបន់ទំនាបកណ្តាល

ទំនាបនេះ ស្ថិតនៅចំកណ្តាលប្រទេស សណ្ឋូកតាមទិសពាយ័ព្យ-អាគ្នេយ៍មានរាងទ្រវែង ស្តួចកណ្តាល រីកធំឆ្ពោះទៅទិសខាងត្បូងជាទំនាបល្បាប់ មានទំហំស្មើ 1/3 នៃផ្ទៃប្រទេស ហើយចែកចេញជា ទំនាបបឹង និងទំនាបទន្លេបួនមុខ ។

**ទំនាបបឹង** : ស្ថិតនៅជុំវិញបឹងទន្លេសាប មានរយៈកម្ពស់ពី 25 ដល់ 200m ។ តាមសណ្ឋានដីទំនាបនេះចែកជាបីផ្នែកគឺ តំបន់លិចទឹកជាប្រចាំ ទំនាបទាបលិចទឹកជំនន់ និងទំនាបខ្ពស់មិនលិចទឹកជំនន់ទេ(វាលស្រែ) ។

**ទំនាបទន្លេបួនមុខ** : ស្ថិតនៅអមសងខាងទន្លេទាំងបួន ។ តាមសណ្ឋានដីទំនាបនេះ គឺចែកចេញជាបីផ្នែកដែរ គឺផ្នែកទីដីល្បាប់ម៉ង្គ (ជាប់មាត់ទន្លេ) តំបន់លិចទឹកនៅរដូវវស្សា និងតំបន់មិនលិចទឹក (វាលស្រែ) ។

### ឃ. តំបន់ខ្ពង់រាប

ខ្ពង់រាបខាងជើង ស្ថិតនៅចន្លោះទំនាបកណ្តាល ជួរភ្នំដងរែក និងជ្រលងទន្លេមេគង្គ មានកូនភ្នំដូចជា ភ្នំត្បែង ចុងកាល់ គូលែន សន្ទុកជាដើម ។

ខ្ពង់រាបខាងកើតនិងឦសានចែកចេញជាបួនផ្នែក ខ្ពង់រាបខេត្តក្រចេះនិងស្ទឹងត្រែង ខ្ពង់រាបខេត្តកំពង់ចាម ខ្ពង់រាបខេត្តរតនគិរី(បរកែវ) និងខ្ពង់រាបខេត្តមណ្ឌលគិរី(ឆ្លូងលើ) ។

## 1.2. អាកាសធាតុ




មូសុងវស្សា (ឧសភា ដល់ តុលា)

មូសុងប្រាំង (វិច្ឆិកា ដល់ មេសា)

(Em) ម៉ាសខ្យល់ អេក្វាទ័រ សមុទ្រ

▲ ស្ថានីយឧតុនិយម

Tc ou Pc tropicalise ម៉ាសខ្យល់ត្រូពិច ឬម៉ាសខ្យល់ប៉ូលកណ្តាលទ្វីប

1370.7mm : កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ

1012 mb : សម្ពាធ

*ផែនទីអាកាសធាតុប្រទេសកម្ពុជា*

ផ្អែកលើកូអរដោនេភូមិសាស្ត្របង្ហាញថា ប្រទេសកម្ពុជាស្ថិតក្រោមឥទ្ធិពលអាកាសធាតុត្រូពិចមូសុងដែលសម្បូរកម្ដៅនិងសំណើម ។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំមានកម្រិតខ្ពស់លើសពី 27°C ។ ចន្លោះកម្ដៅមធ្យមប្រចាំឆ្នាំមានត្រឹម 3.8°C ។ រីឯតំបន់ខ្ពង់រាបមានរហូតដល់ទៅ4.2°C ។ នៅរាជធានីភ្នំពេញ សីតុណ្ហភាពអតិបរមា 40.5C (ខែមេសា) និងអប្បបរមា 14°C (ខែមករា) ។

ខ្យល់ដែលបក់ឆ្លងកាត់ប្រទេសឈ្មោះថា **ខ្យល់មូសុង** ដែលបង្កើតឱ្យមានរដូវពីរគឺ

**មូសុងនិរតី** : បក់ពីមហាសមុទ្រឥណ្ឌា ជាខ្យល់សមុទ្រផ្ទុកដោយចំហាយទឹកច្រើន នាំមកនូវភ្លៀងដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រទេស បង្កើតបានជារដូវវស្សា(ពីខែឧសភាដល់ខែតុលា) ។

**មូសុងឦសាន** : បក់មកពីស៊ីបេរី ជាខ្យល់ទ្វីប ខ្សត់សំណើម មិននាំមកនូវទឹកភ្លៀងទេ បង្កើតបានជារដូវប្រាំង(ពីខែវិច្ឆិកាដល់ខែមេសា) ។

ប្រទេសកម្ពុជាជាប្រទេសសើម មានភ្លៀងធ្លាក់លើសពី 1 000mm ក្នុងមួយឆ្នាំ ស្ទើរគ្រប់ទីកន្លែង តែរបាយទឹកភ្លៀងមិនស្មើគ្នាទេ តែងប្រែប្រួលទៅតាមទីកន្លែងនិងតាមរដូវ ។ នៅតំបន់មាត់សមុទ្រមានភ្លៀងធ្លាក់ពី 2 000 mm ទៅ 5 000 mm តំបន់ខ្ពង់រាបពី 2 000 mm ទៅ 3 000 mm និងតំបន់ទំនាបកណ្ដាលពី 1 200 mm ទៅ 1 500 mm ។

ប្រទេសកម្ពុជា មានបាតុភូតអាកាសធាតុមិនប្រក្រតីជាច្រើនដូចជា ភ្លៀងកក់ខែ(មករា-កុម្ភៈនិងមេសា) កួនរដូវប្រាំងមួយក្នុងរដូវវស្សា (ចុងខែកក្កដានិងដើមខែសីហា) ។ តើបាតុភូតទាំងនេះបណ្ដាលមកពីមូលហេតុអ្វីខ្លះ ?

ដោយបរិយាកាសភពផែនដីមានការប្រែប្រួល ប្រទេសកម្ពុជាក៏ទទួលរងនូវអព្ភូតហេតុអាកាសធាតុផ្សេងៗមានដូចជា ភ្លៀងធ្លាក់មិនទៀងទាត់ ធាតុអាកាសកើនកម្ដៅ រដូវរំហើយសឹងតែបាត់បង់ កាំរន្ទះកើតមានញឹកញយ និងខ្យល់ព្យុះជាដើម ។

## 1.3. ធនធានទឹក

ផ្អែកលក្ខណៈសណ្ឋានដី និងអាកាសធាតុបែបនេះ ជាហេតុនាំឱ្យប្រទេសកម្ពុជាសម្បូរផ្លូវទឹកខ្វាត់ខ្វែងពាសពេញផ្ទៃប្រទេស ។ ផ្លូវទឹកកម្ពុជា អាចចែកចេញជាបីក្រុម ៖

ក. **ប្រព័ន្ធទន្លេមេគង្គ** : (រួមមានតួទន្លេមេគង្គ ទន្លេបាសាក់ ទន្លេតូច និងដៃរបស់វា) ។

**ទន្លេមេគង្គ** : មានប្រភពនៅខ្ពង់រាបទីបេ(រយៈកម្ពស់ 5 000 m) ហូរចាក់ទៅក្នុងសមុទ្រចិនខាងត្បូងប្រវែង 4 200 km ។ នៅលើទឹកដីកម្ពុជា ទន្លេនេះមានប្រវែង 500km ហូរកាត់ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្ដាល និងព្រៃវែង ។ ទន្លេនេះមានរបបទឹកទៀងទាត់ណាស់ គឺរដូវទឹកជំនន់ឡើងពីខែមិថុនាដល់ខែតុលា រដូវទឹកស្រកពីខែវិច្ឆិកាដល់ខែឧសភា។

ទន្លេបាសាក់ : ហូរកាត់ខេត្តកណ្ដាលតាមតាខ្មៅ មានបណ្ដោយ 100km គិតពីភ្នំពេញដល់ព្រំដែនវៀតណាម និងមានដៃសំខាន់ពីរគឺ ស្ទឹងតាកែវ និងស្ទឹងព្រែកត្នោត ។

ទន្លេតូច : បែកចេញពីទន្លេមេគង្គលើត្រង់ពាមប្រធ្នស់(កំពង់ចាម) ហូរកាត់តាមព្រំប្រទល់ខេត្តកំពង់ចាម-ព្រៃវែង និងខេត្តកណ្ដាល-ព្រៃវែងមកភ្ជាប់នឹងទន្លេមេគង្គក្រោមត្រង់ពាមរក៍(ព្រៃវែង) មានបណ្ដោយ 100km ។

២. ប្រព័ន្ធទន្លេសាប : (មានទន្លេសាប បឹងទន្លេសាប និងដៃរបស់វា) ។

ទន្លេសាប : ហូរកាត់រាជធានីភ្នំពេញ ខេត្តកណ្ដាល និងកំពង់ឆ្នាំងមានប្រវែងប្រហែល 100km ប្រៀបបាននឹងព្រែកដ៏ធំមួយ ដែលហូរនាំទឹកពីទន្លេមេគង្គទៅចាក់ក្នុងបឹងទន្លេសាបនៅរដូវវស្សា និងហូរនាំទឹកត្រឡប់មកទន្លេមេគង្គវិញនៅរដូវប្រាំង ។

បឹងទន្លេសាប : ចែកចេញជាបឹងធំ បឹងតូច និងវាលភក់ មានរាងដូចវីយូឡុង មានបណ្ដោយប្រហែល 150km ទទឹងមធ្យម 32km ផ្ទៃ 3 000$km^2$ ជម្រៅទឹកពី 0.8m ទៅ 2m នៅរដូវប្រាំង ។ បឹងនេះមានទិដ្ឋភាពជាកូនសមុទ្រមួយដែលមានផ្ទៃក្រឡា 10 000$km^2$ និងជម្រៅទឹក 14m នៅរដូវវស្សា ។




បណ្ដាញផ្លូវទឹកប្រទេសកម្ពុជា

### គ. ក្រុមផ្លូវទឹកតាមមាត់សមុទ្រ

គឺជាផ្លូវទឹកខ្លីៗ មានប្រភពនៅតាមតំបន់ភ្នំខ្ពស់ៗនៃជួរភ្នំក្រវាញ មានលក្ខណៈជារបបទឹកជ្រោះ មានស្ទឹងមេទឹក ស្ទឹងតាតី ព្រែកជីផាត ព្រែកកំពង់សោម ស្ទឹងជាយអារែង ស្ទឹងកំពត និងព្រែកទូកមាស ។

# 2. លក្ខខណ្ឌនយោបាយ និងប្រជាជនកម្ពុជា

## 2.1. ប្រព័ន្ធនយោបាយ និងការគ្រប់គ្រងរដ្ឋបាល

### ក. របបនយោបាយ

ចាប់ពីថ្ងៃទី 24 ខែកញ្ញា ឆ្នាំ 1993 មក ប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការថា "ព្រះរាជាណាចក្រកម្ពុជា" ប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងគោរពលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ផ្អែកលើគោលការណ៍បែងចែកអំណាចដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ព្រះមហាក្សត្រសោយរាជ្យតែមិនកាន់អំណាចទេ ព្រះអង្គជានិមិត្តរូបនៃសាមគ្គីភាព និងឯកភាពជាតិខ្មែរ ។ អំណាចនយោបាយរដ្ឋកាន់កាប់ដោយនាយករដ្ឋមន្ត្រីមួយរូប ដែលមានឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាច្រើនរូបជាជំនួយ ។

**អំណាចនីតិបញ្ញត្តិ** : ស្ថាប័ននេះអមដោយសភាពីរគឺ ព្រឹទ្ធសភា និងរដ្ឋសភាដែលជាអង្គការកំពូលនៃប្រទេសជាតិ និងជាតំណាងជាន់ខ្ពស់របស់ប្រជារាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ។

**អំណាចនីតិប្រតិបត្តិ** : ជាស្ថាប័នដែលអនុវត្តច្បាប់គ្រប់គ្រងសង្គមដោយផ្ទាល់ គឺរាជរដ្ឋាភិបាល ។ សមាជិករាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះនាយករដ្ឋមន្ត្រី និងចំពោះសភារាល់សកម្មភាពការងាររបស់ខ្លួន ។

**អំណាចតុលាការ** : ជាអំណាចឯករាជ្យ មានតួនាទីធានារក្សាការពារសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រ ។ អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ ។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំនុំជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

### ខ. របៀបរៀបចំផ្នែករដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា បែងចែកជា 25 ខេត្ត និងរាជធានីមួយគឺ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ កែប ប៉ៃលិន ត្បូងឃ្មុំ និងរាជធានីភ្នំពេញ ។

រាជធានីភ្នំពេញចែកចេញជា 12ខណ្ឌគឺ ដូនពេញ ៧មករា ចំការមន ទួលគោក ដង្កោ មានជ័យ ឬស្សីកែវ សែនសុខ ព្រែកព្នៅ ជ្រោយចង្វារ ច្បារអំពៅ ពោធិ៍សែនជ័យ ។ គ្រប់ខេត្តទាំងអស់ត្រូវបានបែងចែកជាស្រុក និងក្រុង ។ ខេត្តមួយចំនួនធំមានស្រុកជាច្រើន និងក្រុងមួយ ដូចជាខេត្តកណ្ដាលមានស្រុកចំនួន 10 និងក្រុងតាខ្មៅ ។ ទន្ទឹមនឹងនេះ ខេត្តខ្លះទៀតមានក្រុង 2 ដូចជាខេត្តស្វាយរៀង មានក្រុងបាវិត និងក្រុងស្វាយរៀង ។ ខេត្តត្បូងឃ្មុំដែលបង្កើតថ្មី មានក្រុងសួង ។ ខេត្តកែប និងខេត្តប៉ៃលិន មានស្រុកមួយ និងក្រុងមួយដូចគ្នា ។

## 2.2. ស្ថានភាពប្រជាជនកម្ពុជា

ដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ស្ថានភាពប្រជាជនកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង ។ នៅចន្លោះឆ្នាំ (1975-1979) ប្រជាជនកម្ពុជាមានអត្រាកំណើនអវិជ្ជមាន ដោយសារអត្រាមរណប្រមាណមានកម្រិតខ្ពស់ ហើយអត្រាជាតិប្រមាណមានកម្រិតទាប ។ ម្យ៉ាងទៀតប្រជាជនរាប់សែននាក់បានភៀសខ្លួនទៅនៅតាមជំរំព្រំដែនថៃ និងទៅប្រទេសក្រៅ ។

តាមជំរឿនឆ្នាំ 2008 ប្រជាជនកម្ពុជាមានទាំងអស់ចំនួន 13 395 682 នាក់ គិតជាដង់ស៊ីតេមធ្យមមាន 75 នាក់ /$km^2$ ។ ក្នុងចំនួននោះ បុរសមាន 6 516 054 នាក់ ស្ត្រីមាន 6 879 628 នាក់ ។ ចំនួនប្រជាជនកម្ពុជាជាប់ចំណាត់ថ្នាក់លេខ 7 ក្នុងចំណោមប្រទេសទាំង 11 នៅអាស៊ីអាគ្នេយ៍ ។

**តារាងបង្ហាញកំណើនប្រជាជនកម្ពុជា**

| ឆ្នាំ | ប្រជាជន(នាក់) | សង្កេត | ឆ្នាំ | ប្រជាជន(នាក់) | សង្កេត |
|---|---|---|---|---|---|
| 1900 | 1 102 000 | ស្ថិតិ | 1962 | 5 751 000 | ជំរឿន |
| 1914 | 1 823 297 | ប៉ាន់ស្មាន | 1971 | 7 000 000 | ប៉ាន់ស្មាន |
| 1921 | 2 402 585 | ជំរឿន | 1980 | 6 700 000 | ជំរឿន |
| 1931 | 2 803 000 | ជំរឿន | 1990 | 8 686 000 | ប៉ាន់ស្មាន |
| 1941 | 3 471 000 | ប៉ាន់ស្មាន | 1998 | 11 437 656 | ជំរឿន |
| 1951 | 4 374 000 | ស្ថិតិ | 2008 | 13 395 682 | ជំរឿន |

### ក. កំណើនប្រជាជន

តារាងខាងលើនេះបង្ហាញថា ចំនួនប្រជាជនកម្ពុជាតាមឆ្នាំមួយចំនួន ពិសេសឆ្នាំដែលយើងបានធ្វើជំរឿន ។ នៅឆ្នាំ 1980 ចំនួនប្រជាជនមានការថយចុះដែលជាផលវិបាកនៃសង្គ្រាម និងរបប

ប្រល័យពូជសាសន៍នៅកម្ពុជា ។ បញ្ហានេះបណ្តាលមកពីអត្រាមរណប្រមាណខ្ពស់ និងអត្រាជាតិប្រមាណទាប ហើយម្យ៉ាងទៀតវិញ ប្រជាជនមួយភាគនាំគ្នារត់ភៀសខ្លួនទៅរស់នៅប្រទេសជិតខាង និងចេញទៅប្រទេសក្រៅ ។ ក្រោយឆ្នាំ 1980 ចំនួនប្រជាជនកម្ពុជាបានកើនឡើងយ៉ាងរហ័ស ។ នេះជាលទ្ធផលដែលបានមកពីអត្រាកំណើនធម្មជាតិមានកម្រិតខ្ពស់ និងចលនាចំណូលស្រុកទាំងស្របច្បាប់ និងមិនស្របច្បាប់មកក្នុងប្រទេសកម្ពុជា ។

កម្ពុជាសព្វថ្ងៃ អត្រាកំណើនធម្មជាតិមាន 1.5% (ជំរឿន 2008) ។ អត្រានេះបានមកពីផលសងរវាងអត្រាជាតិប្រមាណ និងអត្រាមរណប្រមាណ ។ អត្រាជាតិប្រមាណមានកម្រិតខ្ពស់ ចំណែកអត្រាមរណប្រមាណថយចុះ ដោយសារការលូតលាស់ផ្នែកវេជ្ជសាស្ត្រដែលជាហេតុនាំឱ្យអត្រាកំណើនមានកម្រិតខ្ពស់នៅឡើយ ។ ការស្ទាបស្ទង់បានឱ្យដឹងថា គ្រួសារខ្មែរមានកូនជាមធ្យមប្រមាណ 3 នាក់ (ជំរឿន 2008) នៅបស្ចិមប្រទេសគ្រួសារនីមួយៗមានកូនតែមួយ ឬពីរនាក់ប៉ុណ្ណោះ ។

ជាទូទៅ ក្នុងគ្រួសារដែលមានកូនច្រើន កម្រិតជីវភាពច្រើនតែទាប សេវាសុខាភិបាល និងសេវាអប់រំក៏មានកម្រិតទាបដែរ ។ កំណើនប្រជាជនខ្ពស់នាំមកនូវបញ្ហាជាច្រើនចំពោះសង្គមជាតិដូចជា បញ្ហាការងារ អប់រំ សុខភាព លំនៅស្ថាន ស្បៀងអាហារ ទុគ៌តភាព បរិស្ថានធម្មជាតិ ជាដើម ។

## ២. ទម្រង់ប្រជាជនកម្ពុជា




*ពីរ៉ាមីតអាយុប្រជាជនកម្ពុជាឆ្នាំ 1998-2008*

ការប្រៀបធៀបរូបពីរាមីតទាំងពីរបង្ហាញថា ទម្រង់ប្រជារាស្ត្រកម្ពុជាមានការប្រែប្រួលខ្លះដែរ ក្នុងអំឡុងទសវត្សរ៍ (1998-2008) :

- អត្រាកុមារ (0-14) ពី 43.5% ចុះមក 33.8% ។
- អត្រាប្រជាជនសកម្ម (15-16) ពី 53.7% កើនមក 56.1% ។
- អត្រាមនុស្សចាស់ (65ឆ្នាំឡើង) ពី 3.5% កើនមក 4.3% ។

ប្រជារាស្ត្រកម្ពុជានៅតែមានទម្រង់ក្មេង ដូចនៅបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀតដែរ ។

## គ. សូចនាករប្រជាជនផ្សេងៗទៀត

ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ(1998-2008) ប្រជារាស្ត្រខ្មែរកើនបានចំនួន 1.95 លាននាក់ ។ ស្ត្រីមានចំនួនច្រើនជាងបុរស(ស្ត្រីមាន 51.36% បុរសមាន 48.64%)គិតជាផលធៀបភេទមាន 94.7% ។ អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីខ្មែរចុះពី 4.8 មក 3.1 នាក់ ។ អត្រាប្រជាជនក្រុងកើន 18.2% ទៅ 19.5% ហើយដែលនៅអាស៊ីអាគ្នេយ៍ទាំងមូលមានដល់ទៅ 46% ។ ចំណែកសង្ឃឹមរស់ពីកំណើតនៅកម្ពុជាមាន 56ឆ្នាំ ។ ប្រជារាស្ត្រខ្មែរ 96.9% ជាពុទ្ធសាសនិកជន ។

## ? សំណួរ

1. តើប្រទេសកម្ពុជាបានទទួលចំណាត់ថ្នាក់លេខប៉ុន្មាន ខាងផ្ទៃដី និងចំនួនប្រជាជនក្នុងចំណោមប្រទេសទាំង 11 នៅអាស៊ីអាគ្នេយ៍ ?
2. តើសណ្ឋានដីទំនាបបឹង និងទំនាបទន្លេបួនមុខខុសគ្នាដូចម្តេចខ្លះ ?
3. ហេតុអ្វីបានជាអ្នកភូមិវិទ្យា រាប់បញ្ចូលកោះទាំងឡាយរបស់យើងទៅក្នុងតំបន់ភ្នំ ?
4. តើកំណើនកម្តៅផែនដី នាំមកនូវបាតុភូតអាកាសធាតុប្លែកៗអ្វីខ្លះ ចំពោះប្រទេសយើង ?
5. ចូរនិយាយអំពីបាតុភូតទឹកឡើង និងស្រកនៅលើទន្លេមេគង្គកម្ពុជា ។
6. ហេតុអ្វីបានជាគេចាត់ទុកទន្លេសាបជាព្រៃកម្មួយដ៏ធំ ?
7. ចូរនិយាយអំពីរបបគ្រប់គ្រងនយោបាយនៅកម្ពុជា ។
8. តើទម្រង់ប្រជារាស្ត្រកម្ពុជា មានការប្រែប្រួលដូចម្តេចខ្លះក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ (1998-2008) ?

# 2 ប្រទេសឡាវ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសណ្ឋានដី អាកាសធាតុ ផ្លូវទឹក ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជនឡាវ ។

ប្រទេសឡាវស្ថិតក្រោមការត្រួតត្រារបស់សៀម(ថៃ) ពីចុងសតវត្សទី 18 ដល់ចុងសតវត្ស 19 មុននឹងក្លាយទៅជាផ្នែកមួយនៃឥណ្ឌូចិនបារាំង ។ សន្ធិសញ្ញាបារាំង-សៀមបានកំណត់ព្រំដែនឡាវជាមួយថៃ ។ នៅឆ្នាំ 1975 បក្សកុម្មុយនីស្តឡាវឡើងកាន់កាប់អំណាច ដោយបានបញ្ចប់របបរាជាធិបតេយ្យឡាវដែលមានចំណាស់ 6 សតវត្ស ហើយបានចូលជាសមាជិកអាស៊ាននៅឆ្នាំ 1997 ។

ឡាវ ជាប្រទេសតែមួយគត់ក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលគ្មានឆ្នេរសមុទ្រ ។ សម្បូរភ្នំ និងខ្ពង់រាបខ្សត់ទំនាប ហើយបានទទួលចំណាត់ថ្នាក់លេខ 7 ខាងផ្ទៃដី និងលេខ 8 ខាងចំនួនប្រជាជន ។

ប្រទេសនេះមានរាងទ្រវែងលាតសន្ធឹងតាមដងទន្លេមេគង្គពីជើងទៅត្បូងប្រវែង 1 000 km និងមានផ្ទៃ 236 800$km^2$ ។ ប្រទេសនេះស្ថិតនៅចន្លោះខ្សែស្របទី 14° និង 20°30′ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្ដោយទី 100° និង 108° នៃរយៈបណ្ដោយខាងកើត ។ ឡាវមានព្រំប្រទល់ខាងកើតជាប់វៀតណាម (2 130km) ខាងជើងជាប់ចិន (423km) និងមីយ៉ាន់ម៉ា (235km) ខាងលិចជាប់ថៃ (1 754 km) និងខាងត្បូងជាប់ប្រទេសកម្ពុជា ។

## 1. លក្ខខណ្ឌធម្មជាតិ

### 1.1. សណ្ឋានដី

សណ្ឋានដីប្រទេសឡាវ បង្កើតឱ្យមានតំបន់ធម្មជាតិធំៗពីរគឺ

#### ក. តំបន់ខាងជើង ឬស្រុកឡាវលើ

តំបន់នេះស្ថិតនៅខាងជើងទីក្រុងវៀងចន្ទន៍ ។ ភ្នំសំខាន់ៗមានកម្ពស់លើសពី 2 000m ដូចជាភ្នំចាស់ភូយុន (2 100m) ស្ថិតនៅខាងលិចទីក្រុងលួងព្រះបាង ។ ខាងកើតទន្លេមេគង្គ មានភ្នំប្អូនភ្ជាប់ទៅខ្ពង់រាបពីរ (ហួផាន់ និងត្រាននិញកម្ពស់លើសពី 1000m) ។ ភ្នំខ្ពស់ជាងគេនៅទីនោះ គឺភ្នំភូបៀ (2 820m ដែលជាកំពូលខ្ពស់របស់ប្រទេសឡាវ) ។




*ផែនទីសណ្ឋានដីប្រទេសឡាវ*

## ១. តំបន់ខាងត្បូង ឬស្រុកឡាវក្រោម

តំបន់ខាងត្បូង ឬស្រុកឡាវក្រោម លាតសន្ធឹងពីទីក្រុងវៀងចន្ទន៍ដល់ព្រំដែនប្រទេសកម្ពុជា ជាតំបន់ដែលសម្បូរខ្ពង់រាបដែលមានមុខចំណោតទាបទៅៗ ពីកើតទៅលិច និងពីជើងទៅត្បូង ។

ក្រៅពីតំបន់ទាំងពីរខាងលើ គេឃើញមានទំនាបទន្លេមេគង្គ ។ ទំនាបមានលក្ខណៈតូចចង្អៀតខ្លាំងនៅស្រុកឡាវលើ និងមានផ្ទៃធំទូលាយគ្រាន់បើប្រកបដោយជីជាតិផងនោះនៅស្រុកឡាវក្រោម ។

## 1.2. អាកាសធាតុ

ដោយមានទីតាំងស្ថិតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ប្រទេសឡាវទទួលរងឥទ្ធិពលខ្យល់មូសុងដូចប្រទេសដទៃទៀតក្នុងតំបន់ដែរ ដែលបង្កើតឱ្យមានរដូវពីរ គឺរដូវប្រាំង និងរដូវវស្សា ។

រដូវប្រាំង : ចាប់ពីខែវិច្ឆិកាដល់មេសាជារដូវស្ងួត ហើយត្រជាក់ខ្លាំងជាងនៅប្រទេសកម្ពុជាយើង ។ ខ្យល់បក់ពីឦសានទៅនិរតី ជាខ្យល់ទឹបត្រជាក់ហើយស្ងួត ។

រដូវវស្សា : ចាប់ពីខែឧសភាដល់តុលា បង្កើតឡើងដោយខ្យល់មូសុងពីនិរតី ដែលនាំមកនូវចំហាយទឹកទៅប៉ះនឹងជួរភ្នំបណ្ដាលឱ្យកកើតជាភ្លៀងធ្លាក់មកយ៉ាងច្រើន ។ នៅប្រទេសឡាវកម្រិតកម្ពស់ទឹកភ្លៀងកើនឡើងពីតំបន់មាត់ទន្លេមេគង្គ(1 000 - 1 500 mm)ទៅតាមវាលទំនាប(1 500 - 2 000 mm) រហូតទៅដល់តំបន់ភ្នំខ្ពស់ៗនៃប្រទេសឡាវលើ (2 000 -2 500mm) ។

## 1.3. ផ្លូវទឹក

ទន្លេមេគង្គឡាវមានប្រវែង 1 600km គិតពីព្រំដែនចិនដល់ព្រំដែនប្រទេសកម្ពុជា (ល្បាក់ទឹកខោន) ចែកជាបីកំណាត់គឺ

### ក. កំណាត់លួងផ្រះបាង

ចាប់ពីព្រំដែនឡាវ ចិន រហូតដល់ទីក្រុងវៀងចន្ទន៍ ។ លើកំណាត់ផ្លូវទឹកនេះ ពោះទន្លេប្រកបទៅដោយដុំថ្ម និងទឹកជួរ ហើយនាវាមិនអាចប្រព្រឹត្តទៅបានដោយងាយទេ ។ ដៃទន្លេសំខាន់ៗមានទន្លេណាមថា ទន្លេណាមបែង ទន្លេណាមអ៊ូ និងទន្លេណាមខាន ។

### ខ. កំណាត់វៀងចន្ទន៍

គិតពីទីក្រុងវៀងចន្ទន៍ដល់ទឹកជួរខេមរ៉ាត(ខេមរាស្ត្រ) ទទឹងទន្លេមានពី 300m ទៅ 800m ។ នាវាតូចៗអាចធ្វើដំណើរបានពេញមួយឆ្នាំ ។ ដៃសំខាន់ៗនៃកំណាត់ទន្លេនេះមាន ទន្លេណាមងឹមទន្លេណាមង៉ៀប ទន្លេណាមសាន ទន្លេណាមកាឌីង ទន្លេសេបាំងផៃ និងទន្លេសេបាំងហៀង ។

### គ. កំណាត់ចំប៉ាសាក់

គិតពីពាមទន្លេសេមូនដល់ល្បាក់ខោន ទទឹងទន្លេមានពី 1 200m ទៅ 1 500m ។ ដៃសំខាន់លើកំណាត់នេះមានពីរ គឺទន្លេសេមូនដែលហូរមកពីប្រទេសថៃខាងកើត និងទន្លេសេដូន ។

# 2. លក្ខខណ្ឌនយោបាយ និងប្រជាជនឡាវ

## 2.1. ប្រព័ន្ធនយោបាយ

ប្រទេសឡាវមាននាមជាផ្លូវការថា "សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ" (2 ធ្នូ 1975) ប្រកាន់យកមាគ៌ាអភិវឌ្ឍន៍តាមបែបសង្គមនិយម មានទីក្រុងវៀងចន្ទន៍ជារដ្ឋធានី ។

របបគ្រប់គ្រងនយោបាយឡាវចែកចេញជាបីផ្នែកគឺ

### ក. អំណាចនីតិបញ្ញត្តិ

ជាស្ថាប័នកំពូលរបស់ប្រជាជាតិ និងប្រជាជនឡាវ ជាអង្គការតែមួយគត់ហៅថា សភាជាតិឡាវ ដែលមានចំនួនទាំងអស់ 115 អាសនៈ បោះឆ្នោតជ្រើសតាំងទៅតាមបញ្ជីឈ្មោះបេក្ខជនចាត់តាំងឡើងដោយគណបក្សប្រជាជនបដិវត្តន៍ឡាវសម្រាប់អាណត្តិ 5 ឆ្នាំដែរ ។

### ខ. អំណាចនីតិប្រតិបត្តិ

អំណាចនេះកាន់កាប់ដោយគណៈប្រធានរដ្ឋ មានប្រធានាធិបតីមួយរូប និងអនុប្រធានាធិបតីមួយរូប និងក្រុមប្រឹក្សារដ្ឋមន្ត្រីមាននាយករដ្ឋមន្ត្រីមួយរូប និងឧបនាយករដ្ឋមន្ត្រីបួនរូបទៀត ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវជ្រើសតាំងដោយប្រធានាធិបតី និងទទួលការយល់ព្រមពីសភាជាតិដោយការបោះឆ្នោតសម្រាប់អាណត្តិ 5 ឆ្នាំ ។ ទាំងប្រធានាធិបតី ទាំងអនុប្រធានាធិបតី និងនាយករដ្ឋមន្ត្រីសុទ្ធតែត្រូវបោះឆ្នោតជ្រើសរើសដោយសភាជាតិសម្រាប់អាណត្តិ 5 ឆ្នាំ ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីជាអ្នកគ្រប់គ្រងប្រជាពលរដ្ឋឡាវដោយផ្ទាល់ ទទួលខុសត្រូវចំពោះមុខប្រធានាធិបតី និងសភាជាតិ ។

### គ. អំណាចតុលាការ

ជាអំណាចរបស់តុលាការជាន់ខ្ពស់នៃប្រជាជនដែលមានប្រធានមួយរូប បោះឆ្នោតជ្រើសតាំងដោយសភាជាតិ តាមអនុសាសន៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាជាតិ ។ អនុប្រធានមួយរូបនៃតុលាការជាន់ខ្ពស់ និងចៅក្រមច្រើនរូបទៀត ត្រូវជ្រើសតាំងដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភាជាតិ ។

ប្រព័ន្ធនយោបាយឡាវបច្ចុប្បន្ននេះមានគណបក្សតែមួយគត់ គឺគណបក្សប្រជាជនបដិវត្តន៍ឡាវ គ្មានគណបក្សប្រឆាំង ឬក្រុមដាក់សម្ពាធផ្នែកនយោបាយណាសោះឡើយ ។

របៀបគ្រប់គ្រងផ្នែករដ្ឋបាលបានបែងចែកប្រទេសឡាវជា 16 ខេត្ត រដ្ឋធានីមួយ គឺទីក្រុងវៀងចន្ទន៍ ។

## 2.2. ស្ថានភាពប្រជាជន

ប្រជាជនឡាវមានកំណើតពុំសូវច្បាស់លាស់ទេ គេគ្រាន់តែដឹងថាមានជនជាតិចម្រុះមកតាំងទីរស់នៅតាំងពីយូរយារណាស់មកហើយ ។ ប្រទេសនេះមានប្រជាជនសរុបចំនួន 6 677 534 នាក់ (តាមការជំរាន់ស្មានខែកក្កដា 2008) គិតជាដង់ស៊ីតេមធ្យមមាន 28 នាក់ / $km^2$ ។ តំបន់ខាងត្បូង ឬស្រុកឡាវក្រោមមានមនុស្សរស់នៅច្រើនជាងតំបន់ខាងជើងឬស្រុកឡាវលើ ។

ទីក្រុងធំៗដែលមានមនុស្សរស់នៅច្រើន គឺរដ្ឋធានី **វៀងចន្ទន៍** សះវ៉ាន់ខេត ប៉ាកសេ និង លួងព្រះបាង ។

សព្វថ្ងៃក្នុងចំណោមប្រជាជនឡាវ គេសង្កេតឃើញមានជនជាតិសំខាន់ៗបីពួកគឺ ជនជាតិឡាវមាន 55% ជនជាតិឃ្មុ (Khmou) 11% ជនជាតិម៉ុង (Hmong) 8% និងជនជាតិវៀតណាម ចិន ថៃ ខ្មែរ អឺរ៉ុប រួមទាំងជនជាតិភាគតិចមួយចំនួនទៀត (26%) តាមជំរឿនឆ្នាំ 2005 ។

ទម្រង់ប្រជាជនឡាវប្រហាក់ប្រហែលគ្នានឹងប្រទេសកំពុងអភិវឌ្ឍនានាដែរ គឺមានទម្រង់ក្មេង

- ក្រុមកុមារ (0-14 ឆ្នាំ) មាន 41% (កុមារាមាន 20.59% និងកុមារី 20.41%) ។
- ក្រុមប្រជាជនសកម្ម (15-64 ឆ្នាំ) មាន 55.9% (បុរសមាន 27.65% និងស្ត្រីមាន 28.25%) ។
- ក្រុមមនុស្សចាស់ (65 ឆ្នាំឡើង) មាន 3.1% (បុរសមាន 1.36% និងស្ត្រីមាន 1.75%) ។

ទាំងនេះបង្ហាញថា ចំនួនកុមារាមានច្រើនជាងចំនួនកុមារី ។ ចាប់ពី 15 ដល់ 64 ឆ្នាំ ស្ត្រីមានចំនួនច្រើនជាងបុរស ។ ចំណែកក្នុងក្រុមវ័យចំណាស់ស្ត្រីក៏មានច្រើនជាងបុរសដែរ ។ តួលេខទាំងនេះបានមកពីការជំរាន់ស្មាននៅឆ្នាំ 2008 ។

ចំពោះសូចនាករប្រជាសាស្ត្រផ្សេងៗទៀតនៃប្រទេសឡាវមាន អត្រាជាតិប្រមាណ 3.44% អត្រាមរណប្រមាណ 1.10% និងអត្រាកំណើនធម្មជាតិមាន 2.34% ។ អត្រាមរណៈកុមារមាន 7.96% នៃកំណើតរស់ ។ កម្រិតលទ្ធភាពបង្កកំណើតរបស់ស្ត្រីឡាវមាន 4.5 នាក់(ឆ្នាំ 2008 តាមការជំរាន់ស្មាន) ។ អក្ខរជនដែលចេះអាន និងចេះសរសេរចាប់ពីអាយុ 15 ឆ្នាំឡើងមាន 68.7% ដែលក្នុងនោះបុរសមាន 77% និងស្ត្រីមាន 60.9% (ឆ្នាំ 2001 តាមការជំរាន់ស្មាន) ។ ឡាវមានប្រជាជនក្រុង 21.2% (ឆ្នាំ 2004) ។

ចំពោះសាសនាវិញ ប្រជាជនឡាវចំនួន 67% ជាពុទ្ធសាសនិក 1.5% ជាគ្រិស្តសាសនិកនិង 31.5% ជាអ្នកមានជំនឿផ្សេងៗ និងមិនបានកំណត់ច្បាស់ ។ ចំណែកភាសាប្រើប្រាស់ជាផ្លូវការ គឺភាសាឡាវ ។ ក្រៅពីនេះមានភាសាបារាំង អង់គ្លេស និងភាសាជនជាតិជាច្រើនផ្សេងៗទៀត ។

*សន្និដ្ឋាន :* ជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដីគោក ។ ប្រទេសឡាវជាប្រទេសបិទ គឺជាប្រទេសគ្មានឆ្នេរសមុទ្រ សម្បូរភ្នំនិងខ្ពង់រាប ខ្សត់ទំនាប ។ ប្រទេសនេះស្ថិតនៅក្រោមឥទ្ធិពលអាកាសធាតុ

ត្រូពិចមូសុងក្ដៅសើម (ក្ដៅពិបាកទ្រាំ និងត្រជាក់ខ្លាំង) ទឹកហូរស្រោចស្រពដោយទន្លេមេគង្គតែមួយ និងសម្បូរដោយទឹកជ្រូរ ។ ប្រជាជនប្រទេសនេះមានទម្រង់ក្មេង ។ អត្រាកំណើនប្រជាជន និងលទ្ធភាពបង្កកំណើតមានកម្រិតខ្ពស់ជាងនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រទេសឡាវ ប្រកាន់យករបបគ្រប់គ្រងនយោបាយតាមបែបសង្គមនិយម តែរបបសេដ្ឋកិច្ចបែបទីផ្សារសេរី មានទំនាក់ទំនងនយោបាយសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាប្រទេសសមាជិកនៃអង្គការអាស៊ាន (1997) ផងដែរ ។

## ? សំណួរ

1. តើប្រទេសឡាវស្ថិតនៅជាប់នឹងប្រទេសណាខ្លះ ?
2. តើគេចែកសណ្ឋានដីប្រទេសឡាវជាប៉ុន្មានតំបន់ធម្មជាតិ ? អ្វីខ្លះ ? ចូររៀបរាប់ ។
3. ចូរប្រៀបធៀបអាកាសធាតុប្រទេសឡាវ និងអាកាសធាតុប្រទេសកម្ពុជា ។
4. តើផ្លូវទឹកប្រទេសឡាវអាចចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ? ចូររៀបរាប់ ។
5. តើទំនាបសំខាន់ជាងគេរបស់ប្រទេសឡាវស្ថិតនៅត្រង់ណា ? ចូររៀបរាប់ ។
6. តើប្រព័ន្ធនយោបាយឡាវ និងកម្ពុជាដូចគ្នាដែរឬទេ ? ចូរពន្យល់ ។
7. ចូរប្រៀបធៀបទម្រង់តាមអាយុនៃប្រជាជនឡាវ និងប្រជាជនកម្ពុជា ។
8. តើទម្រង់ក្មេងនៃប្រជាជនឡាវចោទជាបញ្ហាសង្គមសំខាន់ៗអ្វីខ្លះ ?
9. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះមួយមានន័យត្រឹមត្រូវ អាស៊ីអាគ្នេយ៍ សមុទ្រ ឡាវ នៃ ដីគោក ឆ្នេរ តែមួយ ប្រទេស ជា ដែល គ្មាន គត់ ។

មេរៀនទី

# 3 ប្រទេសថៃ

**ចប់មេរៀននេះ សិស្សអាច**

❑ រៀបរាប់ពីសណ្ឋានដី អាកាសធាតុ ផ្លូវទឹក ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជនថៃ ។

ប្រទេសថៃស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍លើឧបទ្វីបឥណ្ឌូចិន លាតសន្ធឹងពីខ្សែស្របទី 6° ដល់ទី 20° នៃរយៈទទឹងខាងជើង និងខ្សែបណ្ដោយទី 97° ដល់ទី 106° នៃរយៈបណ្ដោយខាងកើត ។ ប្រទេសនេះមានផ្ទៃដី 513 000km$^2$ បានទទួលចំណាត់ថ្នាក់លេខ 3 ខាងផ្ទៃដី និងលេខ 4 ខាងចំនួនប្រជាជន ។ ប្រទេសថៃមានព្រំប្រទល់ខាងកើតជាប់ប្រទេសឡាវ (1 754km) និងប្រទេសកម្ពុជាខាងជើង និងខាងលិចជាប់ប្រទេសមីយ៉ាន់ម៉ា(1 800km) ខាងត្បូងជាប់សមុទ្រអង់ដាម៉ង់ ប្រទេសម៉ាឡេស៊ី (506km) និងឈូងសមុទ្រថៃ និងមានឆ្នេរសមុទ្រទាំងអស់ប្រវែង 3 219km ។

## 1. លក្ខខណ្ឌធម្មជាតិ

### 1.1. សណ្ឋានដី

សណ្ឋានដីប្រទេសថៃមួយភាគធំមានរយៈកម្ពស់ទាបជាង 600m ពិសេសតំបន់ទំនាបកណ្ដាល ។ សណ្ឋានដីប្រទេសនេះអាចចែកចេញជាបួនភូមិភាគគឺ

**ភូមិភាគខាងជើង** : ជាតំបន់ខ្ពង់រាប និងភ្នំខ្ពស់ៗដែលសណ្ដូកតាមទិសជើង-ត្បូងដូចជាភ្នំដូយអ៊ីនថាណុន(2 680m) ។

**ភូមិភាគអាគ្នេយ៍** : ជាជួរភ្នំដងរែក ដែលជាព្រំដែនធម្មជាតិរវាងកម្ពុជា-ថៃ និងមានដីមួយផ្នែកទៀតលយចូលរហូតដល់ព្រំប្រទល់ប្រទេសម៉ាឡេស៊ី ។

**ភូមិភាគកណ្ដាល** : ជាទំនាបដីធំ(ទំនាបបាងកក) ប្រកបដោយដីល្បាប់យ៉ាងក្រាស់ លាតសន្ធឹងចាប់ពីទន្លេចៅផ្រះយ៉ា (ទន្លេមេណាម) រហូតដល់ឈូងសមុទ្រថៃ ។

**ភូមិភាគខាងកើត** : ជាក្រហូងមួយដ៏ធំ ដែលខណ្ឌពីទំនាបកណ្ដាលដោយជួរភ្នំទាបៗ និងជួរភ្នំដងរែកនៅខាងត្បូង ។ ក្រហូងនេះមានផ្ទៃទេរឆ្ពោះទៅទិសខាងកើត ។




ផែនទីសណ្ឋានដីប្រទេសថៃ




ផែនទីអាកាសប្រទេសថៃ

## 1.2. អាកាសធាតុ

អាកាសធាតុថៃមានលក្ខណៈជាអាកាសធាតុត្រូពិចមូសុង ដូចនៅប្រទេសមីយ៉ាន់ម៉ាដែរ តែមានភ្លៀងតិចជាង ។ អាកាសធាតុនេះបង្កើតឱ្យមានរដូវសំខាន់ពីរគឺ

រដូវប្រាំង : បង្កើតឡើងដោយខ្យល់មូសុងពីទិសឦសាន ពីខែវិច្ឆិកាទៅខែមេសា ជាខ្យល់ទ្វីបខ្សត់សំណើម ធ្វើឱ្យផ្លូវទឹករីងស្ងួត ឬស្រកកម្ពស់ ។

រដូវវស្សា : បង្កើតឡើងដោយខ្យល់មូសុងពីទិសនិរតី ពីខែឧសភាដល់ខែតុលា ប៉ុន្តែរយៈកម្ពស់នៃសណ្ឋានដី ធ្វើឱ្យកម្ពស់ទឹកភ្លៀងប្រែប្រួលទៅតាមតំបន់ ។

របាយទឹកភ្លៀងនៅប្រទេសថៃ តែងប្រែប្រួលទៅតាមរដូវ និងទៅតាមទីកន្លែង ។ មូសុងវស្សានាំមកនូវទឹកភ្លៀងមួយភាគធំមកលើប្រទេសថៃ លើកលែងតែតំបន់នៃឧបទ្វីប ដែលទទួលបានទឹកភ្លៀងច្រើនជាងគេ ។ នៅរដូវប្រាំងមួយភាគនៃឧបទ្វីបនេះទទួលភ្លៀងពីមូសុងឦសានដែលបក់កាត់ឈូងសមុទ្រថៃ ។

ភ្លៀងពុំធ្លាក់ពេញមួយរដូវវស្សានោះទេ គេសង្កេតឃើញមានភាពរាំងស្ងួតមួយរយៈពេលខ្លីដែរ ។ កម្ពស់ទឹកភ្លៀងប្រែប្រួលទៅតាមរយៈកម្ពស់ និងទីតាំងនៃភូមិភាគនីមួយៗ ។ តំបន់ឆ្នេរសមុទ្រនៃឧបទ្វីបភាគខាងលិចបានទទួលទឹកភ្លៀងច្រើនជាងគេ គឺតំបន់តះកួប៉ាមានភ្លៀងធ្លាក់រហូតដល់ 7 000 mm / ឆ្នាំ ។ តំបន់ចន្ទបុរីក៏ទទួលភ្លៀងច្រើនដែរគឺ (5 600 mm / ឆ្នាំ) ។ តំបន់ខ្សត់ភ្លៀង គឺភាគកណ្ដាលនៃខ្ពង់រាបនគររាជ ភាគខាងត្បូងនៃប្រទេសថៃខាងជើង ភាគខាងជើង និងពាយ័ព្យនៃអាងទន្លេចៅព្រះយ៉ា ។

## 1.3. ផ្លូវទឹក

ប្រទេសនេះមានផ្លូវទឹកសំខាន់ពីរក្រុមគឺ

### ក. ប្រព័ន្ធទន្លេចៅព្រះយ៉ា

មានប្រភពនៅតំបន់ភ្នំ និងខ្ពង់រាបខាងជើង មានទន្លេពីង ទន្លេយ៉ុម ទន្លេវាំង និងទន្លេណានហូរតាមចន្លោះភ្នំបង្កើតបានជាដៃដីសំខាន់នៃទន្លេមេណាម (ចៅព្រះយ៉ា) ។ ទន្លេទាំងនេះហូរមកប្រសព្វគ្នាត្រង់ណៈខនសវ៉ាន់ ។ ចាប់ពីណៈខនសវ៉ាន់រហូតដល់ឆៃណាតទន្លេហូរតាមជ្រលងតែមួយ (តួទន្លេមានតែមួយ) ។ ចាប់ពីឆៃណាតដល់ឈូងសមុទ្រថៃ ទន្លេបែកចេញពីគ្នាវិញជាទន្លេថាជីន និងទន្លេចៅព្រះយ៉ា ។

### ខ. ប្រព័ន្ធទន្លេមេគង្គ

មានទន្លេមេគង្គ ជាព្រំដែនធម្មជាតិមួយភាគធំរវាងថៃ-ឡាវ និងមានដៃពីរ គឺទន្លេមូន និងទន្លេឈីហូរកាត់ខ្ពង់រាបនគររាជ មកប្រសព្វគ្នាត្រង់អ៊ូបុនហូរចាក់ទៅក្នុងទន្លេសេមូន រួចធ្លាក់ចូលទៅក្នុងទន្លេមេគង្គត្រង់ប៉ែកខាងត្បូងនៃទីកដូរខេមរ៉ាតក្នុងទឹកដីឡាវ ។

# 2. ប្រព័ន្ធនយោបាយ និងប្រជាជនថៃ

## 2.1. ប្រព័ន្ធនយោបាយ

ប្រទេសនេះមាននាមជាផ្លូវការថា "រាជាណាចក្រថៃ" ប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ អនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចនៅប្រទេសយើងដែរ ។ ព្រះមហាក្សត្រសោយរាជ្យតែមិនកាន់អំណាចទេ គឺគ្រាន់តែជានិមិត្តរូបជាតិប៉ុណ្ណោះ ។ អំណាចដឹកនាំ និងគ្រប់គ្រងប្រទេសស្ថិតនៅលើរាជរដ្ឋាភិបាល រដ្ឋសភា និងតុលាការ ។

## ក. អំណាចនីតិប្រតិបត្តិ

តួនាទីព្រះប្រមុខរដ្ឋ ជារបស់ព្រះមហាក្សត្រថៃ ។ ការអភិសេកឡើងគ្រងរាជ្យ ប្រព្រឹត្តទៅតាមតំណរាជវង្ស ។ ព្រះមហាក្សត្រ ភូមីភុន អាឌុលយ៉ាដេត ទ្រង់ឡើងសោយរាជ្យសម្បត្តិចាប់តាំងពីថ្ងៃទី 9 ខែមិថុនា 1946 មកម្ល៉េះ ។

តួនាទីប្រមុខរាជរដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រីថៃ ជាស្ថាប័នគ្រប់គ្រងសង្គមផ្ទាល់ និងមានឧបនាយករដ្ឋមន្ត្រីបួនរូបទៀតជាសហការី ។ ប្រធានបក្សឈ្នះឆ្នោត អាចរៀបចំរដ្ឋាភិបាលសម្ព័ន្ធភាព ដែលតាមធម្មតាជានាយករដ្ឋមន្ត្រីទទួលបានការយល់ព្រមពីព្រះមហាក្សត្រ ។ នាយករដ្ឋមន្ត្រីមានអាណត្តិ 4 ឆ្នាំ និងកំណត់ត្រឹមតែ 2 អាណត្តិប៉ុណ្ណោះ ។

## ខ. អំណាចនីតិបញ្ញត្តិ

ស្ថាប័ននេះអមដោយសភាពីរគឺ ព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ ។ ព្រឹទ្ធសភាមាន 150 អាសនៈ ជ្រើសតាំងសម្រាប់អាណត្តិ 6 ឆ្នាំ ។ ចំណែកសភាតំណាងរាស្ត្រមាន 480 អាសនៈ ជ្រើសតាំងសម្រាប់អាណត្តិ 4 ឆ្នាំ ។

សភាជាតិថៃជាអង្គការកំពូល តំណាងឱ្យប្រជាជាតិ និងប្រជារាស្ត្រថៃ ។ កិច្ចការសំខាន់ៗរបស់ប្រទេស ត្រូវស្នើសុំសេចក្តីសម្រេចពីសភាសិន ទើបរាជរដ្ឋាភិបាលអាចយកទៅអនុវត្តតាម ។

## គ. អំណាចតុលាការ

អំណាចតុលាការ ជារបស់តុលាការគ្រប់ជាន់ថ្នាក់ មានតុលាការខេត្ត-ក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល (ដែលអង្គចៅក្រមត្រូវចាត់តាំងដោយព្រះមហាក្សត្រ) ជាអង្គការសម្រាប់ការពារសិទ្ធិស្របច្បាប់ និងយុត្តិធម៌ជូនប្រជារាស្ត្រថៃ ក្នុងនាមព្រះមហាក្សត្រ ។

ចំពោះការរៀបចំផ្នែករដ្ឋបាល ប្រទេសថៃត្រូវបានបែងចែកជា 76 ខេត្ត និងមានទីក្រុងបាងកកជារាជធានី ។ គណបក្សនយោបាយសំខាន់ៗនៅប្រទេសថៃមានចំនួន 7 ។

## 2.2. ស្ថានភាពប្រជាជន

ប្រទេសថៃមានប្រជារាស្ត្រទាំងអស់ចំនួន 65 493 296 នាក់ (កក្កដា 2008 ការប៉ាន់ស្មាន) គិតជាដង់ស៊ីតេមធ្យមមាន 127.66 នាក់ / $km^2$ ។

សង្គមថៃជាសង្គមចម្រុះទៅដោយជនជាតិ ជនជាតិសៀមមានចំនួនច្រើនជាងគេ ជនជាតិខ្មែរមានប្រមាណបួនលាននាក់រស់នៅតំបន់អាគ្នេយ៍ជាប់ព្រំដែនខ្មែរ-ថៃ ជនជាតិឡាវរស់នៅភាគខាងកើត ជនជាតិចិនច្រើនរស់នៅតាមទីក្រុង ។ ក្រៅពីនេះ គេឃើញមានជនជាតិភាគតិចមួយចំនួនទៀតដូចជា

ពួកណោត្រីតូ ពួកជ្វា ពួកការេង(ជិតព្រំដែនមីយ៉ាន់ម៉ា) ពួកកុលសម្ព័ន្ធទីបេ មីយ៉ាន់ម៉ា (ផាន ឡូឡូម៉ាន) នៅភាគខាងជើង និងពួកកុលសម្ព័ន្ធដែលមានលក្ខណៈប្រហាក់ប្រហែលខ្មែរលើយើងដែរនៅភូមិភាគខាងកើត ។



*ប្រជាជនថៃ*

របាយប្រជាជនថៃ មិនស្មើគ្នាទេ ។ ដង់ស៊ីតេប្រជាជនខ្ពស់នៅតាមបណ្ដោយផ្លូវទឹក ពោលគឺតាមទំនាបទាបៗ និងដីសណ្ដ ។ តំបន់ខ្ពស់ៗ និងវាលភក់ពុំសូវមានមនុស្សរស់នៅទេ ។ តំបន់មានមនុស្សច្រើនជាងគេ គឺទំនាបកណ្ដាល ពិសេសទំនាបបាងកក ។ បន្ទាប់មកទៀត គឺខ្ពង់រាបនគររាជ តំបន់ឧបទ្វីបមានដង់ស៊ីតេបង្គួរ តំបន់អាគ្នេយ៍មានដង់ស៊ីតេមធ្យម និងតំបន់ខាងជើងនិងខាងលិចមានដង់ស៊ីតេទាប ។

ទម្រង់ប្រជាជនថៃ បើធៀបនឹងទម្រង់ប្រជាជនកម្ពុជា ឬឡាវឃើញថា មានលក្ខណៈប្រសើរជាង ព្រោះថា ក្រុមវ័យកុមារ(0-14ឆ្នាំ)មានត្រឹម 21.2% (ប្រុស 7 104 776នាក់ ស្រី 6 781 453នាក់) ក្រុមវ័យពលកម្ម(15-64ឆ្នាំ) មានដល់ទៅ 70.3% (ប្រុស 22 763 274នាក់ ស្រី 23 304 793នាក់) និងក្រុមវ័យមនុស្សចាស់ (65ឆ្នាំឡើង) មាន 8.5%(ប្រុស 2 516 721 នាក់ ស្រី 3 022 281 នាក់) ។

បើគិតពីទម្រង់តាមភេទវិញ ចំនួនកុមារាមានចំនួនច្រើនជាងចំនួនកុមារី ។ ចំណែកមនុស្សក្នុងក្រុមវ័យពលកម្ម និងវ័យចំណាស់វិញ ចំនួនស្ត្រីមានច្រើនជាងចំនួនបុរស ដូចនៅប្រទេសកម្ពុជា និងឡាវដែរ ។

ស្ទូចនាករប្រជាសាស្ត្រថៃផ្សេងៗទៀតមាន អត្រាជាតិប្រមាណ 1.35% អត្រាមរណប្រមាណ 0.71% អត្រាមរណៈកុមារ 1.82% នៃកំណើតរស់ អត្រាកំណើនប្រជាជន 0.64% ។ អត្រាលទ្ធភាពបង្កកំណើតសម្រាប់ស្ត្រីថៃម្នាក់មាន 1.64 នាក់ ។ សង្ឃឹមរស់ពីកំណើតមាន 72.83 ឆ្នាំ ស្ត្រី 75.27 ឆ្នាំ បុរស 70.51 ឆ្នាំ ។ អត្រាអក្ខរជនចាប់ពីអាយុ 15 ឆ្នាំឡើងទៅមាន 92.6% បុរសមាន 94.6% ស្ត្រី 90.5% (ជំរឿនឆ្នាំ 2000) ។ ក្រុមជនជាតិមានថៃ 75% ចិន 14% ផ្សេងៗទៀត 11% ។ ជំរឿនសាសនាមាន 94.6% ជាពុទ្ធសាសនិក 4.6% អ៊ីស្លាមសាសនិក 0.7% គ្រិស្តសាសនិក និងផ្សេងៗទៀត 0.1% ។ មនុស្សពេញវ័យដែលផ្ទុក HIV/AIDS មាន 1.5% (2003 ប៉ាន់ស្មាន) ។ ថៃមានប្រជាជនក្រុង 32.2% ។

*សន្និដ្ឋាន* : រដ្ឋាភិបាលថៃបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើឱ្យមានស្ថិរភាពកំណើតសំដៅលើកកម្ពស់ជីវភាពប្រជារាស្ត្រ ។ រីឯព្រះពុទ្ធសាសនាស្ថិតក្នុងភាពស្ងប់ស្ងាត់ មិនបង្កើតឧបសគ្គអ្វីដល់គោលនយោបាយរបស់រដ្ឋាភិបាលឡើយ ។ ទោះបីជាប្រជារាស្ត្រថៃទទួលបានការអប់រំច្រើនក្តី ក៏គេឃើញមានអ្នកមិនចេះអក្សរចំនួនប្រមាណ 7.4% ដែរ ។ ហើយបញ្ហាសង្គមមានចោទច្រើននៅឡើយ ដូចជា បញ្ហាគ្រឿងញៀន ពេស្យាចារ ជំងឺអេដស៍ ពលកម្មកុមារ ការជួញដូរផ្លូវភេទ... ។ ក្រៅពីនេះថៃនៅមានទំនាស់បញ្ហាព្រំដែនជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បញ្ហាបះបោរអំពើភុបកម្មពីសំណាក់ពួកអ៊ីស្លាមនៅខេត្តភាគខាងត្បូងជាប់ព្រំដែនម៉ាឡេស៊ី និងបញ្ហាផ្ទៃក្នុងថៃ (វិបត្តិនយោបាយ ឬវិបត្តិរដ្ឋាភិបាល) ។

ប្រជារាស្ត្រថៃ មានសិទ្ធិសេរីភាពខាងជំនឿសាសនា ប៉ុន្តែភាគច្រើនជាពុទ្ធសាសនិកជន ។ តាមប្រពៃណីថៃ យុវជនភាគច្រើនមុនរៀបអាពាហ៍ពិពាហ៍ តែងឆ្លងកាត់ការបួសជាព្រះសង្ឃនៅតាមវត្តក្នុងភូមិរបស់ពួកគេ ។ មាតាបិតា ឬសាច់សារលោហិត ជាអ្នកផ្គត់ផ្គង់ដល់ជីវភាពសង្ឃទាំងនោះ ។

## ? សំណួរ

1. តើប្រទេសថៃមានទីតាំងស្ថិតនៅត្រង់ណា ?
2. តើសណ្ឋានដីប្រទេសថៃ អាចចែកចេញជាប៉ុន្មានភូមិភាគ ? ចូររៀបរាប់ ។
3. ចូរប្រៀបធៀបសណ្ឋានដីថៃ ឡាវ និងកម្ពុជា ។
4. តើតំបន់ណាខ្លះនៃប្រទេសថៃដែលមានដង់ស៊ីតេប្រជាជនខ្ពស់ ? តំបន់ណាមានដង់ស៊ីតេមធ្យម ? តំបន់ណាមានដង់ស៊ីតេទាប ?
5. ចូរប្រៀបធៀបកម្ពស់ទឹកភ្លៀងនៅប្រទេសថៃ និងប្រទេសកម្ពុជា ។
6. ចូររាប់ផ្លូវទឹកសំខាន់ៗរបស់ប្រទេសថៃ ។
7. ចូរប្រៀបធៀបទម្រង់តាមអាយុ និងតាមភេទនៃប្រជារាស្ត្រថៃ និងកម្ពុជា ។
8. តើបញ្ហាសង្គមថៃមានអ្វីខ្លះ ? ដោះស្រាយរួចរាល់អស់ហើយឬនៅ ?

# 4 ប្រទេសឥណ្ឌូណេស៊ី

ចប់មេរៀននេះ សិស្សអាច

- ពណ៌នាពីសណ្ឋានដី អាកាសធាតុ ផ្លូវទឹក ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជនឥណ្ឌូណេស៊ី ។

ប្រទេសឥណ្ឌូណេស៊ីធ្លាក់ក្រោមនិមអាណានិគមនិយមហូឡង់នៅដើមសតវត្សទី 17 បន្ទាប់មកប្រទេសជប៉ុនពីឆ្នាំ 1942 ដល់ 1945 ។ ប្រទេសនេះប្រកាសជាសាធារណរដ្ឋឯករាជ្យក្នុងឆ្នាំ 1943 ហើយទទួលស្គាល់ជាផ្លូវការពីហូឡង់នៅឆ្នាំ 1949 ។ ឥណ្ឌូណេស៊ី ជារដ្ឋកម្រងកោះដ៏ធំបំផុតក្នុងលោក និងជាប្រទេសដែលមានប្រជាជនកាន់សាសនាអ៊ីស្លាមច្រើនជាងគេផងដែរ ។

ប្រទេសនេះមានផ្ទៃដីសរុប 1 919 440 km$^2$ មានកោះទាំងអស់ចំនួន 17 508 កោះ(ក្នុងចំណោមនោះ កោះចំនួន 6 000 គ្មានមនុស្សរស់នៅ) លាតសន្ធឹងពីលិចទៅកើតប្រវែង 5 000 km និងពីជើងទៅត្បូង 2 000 km ។ ទីតាំងប្រទេសនេះ ស្ថិតនៅអមសងខាងខ្សែអេក្វាទ័រ ចន្លោះទ្វីបអាស៊ី និងអូស្ត្រាលីតាមបណ្តោយសមុទ្រជាច្រើន ចន្លោះមហាសមុទ្រឥណ្ឌា លយចូលជ្រៅទៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។ ឥណ្ឌូណេស៊ីជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដីកោះ មានព្រំប្រទល់ខាងកើតជាប់ប្រទេសទីម័រខាងកើត (ទីម័រលេស) 228 km ជាប់ប្រទេសម៉ាឡេស៊ីនៅខាងជើង 1 782 km ជាប់ប៉ាពួញូគីនេនៅចុងខាងកើតបំផុត 820 km សរុបព្រំប្រទល់ទាំងអស់មាន 2 830 km និងមានឆ្នេរសមុទ្រប្រវែង 54 716 km ។

## 1. លក្ខខណ្ឌធម្មជាតិឥណ្ឌូណេស៊ី

### 1.1. សណ្ឋានដី

ក្នុងចំណោមកោះសំខាន់ៗចំនួន 24 របស់ឥណ្ឌូណេស៊ីមានកោះធំៗមួយចំនួនដូចជា កោះស៊ូម៉ាត្រា កោះកាលីម៉ាន់តាន់(បរនេអូ) កោះជ្វា កោះស៊ូឡាវ៉េស៊ី កោះអ៊ីរ្យាំងបារ៉ាត់ (គីណេថ្មី)ជាដើម ។ ប្រទេសនេះមានជួរភ្នំធំៗ និងភ្នំភ្លើងប្រមាណ 45 ដែលបានផ្ទុះចាប់ពីឆ្នាំ 1821 មក ។ បន្ទុះភ្នំភ្លើង និងរញ្ជួយដីកើតមានញឹកញាប់នៅតាមកោះនានា ព្រោះទីតាំងប្រទេសស្ថិតត្រង់សំបកផែនដីមិនស្ថិរឹងមាំដូចប្រទេសហ្វីលីពីនដែរ ។




*ផែនទីសណ្ឋានដីឥណ្ឌូណេស៊ី*

ភ្នំភ្លើងក្រាកាតូ (Krakatoa) នៃកោះរ៉ាកាតា(Rakata)របស់ឥណ្ឌូណេស៊ី បានសម្លាប់មនុស្សអស់ 36 400 នាក់ នៅឆ្នាំ 1883 ។ កាលពីថ្ងៃ 26 ធ្នូ ឆ្នាំ 2004 នៅក្នុងមហាសមុទ្រឥណ្ឌា ក្បែរកោះស៊ូម៉ាត្រាភាគខាងលិច មានរញ្ជួយដីមួយក្នុងកម្រិតខ្ពស់បំផុត គឺ 9° តាមរង្វាស់រិចស្ទ័រ បណ្តាលឱ្យមានរលកយក្សស៊ូណាមិ(Tsunami) បានបំផ្លាញទ្រព្យសម្បត្តិ និងជីវិតមនុស្សអស់យ៉ាងច្រើនសម្បើម ប៉ះពាល់ដល់ប្រទេសចំនួន 8 នៃអាស៊ី និងចំនួន 5 នៃអាហ្វ្រិច មានជនរងគ្រោះជាង 280 000 នាក់ ឥណ្ឌូណេស៊ីមានមនុស្សបាត់ខ្លួនដល់ទៅ 2/3 ។ រលកយក្សមានល្បឿនពី 500 ទៅ 800 km/h ហើយកម្ពស់ទឹកជះមកលើឆ្នេរមានដល់ទៅ 30 m ដែលធ្វើឱ្យខេត្តអាចេរបស់ឥណ្ឌូណេស៊ីត្រូវបំផ្លាញខ្ទេចខ្ទីខ្លាំងជាងគេ ។

ក្រៅពីនេះ ឥណ្ឌូណេស៊ីមានអន្លង់បាតសមុទ្រជ្រៅៗនៅតាមបណ្តោយកោះស៊ូម៉ាត្រា កោះជ្វា និងកោះស៊ូឡាវ៉េស៊ី ។ ភាពសម្បូរភ្នំនាំឱ្យប្រទេសនេះខ្វះត់ទំនាប ។ គេឃើញមានតែទំនាបតូចៗនៅតាមជ្រលងភ្នំ និងទំនាបឆ្នេរដែលជាទីប្រមូលផ្តុំមនុស្សរស់នៅ ។

## 1.2. អាកាសធាតុ

ឥណ្ឌូណេស៊ីជាកម្រងកោះ នៅចន្លោះខ្សែបណ្តោយទី 95° និងទី 145° នៃរយៈបណ្តោយខាងកើត និងចន្លោះខ្សែស្របទី 8° (រយៈទទឹងខាងជើង) និងទី 11° (រយៈទទឹងខាងត្បូង) ។ ទាំងនេះបង្ហាញថា ឥណ្ឌូណេស៊ីស្ថិតក្រោមឥទ្ធិពលនៃអាកាសធាតុអេក្វាទ័រសមុទ្រ ក្តៅហើយសើម និងមានភ្លៀងធ្លាក់ស្ទើរតែរៀងរាល់ថ្ងៃ ។ កម្ពស់ទឹកភ្លៀងជាមធ្យមលើសពី 2 000 mm /ឆ្នាំ និងមានសីតុណ្ហភាពមធ្យម ប្រចាំឆ្នាំពី 20°C ដល់ 30°C ។ និយាយរួមប្រទេសនេះគ្មានរដូវប្រាំងដូចនៅកម្ពុជាយើងទេ ។

### 1.3. ផ្លូវទឹក

ទន្លេធំហើយវែងច្រើនស្ថិតនៅលើកោះធំៗដូចជា ទន្លេបារីតូ ទន្លេកំពូស និងទន្លេរីជាន់ (កោះកាលីម៉ាន់តាន់) ទន្លេម៉បេរ៉ាម៉ូ និងទន្លេឌីគឹល (កោះអ៊ីរីយ៉ង់-ជ្វា) ទន្លេជីតារុំ ទន្លេជីម៉ានុក ទន្លេជីតាន់ឌូ ទន្លេបិងហ្គាវ៉ាន់សូឡូ និងទន្លេប្រាន់តាស់(កោះជ្វា)។ កោះស៊ូម៉ាត្រាមានទន្លេរកាំប៉ា ទន្លេអ៊ិនដ្រាគីរី ទន្លេចាំប៊ី ទន្លេមូស៊ី និងសម្បូរបឹង ដែលមានទេសភាពល្អប្លែកដូចជា បឹងតូបា បឹងម៉ានីនចូ បឹងស៊ីនកូរ៉ាក់ជាដើម។ បឹង និងទន្លេទាំងនោះជាប្រភពផ្តល់ទឹកសាបដ៏សំខាន់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនឥណ្ឌូណេស៊ីដែលជាអ្នកស្រុកកោះ។

## 2. ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជន

### 2.1. ប្រព័ន្ធនយោបាយ

ប្រទេសនេះបានប្រកាសខ្លួនជារដ្ឋឯករាជ្យពីថ្ងៃទី 17 ខែ សីហា ឆ្នាំ 1943 ទទួលស្គាល់ជាផ្លូវការដោយហូឡង់ ពីថ្ងៃទី 27 ខែធ្នូ ឆ្នាំ 1949 មានឈ្មោះថា "សាធារណរដ្ឋឥណ្ឌូណេស៊ី" ជាសាធារណរដ្ឋបែបប្រជាធិបតេយ្យសេរីពហុបក្ស ផ្អែកលើអំណាចឯករាជ្យបីគឺ

#### ក. អំណាចនីតិប្រតិបត្តិ

ស្ថិតក្នុងកណ្តាប់ដៃប្រធានាធិបតី និងអនុប្រធានាធិបតី។ គណៈរដ្ឋមន្ត្រីតែងតាំងឡើងដោយប្រធានាធិបតី។ ប្រធានាធិបតី និងអនុប្រធានាធិបតី ជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋសម្រាប់អាណត្តិ 5ឆ្នាំ។

#### ខ. អំណាចនីតិបញ្ញត្តិ

ជារបស់សភាតំណាងរាស្ត្រ ឬរដ្ឋសភាដែលមានអាសនៈទាំងអស់ចំនួន 550 ជ្រើសតាំងដោយការបោះឆ្នោតសម្រាប់អាណត្តិ5ឆ្នាំ ដូចប្រធានាធិបតីដែរ។ ក្រៅពីនេះគេឃើញមានសភាតំណាងរាស្ត្រតាមតំបន់ និងសន្និបាតប្រឹក្សាយោបល់របស់ប្រជាជនទៀតផង។

#### គ. អំណាចតុលាការ

ជារបស់តុលាការជាន់ខ្ពស់ និងតុលាការតាមផ្នែកមួយចំនួនទៀត

- ចៅក្រមនៃតុលាការជាន់ខ្ពស់ ជ្រើសសម្រាំងដោយអង្គជំនុំសភា តាមបញ្ជីបេក្ខជន ដែលរៀបចំឡើងដោយប្រធានាធិបតី។

- តុលាការធម្មនុញ្ញ ត្រូវបានផ្តល់អំណាចឱ្យដោយប្រធានាធិបតី ។
- ប្រព័ន្ធតុលាការជាន់ទាប រៀបចំឡើងដោយក្រសួងយុត្តិធម៌ និងសិទ្ធិមនុស្ស ទទួលបានការរ៉ាប់រងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុពីតុលាការជាន់ខ្ពស់ ។
- តុលាការការងារ ត្រូវស្ថិតក្រោមការត្រួតពិនិត្យពីសំណាក់តុលាការជាន់ខ្ពស់ ។

*សម្គាល់ :* តាមលទ្ធិប្រជាធិបតេយ្យ អំណាចទាំងបីខាងលើត្រូវស្ថិតនៅដាច់ដោយឡែកពីគ្នាពោលគឺ ជាអំណាចឯករាជ្យ ។ ប៉ុន្តែរបបសាធារណរដ្ឋឥណ្ឌូនេណេស៊ីមានលក្ខណៈ ជារបបសាធារណរដ្ឋបែបប្រធានាធិបតីនិយម ។ នេះបង្ហាញឱ្យឃើញថា ប្រធានាធិបតីហាក់ដូចជាមានអំណាចទូលំទូលាយច្រើនណាស់ ។ ចំណែករបៀបរៀបចំផ្នែករដ្ឋបាលវិញ បានបែងចែកប្រទេសឥណ្ឌូណេស៊ីជា 30 ខេត្ត និងរដ្ឋធានីមួយគឺទីក្រុង ចាកាតា ។

ចំពោះគណបក្សនយោបាយវិញមានច្រើន ហើយគ្មានគណបក្សណាមួយទទួលបានសំឡេងឆ្នោតច្រើនដាច់ខាតនោះទេ មានដូចជាកាលពីសម័យបោះឆ្នោតថ្ងៃទី 5 ខែមេសា ឆ្នាំ 2004 គណបក្ស (Golkar) បាន 21.6% , PDI-P បាន 18.5% , PKB បាន 10.6% , PPP បាន 8.2% , PD បាន 7.5% PKS បាន 7.3% , PAN បាន 6.4% និងគណបក្សផ្សេងៗទៀតបាន 19.9% ។

## 2.2. ស្ថានភាពប្រជាជន



*ប្រជាជននៅកោះកាលីម៉ាន់តាន់ប្រទេសឥណ្ឌូណេស៊ី*

គេសម្គាល់ឃើញនៅតំបន់ព្រៃភ្នំនៃប្រទេសឥណ្ឌូនេស៊ី មានសេសសល់មនុស្សជំនាន់ដើមខ្លះ ដែលជាជនម្ចាស់ស្រុកដូចជា ពួកដាយ៉ាក់ (Dayak) រស់នៅលើកោះកាលីម៉ាន់តាន់ និងពួកបាតាក់ (Batak) លើកោះស៊ូម៉ាត្រា ។ នៅប្រទេសឥណ្ឌូណេស៊ី មានជិតមួយរយក្រុមជនជាតិ ។

សព្វថ្ងៃនេះមានប្រជាជនទាំងអស់ចំនួន 237 512 351 នាក់ (កក្កដា 2008 តាមការប៉ាន់ស្មាន) គិតជាដង់ស៊ីតេមធ្យមមាន 123.74 នាក់/$km^2$ ។ នៅអាស៊ីអាគ្នេយ៍ ឥណ្ឌូណេស៊ីបានទទួលចំណាត់ថ្នាក់លេខមួយខាងផ្ទៃដី និងខាងចំនួនប្រជាជន ។ កោះជ្វា កោះម៉ាឌូរ៉ា និងកោះបាលី មានផ្ទៃដីស្មើ 7% នៃផ្ទៃប្រទេស តែមានប្រជាជនដល់ទៅ 2/3 នៃប្រជាជនសរុប ។ ប្រជាជនឥណ្ឌូណេស៊ីភាគច្រើនលើសលុបចូលចិត្តរស់នៅតាមឆ្នេរសមុទ្រ (98.11%) ។

ឥណ្ឌូណេស៊ីមានប្រជាជនក្រុង 46.7% (ឆ្នាំ 2004) ។ អត្រានេះមានកម្រិតខ្ពស់ជាងនៅ ថៃ ឡាវ និងកម្ពុជា ។ ទីក្រុង 3 ធំជាងគេស្ថិតនៅលើកោះជ្វា គឺរដ្ឋធានីចាកាតា ទីក្រុងស៊ូរ៉ាបាយ៉ា និងបានឌុង ។

ទម្រង់ប្រជាជនឥណ្ឌូណេស៊ី បើធៀបទៅនឹងទម្រង់ប្រជាជនថៃឃើញថា ថៃមានលក្ខណៈប្រសើរជាង ដោយហេតុថា ក្រុមវ័យកុមារ(0-14 ឆ្នាំ) មានដល់ទៅ 28.4% (ថៃ 21.2%) ក្រុមវ័យពលកម្ម (15-64 ឆ្នាំ) មានត្រឹមតែ 65.7% (ថៃមាន 70.3%) ក្រុមមនុស្សចាស់ (65 ឆ្នាំឡើង) មាន 5.8% (ថៃមាន 8.5%) ។

បើគិតទៅតាមភេទវិញឃើញថា ចំនួនកុមារាមានច្រើនជាងចំនួនកុមារី (14.46% ទល់នឹង 13.96%) វ័យពលកម្មបុរសមានចំនួនច្រើនជាងស្ត្រី (32.98% ទល់នឹង 32.74%) វ័យមនុស្សចាស់ស្ត្រីច្រើនជាងបុរស (3.24% ទល់ 2.59%) ។

សូចនាករប្រជាសាស្ត្រឥណ្ឌូណេស៊ីផ្សេងៗទៀត មានអត្រាជាតិប្រមាណ 1.92% អត្រាមរណប្រមាណ 0.62% អត្រាកំណើន 1.30% អត្រាមរណៈកុមារ 3.10% នៃកំណើតរស់ ។ អត្រាលទ្ធភាពបង្កកំណើតសម្រាប់ស្ត្រីឥណ្ឌូណេស៊ីម្នាក់មាន 2.34 នាក់ ។ សង្ឃឹមរស់ពីកំណើតមាន 70.46 ឆ្នាំ បុរស 67.98 ឆ្នាំ ស្ត្រី 73.07 ឆ្នាំ ។ អត្រាអក្ខរភាពមាន 90.4% គិតពីអាយុ 15 ឆ្នាំឡើងដែលចេះអាន និងសរសេរ បុរស 94% ស្ត្រី 86.8% (ឆ្នាំ 2004) ។

ចំពោះក្រុមជនជាតិមាន ជនជាតិជ្វា 40.6% សាន់ដាន 15% ម៉ាឌួរ 3.3% មីណាងកាបូវ 2.7% បេតាវី 2.4% ប៊ូជីស 2.4% បានតិន 2% បានចារ 1.7% និងផ្សេងៗទៀត 29.9% (ជំរឿនឆ្នាំ 2000) ។

ផ្នែកជំនឿសាសនាមាន អ៊ីស្លាមសាសនិក 86.1% ប្រូតេស្តង់ 5.7% រ៉ូម៉ង់កាតូលិច 3% ហិណ្ឌូសាសនិក 1.8% និងផ្សេងៗទៀត 3.4% (ជំរឿនឆ្នាំ 2000) ។

ភាសាផ្លូវការ គឺភាសាបាហាសា(Bahasa) ចំណែកភាសាអង់គ្លេស និងហូឡង់ប្រើជាភាសាយាន និងគ្រាមភាសាដទៃទៀត ។

*សន្និដ្ឋាន* : ប្រទេសឥណ្ឌូណេស៊ីជាកម្រងកោះដ៏ធំបំផុតក្នុងលោក ជាកោះដែលស្ថិតនៅតាមខ្សែក្រវាត់ភ្លើងនៃប៉ាស៊ីហ្វិក សម្បូរភ្នំ ឆ្នេរ និងភ្នំភ្លើង ជួបគ្រោះថ្នាក់ធម្មជាតិញឹកញយ (បន្ទុះភ្នំភ្លើង រញ្ជួយដី រលកយក្សស៊ូណាមិ ) នៅអមសងខាងខ្សែអេក្វាទ័រសម្បូរភ្លៀង (ភ្លៀងធ្លាក់ស្ទើរពេញមួយឆ្នាំ) ។

ប្រទេសនេះមានអ្នកកាន់សាសនាអ៊ីស្លាមច្រើនជាងគេក្នុងពិភពលោក តែស្ត្រីឥណ្ឌូណេស៊ីមានអត្រាអក្ខរភាពខ្ពស់ជាងអត្រាអក្ខរភាពរបស់ស្ត្រីខ្មែរយើងទៅទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រជាជនឥណ្ឌូណេស៊ីមិនទាន់បានចេញផុតពីអនក្ខរភាពទាំងស្រុងនៅឡើយ ដោយនៅមានអនក្ខរជនចំនួន 9.6% ទៀត ។

ឥណ្ឌូណេស៊ី ជាប្រទេសសាធារណរដ្ឋបែបប្រធានាធិបតីនិយម ស្រដៀងគ្នានឹងសហរដ្ឋអាមេរិកដែរ គឺប្រធានាធិបតីមានអំណាចធំទូលាយជាង ។ ការប្រកាន់យករបបនយោបាយបែបប្រធានាធិបតីនិយមគួបផ្សំនឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យដ៏ត្រឹមត្រូវមួយ អាចនាំឱ្យសង្គមជាតិឥណ្ឌូណេស៊ីគេចផុតពីវិបត្តិនានា និងអភិវឌ្ឍឈានឡើងឆ្ពោះទៅរកភាពសម្បូរសប្បាយ កិត្យានុភាព និងមោទនភាពជាតិ ។

## ? សំណួរ

1. តើប្រទេសឥណ្ឌូណេស៊ីមានទីតាំងស្ថិតនៅត្រង់ណា ?
2. ហេតុអ្វីបានជាប្រទេសនេះសម្បូររញ្ជួយដី និងបន្ទុះភ្នំភ្លើង ?
3. ចូរនិយាយអំពីគ្រោះធម្មជាតិមួយដែលកើតមាននៅប្រទេសឥណ្ឌូណេស៊ីកាលពីថ្ងៃទី 26 ខែធ្នូ ឆ្នាំ 2004 ។
4. ចូររាប់ឈ្មោះកោះធំៗរបស់ប្រទេសឥណ្ឌូណេស៊ីឱ្យបានយ៉ាងតិច ៥ ។ តើកោះណាមួយដែលមានទីក្រុងធំៗ ? ទីក្រុងណាខ្លះ ?
5. តើអាកាសធាតុឥណ្ឌូណេស៊ី និងអាកាសធាតុកម្ពុជាដូចគ្នាដែរឬទេ? ព្រោះអ្វី ? ចូរពន្យល់ ។
6. តើប្រទេសឥណ្ឌូណេស៊ីប្រកាន់យករបបនយោបាយអ្វី?
7. តើរបបនយោបាយឥណ្ឌូនេស៊ី និងរបបនយោបាយឡាវខុសគ្នាដូចម្តេចខ្លះ ?
8. ចូរប្រៀបធៀបទម្រង់តាមអាយុនៃប្រជាជនឥណ្ឌូណេស៊ី និងថៃ ។
9. ចូរប្រៀបធៀបប្រទេសទាំងបួន កម្ពុជា ឡាវ ថៃ និងឥណ្ឌូណេស៊ីទៅលើចំណុចអត្រាអក្ខរភាព កម្រិតលទ្ធភាពបង្កកំណើត ប្រជាជនក្រុង និងសង្ឃឹមរស់ពីកំណើត ។
10. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះមួយមានន័យត្រឹមត្រូវ :

    ឥណ្ឌូណេស៊ី ប្រមុខរដ្ឋ ប្រធានាធិបតី ជា ផង និង ផង ជា ប្រមុខរដ្ឋាភិបាល ។

# 5 ប្រទេសភីលីពីន

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសណ្ឋានដីអាកាសធាតុ ផ្លូវទឹក ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជនហ្វីលីពីន ។

ប្រទេសហ្វីលីពីនធ្លាក់ក្រោមនឹមអាណានិគមប្រទេសអេស្ប៉ាញនៅសតវត្សទី 16 ក្លាយជាទឹកដីអាណានិគមរបស់សហរដ្ឋអាមេរិកលើកទី 1 ពីឆ្នាំ 1898 ដល់ ឆ្នាំ 1942 របស់ប្រទេសជប៉ុនពី ឆ្នាំ 1942 ដល់ ឆ្នាំ 1944 និងរបស់សហរដ្ឋអាមេរិកជាលើកទី 2 នៅឆ្នាំ 1945 ។ ប្រទេសនេះបានទទួលឯករាជ្យនៅថ្ងៃទី 4 ខែកក្កដា ឆ្នាំ 1946 និងមានឈ្មោះថា " **សាធារណរដ្ឋហ្វីលីពីន** " ។

ហ្វីលីពីន ជាកម្រងកោះមួយស្ថិតនៅភាគខាងកើតបំផុតនៃអាស៊ីអាគ្នេយ៍ ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ខាងកើតប្រទេសវៀតណាម ចន្លោះសមុទ្រហ្វីលីពីន និងសមុទ្រចិនខាងត្បូង ។ ប្រទេសហ្វីលីពីន មានកោះទាំងអស់ចំនួន 7107 មានផ្ទៃដីសរុប 300 000 $km^2$ មានឆ្នេរទាំងអស់ប្រវែង 36 289 km និងគ្មានព្រំដែនគោកជាប់ប្រទេសណាមួយឡើយ ។

## 1. លក្ខខណ្ឌធម្មជាតិ

### 1.1. សណ្ឋានដី

គេអាចចែកកោះទាំងអស់របស់ហ្វីលីពីន ជាបីក្រុមធំៗ គឺក្រុមកោះលូសុន ( 141 495 $km^2$) ក្រុមកោះវីសាយ៉ាស(56 605 $km^2$) និងក្រុមកោះមិនដាណាវ (102 000 $km^2$) ។ ក្នុងចំណោមកោះទាំងអស់ មានតែកោះចំនួនមួយពាន់ទេដែលមានមនុស្សរស់នៅ ។ អន្លង់បាតសមុទ្រនៅក្បែរកោះមិនដាណាវ មានជម្រៅ 10 830 m គឺជាតំបន់សំបកផែនដីស្តើងស្ថិតនៅតាមបណ្តោយខ្សែក្រវាត់ភ្លើងនៃមហាសមុទ្រប៉ាស៊ីហ្វិក ហ្វីលីពីន គឺសម្បូរភ្នំភ្លើងណាស់ដែរ ។ ប្រទេសនេះទទួលរងនូវចលនាតិចតូចនិចជាញឹកញាប់(រញ្ជួយដី និងបន្ទុះភ្នំភ្លើង) ។ ហ្វីលីពីនសម្បូរភ្នំ និងទំនាបតូចៗដែលស្ថិតនៅតាមបណ្តោយឆ្នេរ ។ ទំនាបធំៗក៏មានខ្លះៗដែរ ដូចជាទំនាបម៉ានីល ទំនាបកាកាយ៉ាន់នៅលើកោះលូសុន ទំនាបតូកាបាតូ និងទំនាបដាវ៉ៅនៅលើកោះមិនដាណាវ ។ កំពូលខ្ពស់នៃប្រទេសហ្វីលីពីន គឺភ្នំអាប៉ូ(2955m) ស្ថិតនៅលើកោះមិនដាណាវ ។



ផែនទីសណ្ឋានដីប្រទេសហ្វីលីពីន



តំបន់ទទួលឥទ្ធិពលព្យុះទីហ្វុង

## 1.2. អាកាសធាតុ និងផ្លូវទឹក

ទីតាំងភូមិសាស្ត្របង្ហាញថា ហ្វីលីពីនស្ថិតក្រោមឥទ្ធិពលអាកាសធាតុត្រូពិចសមុទ្របន្ថែមដោយខ្យល់មូសុងនិរតី និងឦសានដែលបង្កើតឱ្យមានរដូវពីរច្បាស់លាស់គឺ រដូវប្រាំងពីខែវិច្ឆិកាដល់ខែមេសា និងរដូវវស្សាពីខែឧសភាដល់ខែតុលា ។

សីតុណ្ហភាពប្រែប្រួលពី 21°C ដល់ 23°C ។ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំលើសពី 2 000 mm ។ ភ្លៀងធ្លាក់ច្រើនជាងគេនៅតំបន់បាំគីយ៉ូ (4 648 mm) និងតិចជាងគេនៅតំបន់ទំនាបកាកាយ៉ាន់ (1 300 mm) ។ តំបន់ទាំងពីរនេះស្ថិតនៅកោះលូសុនដូចគ្នា ។ ក្រៅពីគ្រោះមហន្តរាយបង្កឡើងដោយចលនាតិចតូនិច បាតុភូតអាកាសធាតុដ៏មហាប្រល័យមួយ គឺខ្យល់ព្យុះទីហ្វុងដែលតែងបក់បោកមកលើប្រទេសកោះនេះជាញឹកញាប់ ដូចជានៅចុងរដូវវស្សាឆ្នាំ 2009 ព្យុះកំណាចបី ឈ្មោះកេតសាណា(Ketsana) ប៉ារម៉ា (Parma) និងមីរីនេ (Mirinae) កើតមានជាបន្តបន្ទាប់ ហើយឆក់យកជីវិតប្រជាជនហ្វីលីពីនអស់ជាច្រើន និងបំផ្លិចបំផ្លាញផ្ទះសំបែង ទ្រព្យសម្បត្តិអស់ក៏មិនតិចដែរ ។ ចំណែកផ្លូវទឹកវិញ ដោយប្រទេសហ្វីលីពីនជាកម្រងកោះ សម្បូរភ្នំ និងសម្បូរភ្លៀង ទើបគេសង្កេតឃើញទន្លេឬស្ទឹងជាច្រើន មានបណ្តោយខ្លីៗ មិនអនុគ្រោះដល់ការធ្វើនាវាចរណ៍ឡើយ ។

## 2. ប្រពន្ធ័នយោបាយ និងស្ថានភាពប្រជាជន

### 2.1. ប្រព័ន្ធនយោបាយហ្វីលីពីន

ក្រោយពេលទទួលបានឯករាជ្យ ប្រទេសនេះមាននាមជាផ្លូវការថា "សាធារណរដ្ឋហ្វីលីពីន" ជាសាធារណរដ្ឋបែបប្រធានាធិបតីនិយម អនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ឈរលើគោលការណ៍បែងចែកអំណាចរវាងស្ថាប័នឯករាជ្យបីគឺ

#### ក. អំណាចនីតិប្រតិបត្តិ

រួមមានប្រធានាធិបតី អនុប្រធានាធិបតី និងគណៈរដ្ឋមន្ត្រី ។ ប្រធានាធិបតីជាប្រមុខរដ្ឋផង និងជាប្រមុខរដ្ឋាភិបាលផង ។ គណៈរដ្ឋមន្ត្រីបង្កើតឡើងដោយប្រធានាធិបតី ព្រមទាំងទទួលបានការយល់ព្រមពីគណៈកម្មការតែងតាំងផង ។ ប្រធានាធិបតី និងអនុប្រធានាធិបតីត្រូវជ្រើសតាំងដោយការបោះឆ្នោតពីប្រជាជន សម្រាប់អាណត្តិ 6ឆ្នាំ តាមបញ្ជីឈ្មោះពីរដាច់ពីគ្នា ។

#### ខ. អំណាចនីតិប្បញ្ញត្តិ

គឺជាសមាជិកដែលអមដោយសភាពីរមាន

- **ព្រឹទ្ធសភា** : មាន 24 អាសនៈ សម្រាប់អាណត្តិ 6ឆ្នាំ ជ្រើសតាំងដោយការបោះឆ្នោតពីសំណាក់ប្រជាជន ។
- **សភាតំណាងរាស្ត្រ** : មាន 239 អាសនៈ សម្រាប់អាណត្តិ 3ឆ្នាំ ជ្រើសតាំងដោយការបោះឆ្នោតពីសំណាក់ប្រជាជនដែរ ។

#### គ. អំណាចតុលាការ

មានតុលាការកំពូល សាលាឧទ្ធរណ៍ និងតុលាការពិសេស ។ តុលាការកំពូលមានចៅក្រម 15រូប ជ្រើសតាំងដោយប្រធានាធិបតី តាមអនុសាសន៍របស់ក្រុមប្រឹក្សានៃអង្គចៅក្រម និងបម្រើការងាររហូតដល់អាយុ 70ឆ្នាំ ។ តុលាការពិសេសសម្រេចរឿងក្តីនៃអំពើពុករលួយរបស់រដ្ឋាភិបាលស្របច្បាប់ ។

### 2.2. ស្ថានភាពប្រជាជនហ្វីលីពីន

ប្រទេសហ្វីលីពីនសព្វថ្ងៃនេះ មានប្រជាជនទាំងអស់ចំនួន 96 061 680 នាក់ (កក្កដា 2008 ប៉ាន់ស្មាន) គិតជាដង់ស៊ីតេមធ្យមមាន 320 នាក់/$km^2$ ជាប្រទេសមានផ្ទៃដីចង្អៀតទី 2 បន្ទាប់ពីសិង្ហបុរី ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ ។



*ប្រជាជនហ្វីលីពីន*

ប្រជាជនហ្វីលីពីនចម្រុះដោយជនជាតិដែលក្នុងនោះមានបីក្រុមធំៗ គឺពួកអ៊ីឡូកាណូ(Ilocano) ពួកតាកាឡុក(Tagalog) និងសេបូអាណូ(Ceboano)។ ជនជាតិដទៃទៀតមានពួកណេគ្រីតូ ឥណ្ឌូណេស៊ី អ៊ីកូរ៉ុត(Igorot) តាកាល់(Tagal) ប៊ីកូល(Bikol) វីសាយ៉ាន់(Visayan) ម៉ូរ៉ូ(Moro)... ។

## ក. ទម្រង់តាមអាយុនៃប្រជាជនហ្វីលីពីន

- ក្រុមវ័យកុមារ(0-14ឆ្នាំ) តាង 35.5% នៃប្រជាជនសរុប (ប្រុស 17 392 780 នាក់ ស្រី 16 708 255 នាក់)
- ក្រុមវ័យពលកម្ម(15-64ឆ្នាំ) តាងបាន 60.4% (ប្រុស 28 986 232 នាក់ ស្រី 29 076 329 នាក់)
- ក្រុមវ័យចំណាស់(65ឆ្នាំឡើង) តាងបាន 4.1% (ប្រុស 1 682 485 នាក់ ស្រី 2 215 602 នាក់)

## ខ. ទម្រង់តាមភេទ

កុមារាមានចំនួនច្រើនជាងកុមារី វ័យពលកម្មស្ត្រីមានចំនួនច្រើនជាងបុរស វ័យចំណាស់ស្ត្រីក៏មានចំនួនច្រើនជាងបុរសដែរ ។

ទាំងនេះបង្ហាញថា ប្រជាជនហ្វីលីពីនមានទម្រង់ក្មេងប្រហាក់ប្រហែលនឹងទម្រង់ប្រជាជនកម្ពុជា ឬបណ្ដាប្រទេសកំពុងអភិវឌ្ឍដទៃទៀតដែរ ។

គ. សូចនាករប្រជាសាស្ត្រហ្វីលីពីនផ្សេងៗទៀតមាន

- អត្រាជាតិប្រមាណ 2.64% អត្រាមរណប្រមាណ 0.51% ដូចនេះអត្រាកំណើនធម្មជាតិស្មើនឹង 2.13% អត្រាមរណៈកុមារ 2.12% នៃកំណើតរស់ ។
- អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីហ្វីលីពីន 3.32 នាក់ សង្ឃឹមរស់ពីកំណើត 70.8 ឆ្នាំ (បុរស 67.89 ឆ្នាំ ស្ត្រី 73.85 ឆ្នាំ) ។
- ភាគច្រើននៃប្រជាជនហ្វីលីពីនកាន់គ្រិស្តសាសនា និកាយរ៉ូម៉ាំងកាតូលិក 80.9% អ៊ីស្លាមសាសនិក 5% គ្រិស្តសាសនិកផ្សេងៗទៀត 4.5% និងក្រុមអ្នកគ្មានសាសនាពិតប្រាកដ ។

ភាសាផ្លូវការរបស់ហ្វីលីពីន គឺភាសាតាកាឡុក (Tagalog) និងមានគ្រាមភាសាជាង 80 ទៀត ។ ដើម្បីងាយស្រួលទាក់ទងគ្នា រដ្ឋាភិបាលប្រើប្រាស់ភាសាអង់គ្លេស ជាភាសាយាន ។ នៅសាលាបឋមសិក្សា ចំនួនម៉ោងសិក្សាភាសាអង់គ្លេសមានច្រើនស្មើគ្នានឹងភាសាជាតិដែរ ។ ពេលបញ្ចប់បឋមសិក្សា សិស្សចេះសរសេរ និងនិយាយភាសាអង់គ្លេសបាន ។ ហេតុនេះហើយបានជាប្រជាជនហ្វីលីពីន ច្រើនចេះភាសាអង់គ្លេស ។ ចំពោះអក្ខរភាពវិញ មនុស្សអាយុចាប់ពី 15 ឆ្នាំឡើង ដែលចេះអាន និងសរសេរបានមាន 92.6% នៃប្រជាជនសរុប(បុរស 92.5% ស្ត្រី 92.7% តាមជំរឿនឆ្នាំ 2000) ។ ប្រជាជនក្រុងមាន 61.8% (ឆ្នាំ 2004) ។

ដោយប្រទេសនេះ ស្ថិតនៅក្រោមអាណានិគមប្រទេសអេស្ប៉ាញដ៏យូរលង់ បន្ទាប់មកក្រោមឥទ្ធិពលសហរដ្ឋអាមេរិក ចាប់ពីក្រោយសង្គ្រាមលោកលើកទី 2 មក អរិយធម៌បស្ចិមប្រទេសបានជ្រួតជ្រាបពេញបន្ទុកក្នុងសង្គមហ្វីលីពីន ។ ម៉ានីល ជារដ្ឋធានីស្ថិតនៅត្រង់ឆកមួយនៃកោះលូសុនមានមនុស្សរស់នៅកកកុញ ។ ប្រជាជនហ្វីលីពីនមានកម្រិតជីវភាពខុសៗគ្នាទៅតាមតំបន់ ។

*សន្និដ្ឋាន :* ប្រទេសហ្វីលីពីន ជាកម្រងកោះស្ថិតនៅតាមបណ្តោយខ្សែក្រវាត់ភ្លើងនៃមហាសមុទ្រប៉ាស៊ីហ្វិក ។ ប្រទេសនេះសម្បូរគ្រោះធម្មជាតិធំៗដូចជា បន្ទុះភ្នំភ្លើង (ពីណាទូបូផ្ទុះខ្លាំងសម្បើមកាលពីថ្ងៃទី 15 ខែមិថុនា ឆ្នាំ 1991 បន្ទាប់ពីសម្ងំស្ងៀមអស់រយៈពេល 5 សតវត្សមក) រញ្ជួយដីនៅទីក្រុងម៉ានីល បានសម្លាប់មនុស្សអស់ 2 000 នាក់ ព្យុះទីហ្វុងឈ្មោះកេតសាណា កាលពីថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2009 បានសម្លាប់ប្រជាជនហ្វីលីពីនអស់ 246 នាក់ ។

ជាសាធារណរដ្ឋបែបប្រធានាធិបតីនិយម ប្រទេសហ្វីលីពីនបានអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ផ្អែកលើការបែងចែកអំណាចរវាងស្ថាប័នបីដាច់ចេញពីគ្នា ។ ប្រជាជនហ្វីលីពីនមានទម្រង់ក្មេង ដូចប្រទេសដទៃទៀតនៃលោកខាងត្បូងដែរ ។ ប្រជាជននេះច្រើននិយាយភាសាអង់គ្លេស និងកាន់សាសនាគ្រិស្ត ផ្ទុយពីកម្ពុជា ថៃ ឡាវ ដែលប្រជាជនភាគច្រើនកាន់សាសនាព្រះពុទ្ធ ។

## ? សំណួរ

1. តើប្រទេសហ្វីលីពីនមានទីតាំងស្ថិតនៅត្រង់ណា ?
2. តើកម្រងកោះហ្វីលីពីនអាចចែកចេញជាប៉ុន្មានក្រុមធំៗ ? អ្វីខ្លះ ?
3. ហេតុអ្វីបានជាប្រទេសហ្វីលីពីនសម្បូររញ្ជួយដី និងបន្ទុះភ្នំភ្លើង ?
4. តើអាកាសធាតុហ្វីលីពីនមានលក្ខណៈដូចម្ដេច ?
5. ហេតុអ្វីបានជាផ្លូវទឹកហ្វីលីពីនមានបណ្ដោយខ្លីៗ ?
6. ហេតុអ្វីបានជាប្រទេសហ្វីលីពីនជួបប្រទះព្យុះទីហ្វុងញឹកញាប់បែបនេះ ?
7. ជាទូទៅ តើប្រព័ន្ធនយោបាយហ្វីលីពីនមានលក្ខណៈដូចម្ដេច ?
8. ចូរប្រៀបធៀបស្ថាប័ននីតិប្រតិបត្តិហ្វីលីពីនទៅនឹងស្ថាប័ននីតិប្រតិបត្តិប្រទេសឡាវ ។
9. ចូរប្រៀបធៀបសូចនាករប្រជាសាស្ត្រហ្វីលីពីន និងកម្ពុជាលើចំណុច

   ក. លទ្ធភាពបង្កកំណើត

   ខ. សង្ឃឹមរស់ពីកំណើត

   គ. អត្រាអក្ខរភាព
10. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

    ក. រដ្ឋធានីប្រទេសហ្វីលីពីនមានឈ្មោះថា ................ ស្ថិតនៅលើកោះ ............... ។

    ខ. ព្យុះទីហ្វុងដែលបក់បោកមកពីលើប្រទេសហ្វីលីពីនជាបន្តបន្ទាប់នៅចុងរដូវវស្សាឆ្នាំ 2009 នេះ មានឈ្មោះ ............ ប៉ារម៉ា និង ............ ។
11. ចូរគណនាកំណើនប្រជាជនហ្វីលីពីន តាមបម្រាប់លេខខាងក្រោម

    - អត្រាកំណើនធម្មជាតិមាន 1.991% ។
    - ប្រជាជនមានចំនួនទាំងអស់ 96.06 លាននាក់ ។

# 6 ប្រទេសវៀតណាម

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីសណ្ឋានដី អាកាសធាតុ ផ្លូវទឹកនិងប្រព័ន្ធនយោបាយ ស្ថានភាពប្រជាជនវៀតណាម ។

ប្រទេសវៀតណាម ជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដីគោកស្ថិតនៅលើឧបទ្វីបឥណ្ឌូចិន ចន្លោះខ្សែស្របទី 8° 10 និង 23° 24 នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្ដោយទី 102° 09 និង 109° 30 នៃរយៈបណ្ដោយខាងកើត ។ ប្រទេសនេះមានរាងទ្រវែងដូចជាអក្សរ "S" មានផ្ទៃដី 330 991 km$^2$ មានព្រំដែនគោកជាប់នឹងប្រទេសកម្ពុជាផ្នែកខាងលិច និងខាងត្បូង ជាប់នឹងប្រទេសចិនផ្នែកខាងជើង (1 281km) និងជាប់ប្រទេសឡាវផ្នែកខាងលិច (2130 km) មានឆ្នេរប្រវែង 3444 km (មិនគិតកោះ) ។

វៀតណាម ជាអតីតទឹកដីអាណានិគមរបស់បារាំងដូចកម្ពុជា និងឡាវដែរ ហើយបានទទួលឯករាជ្យនៅឆ្នាំ 1954 តាមកិច្ចព្រមព្រៀងសឺណែវដែលបានចែកចេញជាពីរតាមខ្សែស្របទី 17 គឺវៀតណាមខាងជើងជាសាធារណរដ្ឋសង្គមនិយម និងវៀតណាមខាងត្បូងជាសាធារណរដ្ឋសេរី ។ រហូតមកដល់ឆ្នាំ1975 ទើបអាចរួបរួមជារដ្ឋតែមួយមានឈ្មោះថា "**សាធារណរដ្ឋសង្គមនិយមវៀតណាម**" និងមានទីក្រុងហាណូយជារដ្ឋធានី ។

## 1. លក្ខខណ្ឌធម្មជាតិ

### 1.1. សណ្ឋានដី

ប្រទេសវៀតណាមលាតសន្ធឹងពីជើងទៅត្បូងលើចម្ងាយ 1 650 km ពីលិចទៅកើតចម្ងាយអតិបរមា 600 km នៅតំបន់បាក់បូ (វៀតណាមខាងជើង) 50 km នៅតំបន់ទ្រុងបូ(វៀតណាមកណ្ដាល) និង 400 km នៅតំបន់ណាមបូ(វៀតណាមខាងត្បូង) ។

ប្រទេសនេះសម្បូរភ្នំ និងខ្ពង់រាប ដែលមានដល់ទៅ 3/4 នៃផ្ទៃប្រទេស ។ ប្រព័ន្ធភ្នំដែលសណ្ដូកពីព្រំដែនពាយ័ព្យដល់ប៉ែកខាងកើតតំបន់ណាមបូ មានបណ្ដោយ 1 400 km ។

**ភ្នំសំខាន់ៗមាន** : ហ្វាន់ស៊ីប៉ាន់ (3 143 m ជាកំពូលខ្ពស់នៅវៀតណាម) ពុយស៊ីលុង (3 076 m) ពុយខ្សៀឡឹង (2 711 m) ង៉ុកលិញ (2 598 m) និងកាយកុងលិញ (2 431 m) ។

ខ្ពង់រាបសំខាន់ៗមាន : ឡាំវៀន( 1500 m) ឌីលីញ(972 m) ផ្លេគូ(772 m) កនុំ(536 m) និង បួនមីថួត (461 m) ។

វៀតណាមមានទំនាបឆ្នេរតូចចង្អៀតហើយវែង ភ្ជាប់ដីសណ្ដទន្លេក្រហម(15 000 km$^2$)នៅប៉ែកខាងជើង មកដីសណ្ដទន្លេមេគង្គ (40 000 km$^2$) នៅប៉ែកខាងត្បូង ។ ដីសណ្ដពីរ មានរដ្ឋធានីពីររដ្ឋធានីហាណូយស្ថិតនៅតំបន់ដីសណ្ដទន្លេក្រហម ទីក្រុងហូជីមិញ(ព្រៃនគរ)តាំងនៅដីសណ្ដទន្លេមេគង្គ ។



ផែនទីសណ្ឋានដីវៀតណាម

## 1.2. អាកាសធាតុ

ប្រទេសវៀតណាម មានអាកាសធាតុខុសប្លែកពីប្រទេសដទៃទៀតនៃឧបទ្វីប ពិសេសរវាងភាគខាងជើង និងខាងត្បូងវៀតណាមខ្លួនឯងតែម្ដង ភាគខាងត្បូងក្ដៅហើយសើម ភាគខាងជើងត្រជាក់ខ្លាំងនៅសិសិររដូវ ។ ឆ្នេរភាគខាងជើងស្ថិតនៅចំមុខទិសខ្យល់ព្យុះទីហ្វុងដែលតែងបោកបក់ឆក់យកអាយុជីវិតមនុស្ស និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិម្ដងៗអស់មិនតិចទេ នៅចន្លោះខែឧសភា និងខែធ្នូ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលខ្លាំងដែលមួយផ្នែកបណ្ដាលមកពីព្យុះទីហ្វុងនោះ ។ ឆ្នេរភាគខាងត្បូងមានភ្លៀងធ្លាក់តិចជាង តែក្ដៅជាងឆ្នេរភាគខាងជើងសីតុណ្ហភាពមធ្យមប្រចាំឆ្នាំស្ថិតនៅជុំវិញ 26°C នៅទីក្រុងហូជីមិញ និង 17°C នៅទីក្រុងហាណូយ ។

## 1.3. ផ្លូវទឹក

ប្រទេសវៀតណាមមានទន្លេធំៗពីរហូរកាត់ទឹងប្រទេស ទន្លេមេគង្គហូរកាត់ភាគខាងត្បូងលើបណ្ដោយ 220 km ចាក់ទៅក្នុងសមុទ្រចិនខាងត្បូង ទន្លេក្រហមហូរកាត់ភាគខាងជើងលើបណ្ដោយ 510 km ហូរចាក់ទៅឈូងសមុទ្រតុងកឹង ។ ក្រៅពីទន្លេទាំងពីរនៅមានទន្លេ និងស្ទឹងជាច្រើនទៀតដូចជាទន្លេ សុងម៉ា សុងកា សុងចា ដុងណាយ ... ។ ទន្លេក្នុងប្រទេសនេះមានប្រវែងសរុប 41 000 km និងព្រែក 3100 km ។ ផ្លូវទឹកភាគច្រើន អាចស្ថាបនាទំនប់វារីអគ្គិសនីបាន ។

## 2. ប្រព័ន្ធនយោបាយ និងស្ថានភាពប្រជាជន

### 2.1. ប្រព័ន្ធនយោបាយ

ប្រទេសវៀតណាមមាននាមជាផ្លូវការថា "សាធារណរដ្ឋសង្គមនិយមវៀតណាម" ប្រកាន់យកមាគ៌ាអភិវឌ្ឍន៍ប្រទេសតាមបែបសង្គមនិយម មានទីក្រុងហាណូយជាទីក្រុងនយោបាយ ។ របបគ្រប់គ្រងនយោបាយរបស់ប្រទេសនេះមានស្ថាប័នបីដូចប្រទេសដទៃទៀតដែរ ពិសេសមានលក្ខណៈស្រដៀងគ្នានឹងប្រទេសឡាវដែលជារដ្ឋសង្គមនិយមដូចគ្នា ។

**ក. អំណាចនីតិប្រតិបត្តិ**

ស្ថិតនៅកណ្តាប់ដៃគណៈប្រធានរដ្ឋ និងរដ្ឋាភិបាល ។ គណៈប្រធានរដ្ឋរួមមាន ប្រធានាធិបតី និងអនុប្រធានាធិបតី ។ រដ្ឋាភិបាលរួមមាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីអចិន្ត្រៃយ៍មួយរូប និង ឧបនាយករដ្ឋមន្ត្រីបួនរូបទៀតជាជំនួយការ ។

គណៈប្រធានរដ្ឋជ្រើសតាំងក្នុងបណ្តាសមាជិកសភាតាមការបោះឆ្នោតនៅក្នុងសភាជាតិសម្រាប់អាណត្តិ 5ឆ្នាំ ។ នាយករដ្ឋមន្ត្រីតែងតាំងដោយប្រធានាធិបតី ក្នុងចំណោមសមាជិកសភាជាតិ ។ ឧបនាយករដ្ឋមន្ត្រីតែងតាំងដោយនាយករដ្ឋមន្ត្រី ។ ទាំងនាយករដ្ឋមន្ត្រី ទាំងឧបនាយករដ្ឋមន្ត្រីត្រូវទទួលបានការយល់ព្រមពីសភាជាតិ ។

គណៈរដ្ឋមន្ត្រីតែងតាំងដោយប្រធានាធិបតី តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី និងទទួលបានការយល់ព្រមពីសភាជាតិ ។

**ខ. អំណាចនីតិបញ្ញត្តិ**

ជារបស់សភាជាតិដែលមានទាំងអស់ចំនួន 500 អាសនៈ ។ សមាជិកសភាត្រូវបោះឆ្នោតជ្រើសរើសដោយប្រជាជនសម្រាប់អាណត្តិ 5 ឆ្នាំ ។

**គ. អំណាចតុលាការ**

ជារបស់តុលាការប្រជាជនជាន់ខ្ពស់ ហើយប្រធានតុលាការត្រូវជ្រើសតាំងដោយការបោះឆ្នោតក្នុងសភាជាតិ តាមអនុសាសន៍របស់ប្រធានាធិបតី ។

គណបក្សនយោបាយមានតែមួយ គឺគណបក្សកុម្មុយនីស្តវៀតណាម (CPV) ។ គណបក្សផ្សេងៗទៀតត្រូវហាមឃាត់ ។ របៀបរៀបចំផ្នែករដ្ឋបាលបានបែងចែកប្រទេសវៀតណាមជា 59 ខេត្ត និង 5 ទីក្រុង (កាន់ថឺ ដាណាំង ហៃផុង ហាណូយ និងហូជីមិញ) ។

## 2.2. ស្ថានភាពប្រជាជនវៀតណាម

ប្រទេសវៀតណាមសព្វថ្ងៃមានប្រជាជនទាំងអស់ 86 116 560 នាក់ (កក្កដា 2008 ការប៉ាន់ស្មាន) គិតជាដង់ស៊ីតេមធ្យមមាន 260 នាក់ / $km^2$ ។

### ក. ជនជាតិនានានៅវៀតណាម

ជនជាតិនានានៅវៀតណាមមានចំនួន 54 ក្រុម ។ ជនជាតិវៀតណាមមានចំនួន 86.2% នៃប្រជាជនសរុប រស់នៅពាសពេញផ្ទៃប្រទេស ពិសេសតាមដីសណ្ត ទំនាបឆ្នេរ ជ្រលងភ្នំ តាមបណ្តោយផ្លូវ ខ្ពង់រាប និងតាមកោះក្នុងលំហសមុទ្រ ។ ជនជាតិភាគតិច 53 ក្រុមទៀតត្រូវជា 13.8% នៃប្រជាជនទូទាំងប្រទេស ។ ជនជាតិខ្មែរ និងចាមរស់នៅតាមទំនាបណាមបូ និងទ្រុងបូ ។ ជនជាតិចិនរស់នៅក្នុងទីក្រុងហូជីមិញ ។ ចំណែកជនជាតិដទៃទៀតរស់នៅតំបន់ភ្នំ និងខ្ពង់រាបដូចជា ថៃ មឿង តាយ ធី នូយ ចារាយ បាណា ... ។

### ខ. កំណើនប្រជាជនវៀតណាម

ប្រជាជនវៀតណាមកើនឡើងយ៉ាងរហ័សពី 13 លាននាក់នៅឆ្នាំ 1901 ដល់ឆ្នាំ 79 លាននាក់នៅឆ្នាំ 1998 និង 86 លាននាក់ នៅឆ្នាំ 2008 និងអាចកើនដល់ 100 លាននាក់នៅឆ្នាំ 2025 ទើបមានលំនឹង ។ កំណើនដ៏លឿននេះ បណ្តាលមកពីចំនួនមនុស្សក្នុងកម្រិតបង្កកំណើតមានអត្រាខ្ពស់ ហើយគេពុំទាន់យល់ដឹងពីផែនការគ្រួសារ ។ កំណើនបែបនេះនាំមកនូវបញ្ហាសង្គម និងបរិស្ថានជាច្រើន ។ អាស្រ័យហេតុនេះហើយ ទើបរដ្ឋាភិបាលវៀតណាមដាក់ចេញផែនការគ្រួសារ ប្តីប្រពន្ធមួយគូៗត្រូវមានកូនមួយ ឬពីរនាក់ជាកំហិត ។ ផែនការនេះ សំដៅលើកស្ទួយកម្រិតជីវភាព និងធានាសុភមង្គលប្រជាជន ។

### គ. របាយប្រជាជនវៀតណាម

របាយប្រជាជនល្មៀងគ្នាឆ្ងាយណាស់រវាងតំបន់ទំនាប តំបន់ភ្នំ និងខ្ពង់រាប ។ តំបន់វាលរាបមានដង់ស៊ីតេមធ្យម 500 នាក់ / $km^2$ តំបន់ដីសណ្តទន្លេក្រហមមាន 800 នាក់ / $km^2$ តំបន់មាត់សមុទ្រភាគកណ្តាលមាន 500 នាក់ / $km^2$ និងតំបន់ដីសណ្តទន្លេមេគង្គមាន 350 នាក់ / $km^2$ ។ ចំណែកតំបន់ភ្នំ និងខ្ពង់រាបមានជាង 30 នាក់ / $km^2$ ប៉ុណ្ណោះ ។

### ឃ. ទម្រង់ប្រជាជនតាមអាយុ និងតាមភេទ

- ក្រុមវ័យកុមារ (0-14 ឆ្នាំ) គាង 25.6% នៃប្រជាជនសរុបដែលក្នុងនោះកុមារាមានចំនួន 51.86% និងកុមារីមានចំនួន 48.14% ឃើញថាកុមារាមានអត្រាខ្ពស់ជាងកុមារី ។

- ក្រុមវ័យពលកម្ម (15-64 ឆ្នាំ) តាងបាន 68.6% ដែលក្នុងនោះ បុរសមានចំនួន 49.63% និង ស្ត្រីមានចំនួន 50.37% ។ ក្នុងក្រុមនេះឃើញថាចំនួនស្ត្រីមានច្រើនជាងបុរស ។
- ក្រុមវ័យចំណាស់ (65 ឆ្នាំឡើង) មាន 5.8% ដែលក្នុងចំនួននោះ បុរសតាងបាន 38.66% និង ស្ត្រី 61.34% ។ ក្នុងក្រុមនេះ ឃើញថាចំនួនស្ត្រីមានច្រើនជាងបុរសឆ្ងាយណាស់ ។

តួលេខទាំងនេះបង្ហាញថា ប្រជាជនវៀតណាមនៅមានទម្រង់ក្មេងនៅឡើយ ប្រហាក់ប្រហែលគ្នានិងប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀតដែរ លើកលែងតែប្រទេសសិង្ហបុរីចេញ ។




*ផែនទីរបាយប្រជាជនវៀតណាម*

សូចនាករប្រជាសាស្ត្រវៀតណាមឆ្នាំ 2008 មួយចំនួនទៀតមាន

- អត្រាកំណើនធម្មជាតិ 1.03% អត្រាជាតិប្រមាណ 1.64% អត្រាមរណប្រមាណ 0.61% អត្រាមរណៈកុមារ 2.36% នៃកំណើនរស់ ។
- អត្រាអក្ខរភាព 90.3% នៃមនុស្សចេះអាន និងចេះសរសេរចាប់ពីអាយុ 15 ឆ្នាំឡើង លទ្ធភាពបង្កកំណើតមាន 1.86 នាក់សម្រាប់ស្ត្រីវៀតណាមម្នាក់ សង្ឃឹមរស់ពីកំណើតមាន 71.33 ឆ្នាំ (បុរសមាន 68.52 ឆ្នាំ ស្ត្រីមាន 74.33 ឆ្នាំ) ។ វៀតណាមមានប្រជាជនក្រុង 26.2% (ឆ្នាំ 2004) ។
- ចំពោះសាសនិកជនវិញមាន ពុទ្ធសាសនិកជន 9.3% កាតូលិកសាសនិក 6.7% ហ័រហោរ 1.5% កាវដាយ (1.1%) ប្រូតេស្តង់ (0.5%) អ៊ីស្លាមសាសនិក (0.1%)អ្នកគ្មានសាសនា 80.8% (ជំរឿន 1999) ។

- ភាសាវៀតណាមជាភាសាផ្លូវការ ភាសាអង់គ្លេសជាភាសាបន្ទាប់ទី 2 និងភាសាផ្សេងៗទៀត មានភាសាបារាំង ចិន ខ្មែរ និងភាសាតាមក្រុមជនជាតិ ។

*សន្និដ្ឋាន* : ប្រទេសវៀតណាមមានរាងជាអក្សរ "S" លាតសន្ធឹងពីជើងទៅត្បូងលើបណ្ដោយ 1650km ។ ប្រទេសវៀតណាម ជាទឹកដីសម្បូរភ្នំ និងខ្ពង់រាប សម្បូរគ្រោះធម្មជាតិ (ព្យុះទីហ្វុង ទឹកជំនន់) ជាប្រទេសសង្គមនិយមដែលសេដ្ឋកិច្ចបែបទីផ្សារសេរីមានគណបក្សទោល គឺបក្សកុម្មុយនីស វៀតណាម ។ ប្រទេសវៀតណាមមិនទាន់ចេញផុតពីអក្ខរភាពបានទាំងស្រុងនៅឡើយ (9.7%ជាអនក្ខរជន) តែសង្ឃឹមរស់ពីកំណើតរបស់ប្រជាជនវៀតណាមវែងជាងប្រជាជនកម្ពុជា និងឡាវ ។

## ? សំណួរ

1. តើប្រទេសវៀតណាមមានទីតាំងស្ថិតនៅត្រង់ណា?
2. តើតំបន់ទំនាបរបស់ប្រទេសវៀតណាមស្ថិតនៅត្រង់ណាខ្លះ?
3. តើទីក្រុងហាណូយ និងទីក្រុងហូជីមិញស្ថិតនៅតំបន់ណា?
4. តើអាកាសធាតុវៀតណាមមានលក្ខណៈដូចម្ដេច?
5. ចូរនិយាយពីប្រព័ន្ធនយោបាយវៀតណាម ។
6. តើប្រជាជនវៀតណាមមានរបាយដូចម្ដេច?
7. តើប្រជាជនវៀតណាមមានកំណើនដូចម្ដេច?
8. ចូរប្រៀបធៀបរបបនយោបាយវៀតណាម និងកម្ពុជា ។
9. ចូរប្រៀបធៀបទម្រង់តាមអាយុនៃប្រជាជនវៀតណាម និងថៃ ។
10. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះ ក និងល្បះ ខ មានន័យត្រឹមត្រូវ

    ក. ក្ដៅហើយសើម ចំណែក សិសិររដូវ ភាគខាងត្បូង ភាគខាងជើង នៅ ត្រជាក់ខ្លាំង មាន អាកាសធាតុ ប្រទេសវៀតណាម ។

    ខ. ដីសណ្ដទន្លេក្រហម ដីសណ្ដទន្លេមេគង្គ ទំនាបឆ្នេរ មាន មក តូចចង្អៀត ភ្ជាប់ ហើយវែង វៀតណាម នៅប៉ែកខាងជើង នៅប៉ែកខាងត្បូង ។
11. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

    ក. លទ្ធភាពបង្កកំណើតរបស់ស្ត្រីវៀតណាម .................. លទ្ធភាពបង្កកំណើតរបស់ស្ត្រីហ្វីលីពីន ។

    ខ. រដ្ឋធានីហាណូយមានទីតាំងស្ថិតនៅតំបន់ ........... នៃ ............... ។

# 7 ប្រទេសទីម័រខាងកើត

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសណ្ឋានដី ផ្លូវទឹក អាកាសធាតុ និងប្រព័ន្ធនយោបាយ
- ❑ ស្ថានភាពប្រជាជនទីម័រខាងកើត ។

ដោយទីម័រខាងកើត (ទីម័រលេស) ជាប្រទេសថ្មីមុននិងសិក្សាបានច្បាស់ពីមជ្ឈដ្ឋានធម្មជាតិ និងសង្គមទីម័រ យើងត្រូវតែយល់ដឹងពីអតីតកាលនៃទឹកដីនេះជាមុនសិន ។

## 1. អតីតកាល

នៅដើមសតវត្សទី 16 ជនជាតិព័រទុយហ្គាល់បានចូលមកធ្វើជំនួញនៅលើកោះទីម័រ រួចបានយកធ្វើជាទឹកដីអាណានិគមរបស់ខ្លួននៅពាក់កណ្ដាលសតវត្សទី 16 ។ ក្រោយមក បន្ទាប់ពីមានការប៉ះទង្គិចដោយអាវុធជាមួយពួកហូឡង់ និងតាមកិច្ចព្រមព្រៀងឆ្នាំ 1859 កោះទីម័រត្រូវបែងចែកជាពីរ មួយកំណាត់កោះខាងលិចត្រួតត្រាដោយពួកហូឡង់ និងមួយកំណាត់ខាងកើតជារបស់ពួកព័រទុយហ្គាល់ ។ ពីឆ្នាំ 1942 ដល់ឆ្នាំ 1945 ទីម័រខាងកើតត្រូវពួកជប៉ុនចូលកាន់កាប់ ។ ក្រោយពេលជប៉ុនចាញ់ក្នុងសង្គ្រាមលោកលើកទី 2 ពួកព័រទុយហ្គាល់ត្រឡប់មកត្រួតត្រាទីម័រខាងកើតជាថ្មី ។

ថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 1975 ទីម័រខាងកើតបានប្រកាសឯករាជ្យចេញពីនឹមត្រួតត្រាព័រទុយហ្គាល់ ។ តែ 9 ថ្ងៃក្រោយមក កងទ័ពឥណ្ឌូណេស៊ីបានចូលលុកលុយ និងកាន់កាប់ទីម័រខាងកើត ព្រមទាំងដាក់បញ្ចូលទៅក្នុងទឹកដីឥណ្ឌូណេស៊ីជាខេត្តមួយឈ្មោះថា ទីម័រទីមួ(ទីម័រខាងកើត)នៅខែកក្កដា ឆ្នាំ 1976 ។

ការប្រយុទ្ធដើម្បីសន្តិភាពមិនបានសម្រេចជោគជ័យមួយ បានប្រព្រឹត្តទៅអស់រយៈពេលជាងពីរទសវត្សរ៍ បណ្ដាលឱ្យបាត់បង់ជីវិតមនុស្សអស់ពី 100 000 ទៅ 250 000 នាក់ ។ ការធ្វើប្រជាមតិមួយដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ(30 សីហា 1999)បានបង្ហាញថា ប្រជាជនទីម័រខាងកើតភាគច្រើនលើសលប់ចង់បានឯករាជ្យដាច់ចេញពីប្រទេសឥណ្ឌូណេស៊ី ។

នៅខែកញ្ញា ឆ្នាំ 1999 កងជីវពលប្រឆាំងឯករាជ្យដែលបង្កើតឡើងនិងគាំទ្រដោយកងទ័ពឥណ្ឌូណេស៊ី បានបើកការប្រយុទ្ធសងសឹកធំធេង និងយ៉ាងព្រៃផ្សៃ សម្លាប់ប្រជាជនទីម័រខាងកើតអស់ជិត 1 400 នាក់ និងជន្លៀសប្រជាជនដោយបង្ខំ ឱ្យទៅរស់នៅទីម័រខាងលិចចំនួន 300 000 នាក់ ។

នៅថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 1999 កងកម្លាំងរក្សាសន្តិភាពអូស្ត្រាលី ក្នុងនាមកងកម្លាំងអន្តរជាតិ ដើម្បីទីម័រខាងកើតហៅថា INTERFET (International Force For East Timor) បានចូលមកធ្វើអន្តរាគមន៍បញ្ចប់អំពើហិង្សា ។ ថ្ងៃទី 20 ខែឧសភា ឆ្នាំ 2002 ទីម័រលេស ត្រូវបានទទួលស្គាល់ជាអន្តជាតិថា ជារដ្ឋឯករាជ្យ ។

នៅចុងខែមេសា ឆ្នាំ 2006 ភាពតានតឹងផ្ទៃក្នុងមួយ បានគំរាមកំហែងសន្តិសុខប្រជាជាតិដ៏ក្មេងខ្ចីនេះ ។ ឆ្លើយតបតាមសំណើសុំរបស់រដ្ឋាភិបាលទីម័រខាងកើត កងកម្លាំងស្ថិរកម្មអន្តរជាតិ ISF (International Stabilization Force) ជាតិអូស្ត្រាលីបានចូលមកធ្វើអន្តរាគមន៍ នៅចុងខែឧសភា ឆ្នាំ 2006 ។ នៅខែសីហា ឆ្នាំ 2006 ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបញ្ជូន "ក្រុមបេសកកម្មសម្រាប់សមាហរណកម្មនៃសហប្រជាជាតិនៅទីម័រខាងកើត" UNMIT ( UN Intergrated Mission of Timor-Leste) ជំនួសឱ្យ ISF ។ ពីខែមេសាដល់ខែមិថុនា ឆ្នាំ 2007 រដ្ឋាភិបាលទីម័រខាងកើតបានធ្វើការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអ្នកតំណាងរាស្ត្រក្នុងបរិយាកាសប្រកបដោយសន្តិភាពក្រោមជំនួយឧបត្ថម្ភពី UNMIT និងអ្នកផ្តល់អំណោយអន្តរជាតិ ។

# 1. លក្ខខណ្ឌធម្មជាតិ

## 1.1. ទីតាំងភូមិសាស្ត្រ

ទីម័រខាងកើតជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដីកោះ ស្ថិតនៅទិសពាយ័ព្យប្រទេសអូស្ត្រាលី ក្នុងប្រជុំកោះសុងតូច ចុងខាងកើតនៅកម្រងកោះឥណ្ឌូណេស៊ី រួមមានពាក់កណ្តាលខាងកើតនៃកោះទីម័រ តំបន់អ៊ីគូស៊ី ឬអំបឺណូ (Oecussi / Ambeno) ជាផ្ទៃកតូចមួយនៃភាគពាយ័ព្យនៃកោះ បូកទាំងកោះអាតួរ៉ូ និងកោះចាកូ ។ កូអរដោនេភូមិសាស្ត្រនៃប្រទេសនេះ គឺស្ថិតចន្លោះខ្សែស្របទី 8° និងទី 10° នៃរយៈទទឹងខាងត្បូង និងចន្លោះខ្សែបណ្តោយទី 124° និងទី 128° នៃរយៈបណ្តោយខាងកើត ។ ទីម័រខាងកើតមានផ្ទៃដីសរុប 15 007 $km^2$ ធំជាងប្រទេសព្រុយណេ និងសិង្ហបុរី ប៉ុន្តែតូចជាងប្រទេសកម្ពុជាប្រហែល 12ដង មានព្រំដែនជាប់ឥណ្ឌូណេស៊ី(ខេត្តទីម័រខាងលិច)ប្រវែង 228 km និងឆ្នេរប្រវែង 706 km ។

## 1.2. សណ្ឋានដី

ទីម័រខាងកើត ជាប្រទេសសម្បូរភ្នំនិងខ្ពង់រាប ខ្សត់ទំនាប(ទំនាបឆ្នេរតូចចង្អៀត)មានកំពូលខ្ពស់គឺភ្នំហ្វូហ្វូតាតាម៉េឡូ (2963 m) ព័ទ្ធជុំវិញដោយសមុទ្រទីម័រ សមុទ្រសាវូ និងសមុទ្របានដា ។ ដីភ្ជួររាស់ 8.2% ដីដាំដុះ 0.45% និងដីផ្សេងៗទៀត 8.723% ។ ដីបញ្ចូលទឹកមាន 1 065 $km^2$ ។ ប្រទេសនេះតែងជួបគ្រោះទឹកជំនន់ ការបាក់ដី ការរញ្ជួយដី ស៊ូណាមី និងព្យុះស៊ីក្លូនត្រូពិច ។




*ផែនទីប្រទេសទីម័រខាងកើត*

## 1.3. អាកាសធាតុ និងផ្លូវទឹក

កូអរដោនេភូមិសាស្ត្របង្ហាញថា ទីម័រខាងកើតស្ថិតក្រោមឥទ្ធិពលអាកាសធាតុត្រូពិចមូសុងសមុទ្រក្តៅសើម មានរដូវពីរច្បាស់លាស់គឺ រដូវប្រាំង (ពីខែមេសាដល់ខែកញ្ញា) និងរដូវវស្សា (ពីខែតុលាដល់ខែមីនា) ។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំប្រហែល 26°C ។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំខ្ពស់ជាង 1 000 mm ។ មូសុងប្រាំងបក់មកពីទិសអាគ្នេយ៍ និងមូសុងវស្សាបក់មកពីទិសពាយ័ព្យ ។

ផ្លូវទឹកប្រទេសនេះច្រើនខ្លីៗ ហូរចុះពីទីខ្ពស់កាត់ទំនាបឆ្នេរដ៏តូចចង្អៀត រួចចាក់ទៅក្នុងសមុទ្រ ដែលគេអាចប្រើប្រាស់សម្រាប់បញ្ចូលទឹកលើផ្ទៃដីបាន 1 065 $km^2$ និងសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកសាបផងដែរ ។

# 2. លក្ខខណ្ឌសង្គម

## 2.1. ប្រព័ន្ធនយោបាយ

ប្រទេសនេះមាននាមជាផ្លូវការថា"សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត" និងមានរដ្ឋធានីឈ្មោះទីក្រុងឌីលី (Di Li) ។

របបគ្រប់គ្រងផ្នែកនយោបាយរបស់ទីម័រខាងកើតចែកចេញជាស្ថាប័នឯករាជ្យបីគឺ

### ក. អំណាចនីតិប្រតិបត្តិ

រួមមានប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល

- ប្រមុខរដ្ឋ គឺជាប្រធានាធិបតីជ្រើសរើសតាមការបោះឆ្នោតដោយសេរីជាសកលពីប្រជាពលរដ្ឋផ្ទាល់សម្រាប់អាណត្តិ 5 ឆ្នាំមានអំណាចឬតួនាទីធំទូលាយណាស់ព្រោះអាចមានសិទ្ធិជំទាស់ (វេតូ) ទៅនឹងសេចក្តីសម្រេចរបស់សភាហើយអាចរំលាយសភា និងកោះហៅការបោះឆ្នោតសាជាថ្មី ។
- ប្រមុខរដ្ឋាភិបាលមាននាយករដ្ឋមន្ត្រីមួយរូប និងឧបនាយករដ្ឋមន្ត្រីមួយរូប ។ មេដឹកនាំគណបក្សដែលទទួលបានសំឡេងភាគច្រើន ឬក៏រដ្ឋាភិបាលចម្រុះ (សម្ព័ន្ធភាពគណបក្ស) ត្រូវបានជ្រើសតាំងដោយប្រធានាធិបតីឱ្យធ្វើជានាយករដ្ឋមន្ត្រី ។

### ខ. អំណាចនីតិបញ្ញត្តិ

មានសភាតែមួយគឺរដ្ឋសភា(សភាជាតិ)ដែលមានចំនួនអាសនៈប្រែប្រួលពី 52 ទៅ 65 ។

សមាជិកសភាត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋសម្រាប់អាណត្តិ 5 ឆ្នាំ ។ កាលពីសម័យបោះឆ្នោតថ្ងៃទី 30 មិថុនា 2007 ចំនួនអាសនៈរបស់គណបក្សឈ្នះឆ្នោតមាន FRETILIN 21 អាសនៈ CNRT 18 អាសនៈ ASDT-PSD 11 អាសនៈ PD 8 អាសនៈ PUN 3 អាសនៈ KOTA-PPT 2 អាសនៈ UNDERTIM 2 អាសនៈ សរុបមានទាំងអស់ 65 អាសនៈ ។

### គ. អំណាចតុលាការ

មានតុលាការកំពូលនៃយុត្តិធម៌

រដ្ឋធម្មនុញ្ញត្រូវការចៅក្រមម្នាក់ ដើម្បីដាក់ឱ្យសភាជាតិជ្រើសតាំង ហើយក្រៅពីនេះត្រូវជ្រើសតាំងដោយក្រុមប្រឹក្សាជាន់ខ្ពស់នៃអង្គចៅក្រម ។ ទម្រាំតែតុលាការកំពូលត្រូវបានបង្កើតរួចរាល់ហើយនោះ សាលាឧទ្ធរណ៍នៅតែជាតុលាការថ្នាក់ខ្ពស់បំផុត ។

## 2.2. ស្ថានភាពប្រជាជនទីម័រខាងកើត



*ប្រជាជនទីម័រខាងកើត*

### ក. លក្ខណៈទូទៅ

ទីម័រខាងកើតមានប្រជាជនទាំងអស់ 947 000 នាក់ (ឆ្នាំ 2005) 1 108 777 នាក់ (កក្កដា 2008 ការប៉ាន់ស្មាន) គិតជាដង់ស៊ីតេមធ្យមមាន 73.88 នាក់ / km$^2$ ទាបជាងកម្ពុជាបន្តិច(75 នាក់ / km$^2$ )ខ្ពស់ជាងប្រទេសឡាវ(28 នាក់ / km$^2$ ) ។

ចំពោះក្រុមជនជាតិវិញ គេឃើញមានក្រុមជនជាតិអំបូរអូស្ត្រូណេស៊ី(ម៉ាឡាយូ-ប៉ូលីនេស៊ី) អំបូរប៉ាពូអាន និងអណិកជនចិនតិចតួច ។ ផ្នែកជំនឿសាសនាវិញមាន រ៉ូម៉ាំងកាតូលិក (98%) អ៊ីស្លាមសាសនិក(1%) និងប្រូតេស្តង់(1%) ។ ភាសាផ្លូវការ គឺភាសាតាទុមនិងព័រទុយហ្គាល់ ។ ក្រៅពីនេះមានភាសាឥណ្ឌូណេស៊ី អង់គ្លេស និងគ្រាមភាសាចំនួនប្រហែល 16 ទៀត ។ ភាសាតាទុម(Tatum) ហ្គាឡូល(Ga Lole) ម៉ំមបេ(Mambae) និងខេម៉ាក (Kemak)ត្រូវបាននិយាយដោយប្រជាជនក្នុងចំនួនច្រើនគួរឱ្យកត់សម្គាល់ ។

### ខ. ទម្រង់ប្រជាជន

- ក្រុមវ័យកុមារ(0-14 ឆ្នាំ)មាន 35.1% ដែលក្នុងនោះកុមារាមានចំនួន 197 975 នាក់ និងកុមារីមាន 191 716 នាក់ (កុមារាមានចំនួនច្រើនជាងកុមារី) ។
- ក្រុមវ័យពលកម្ម(15-64 ឆ្នាំ) មាន 6.16% ដែលក្នុងនោះបុរសមាន 347 573 នាក់ និងស្ត្រីមាន 334 908 នាក់(បុរសមានចំនួនច្រើនជាងស្ត្រី) ។
- ក្រុមមនុស្សចាស់ (65 ឆ្នាំឡើង) មាន 3.3% ដែលក្នុងនោះបុរសមាន 17 578 នាក់ និងស្ត្រីមាន 19 027 នាក់ (ស្ត្រីមានចំនួនច្រើនជាងបុរស) ។

## គ. សូចនាករប្រជាសាស្ត្រទីម័រខាងកើតផ្សេងៗទៀត

នៅឆ្នាំ 2008 ទីម័រខាងកើតមានអត្រាជាតិប្រមាណ 2.65% អត្រាមរណប្រមាណ 0.60% និងអត្រាកំណើតធម្មជាតិ 0.20% ។ អត្រាមរណៈកុមារ 4.19% នៃកំណើតរស់ ។ កម្រិតលទ្ធភាពបង្កកំណើតរបស់ស្ត្រីទីម័រមាន 3.36 នាក់ ។ សង្ឃឹមរស់ពីកំណើតមាន 66.94 ឆ្នាំ បុរស 64.6 ឆ្នាំ និងស្ត្រី 69.39 ឆ្នាំ ។ ប្រជាជនក្រុងមាន 7.7% (ឆ្នាំ 2004) ។ ចំណែកអក្ខរភាពប្រជាជនវិញតាងបាន 58.6% (ចាប់ពីអាយុ 15 ឆ្នាំឡើងដែលចេះអាន និងសរសេរបាន) ។

*សន្និដ្ឋាន :* ដោយធ្លាប់បានឆ្លងកាត់អតីតកាលដ៏ខ្មៅងងឹតអស់រយៈពេលប្រហែល 4 សតវត្សជាង ទើបទីម័រខាងកើតបានទទួលបានពន្លឺនៃសន្តិភាព និងឯករាជ្យភាពពិតប្រាកដដែលទទួលស្គាល់ជាអន្តរជាតិ ។ ក្នុងស្ថានភាពជាប្រទេសកើតថ្មី ទីម័រខាងកើតប្រាកដជាជួបការលំបាកច្រើនក្នុងការរៀបចំសង្គម និងកសាងទឹកដីឱ្យរីកចម្រើន រត់ឱ្យទាន់ប្រទេសនានាក្នុងតំបន់ ។ ប្រសិនបើគ្មានជំនួយឧបត្ថម្ភ គាំពារដ៏រឹងមាំពីអង្គការសហប្រជាជាតិ ពីសហគមន៍អន្តរជាតិ ពិសេសបើគ្មានមនសិការស្នេហាជាតិខ្ពស់របស់ប្រជាជន និងយុទ្ធជនទីម័រខាងកើតទេនោះ ទីម័រខាងកើតនឹងមិនមានឈ្មោះលើផែនទីពិភពលោកទៀតឡើយ ។

## ? សំណួរ

1. តើមានបញ្ហាអ្វីកើតឡើងនៅទីម័រខាងកើត ក្រោយពេលប្រកាសឯករាជ្យពីនឹមត្រួតត្រារបស់ព័រទុយហ្គាល់ ?
2. តើការធ្វើប្រជាមតិនៅទីម័រខាងកើត ថ្ងៃទី 30 ខែសីហា ឆ្នាំ 1999 ទទួលបានលទ្ធផលដូចម្តេច ?
3. តើកងជីវពលប្រឆាំងឯករាជ្យទីម័រខាងកើតគាំទ្រដោយអ្នកណា ? តើពួកនេះបានប្រព្រឹត្តអំពើអ្វីខ្លះ ?
4. តើអំពើហិង្សាប្រឆាំងឯករាជ្យទីម័រខាងកើតបញ្ចប់ទៅយ៉ាងដូចម្តេច ? ហើយអន្តរជាតិទទួលស្គាល់ឯករាជ្យទីម័រខាងកើតនៅថ្ងៃ ខែ ឆ្នាំណា ?
5. តើទីម័រខាងកើតតែងជួបប្រទះនឹងគ្រោះធម្មជាតិអ្វីខ្លះ ?
6. ចូរនិយាយដោយសង្ខេបពីលក្ខខណ្ឌធម្មជាតិរបស់ប្រទេសទីម័រខាងកើត ។
7. ចូរប្រៀបធៀបប្រព័ន្ធនយោបាយរបស់ប្រទេសទាំងពីរ គឺទីម័រខាងកើត និងប្រទេសភីលីពីន ។
8. ចូរប្រៀបធៀបទម្រង់ប្រជាជនតាមអាយុ និងតាមភេទនៃប្រទេសទាំងពីរ គឺទីម័រខាងកើត និងកម្ពុជា ។

## ? សំណួរបញ្ចប់ជំពូកទី១

**I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រូវដែលមានតែមួយគត់ :**

1. នៅអាស៊ីអាគ្នេយ៍ប្រទេសដែលប្រកាន់យករបបសាធារណរដ្ឋប្រជាធិបតេយ្យបែបសេរីគឺ

☐ក. កម្ពុជា ☐ខ. វៀតណាម ☐គ. ឡាវ ☐ឃ. ហ្វីលីពីន ។

2. កាលពីថ្ងៃទី 15 មិថុនា 1991 នៅអាស៊ីអាគ្នេយ៍មានបាតុភូតធម្មជាតិដ៏សំខាន់មួយបានកើតឡើងគឺ

☐ក. បន្ទុះភ្នំភ្លើងក្រាកាតូ ☐ខ. បន្ទុះភ្នំភ្លើងពីណាទូបូ

☐គ. រលកយក្សស៊ូណាមិ ☐ឃ. ព្យុះទីហ្វុងកេតសាណា ។

3. ភ្នំភ្លើងពីណាទូបូស្ថិតនៅក្នុងប្រទេសណា :

☐ក. ហ្វីលីពីន ☐ខ. ឥណ្ឌូណេស៊ី ☐គ. ព្រុយណេ ☐ឃ. ទីម័រខាងកើត ។

4. ប្រទេសហ្វីលីពីនប្រកាន់យករបបគ្រប់គ្រងនយោបាយតាមបែប

☐ក. រាជាធិបតេយ្យផ្តាច់ការ ☐ខ. រាជាធិបតេយ្យអាស្រ័យសភា

☐គ. សាធារណរដ្ឋផ្តាច់ការ ☐ឃ. សាធារណរដ្ឋសេរី ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :**

1. នៅអាស៊ីអាគ្នេយ៍ប្រទេសដែលប្រកាន់យករបបសង្គមនិយម គឺ .................. និង .................. ។
2. ក្នុងបណ្តាប្រទេសទាំង 7 នៃអាស៊ីអាគ្នេយ៍ដែលយើងសិក្សារួចមកហើយ ប្រទេសដែលមានប្រជាជនតិចជាងគេ គឺ .............................. ។
3. ខេត្តកំពង់ចាមមានទីក្រុងពីរ គឺ .................. និង .............................. ។
4. ប្រទេសឥណ្ឌូណេស៊ីមាននាមជាផ្លូវការថា .............................. ។

**III. ចូរឆ្លើយសំណួរខាងក្រោម**

1. តើកម្រងកោះហ្វីលីពីនអាចចែកចេញជាប៉ុន្មានក្រុមធំៗ ? អ្វីខ្លះ ? ចូររៀបរាប់ ។
2. តើរបបនយោបាយរបស់ប្រទេសឡាវ និងឥណ្ឌូណេស៊ីខុសគ្នាដូចម្តេចខ្លះ ?
3. ចូរប្រៀបធៀបអត្រាអក្ខរភាព កម្រិតលទ្ធភាពបង្កកំណើត អត្រាប្រជាជនក្រុង និងសង្ឃឹមរស់ពីកំណើតនៃប្រទេសទាំងបួនគឺ កម្ពុជា ឡាវ ថៃ និងឥណ្ឌូនេស៊ី ។
4. តើទម្រង់ប្រជាជនកម្ពុជាមានការប្រែប្រួលដូចម្តេចខ្លះ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ (1998-2008) ?

# ជំពូកទី 2 ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ



*សង្កាត់ក្រីក្រនៃទីក្រុងមួយនៅទ្វីបអាហ្វ្រិក*

ការអភិវឌ្ឍប្រទេស ឬសង្គមមួយ គឺជាដំណើរដែលនាំឱ្យប្រទេសឬសង្គមនោះឈានទៅពង្រីកលទ្ធភាព ដើម្បីបំពេញនូវតម្រូវការសំខាន់ៗសម្រាប់ជីវិតសមាជិកខ្លួនឱ្យទទួលបានការអប់រំ សុខភាព និងកម្រិតជីវភាពមួយសមស្រប ។

យោលទៅតាមកម្រិតនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច គេចែកប្រទេសនានាក្នុងសកលលោកជាពីរក្រុមធំៗ គឺប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ ។ គេសង្កេតឃើញផងដែរថា ក្នុងក្រុមប្រទេសនីមួយៗកម្រិតអភិវឌ្ឍវាមិនដូចគ្នានោះទេ ។ ទោះបីជាមានឈ្មោះថា ជាប្រទេសកំពុងអភិវឌ្ឍក្តី ឬប្រទេសអភិវឌ្ឍក្តី ការអភិវឌ្ឍនៅតែមានតួនាទីសំខាន់ជានិច្ចក្នុងការរក្សា និងលើកកម្ពស់សង្គមសេដ្ឋកិច្ចរបស់ប្រជាជាតិនីមួយៗ ។

# 1 ប្រទេសកំពុងអភិវឌ្ឍ

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីស្ថានភាពប្រជាជន ជីវភាព របបអាហារ សុខាភិបាល អប់រំ ការគោរពច្បាប់ និងតួនាទីនៃការអភិវឌ្ឍក្នុងប្រទេសកំពុងអភិវឌ្ឍ ។

ប្រទេសកំពុងអភិវឌ្ឍច្រើនតែជាប្រទេសអតីតអាណានិគមដែលទទួលបានឯករាជ្យក្រោយសង្គ្រាមលោកលើកទី 2 ហើយដែលមានសេដ្ឋកិច្ចនៅអន់ថយនៅឡើយមកទល់បច្ចុប្បន្ននេះ ។ ប៉ុន្តែដោយសារការខិតខំប្រឹងប្រែងក្នុងការកសាងសង្គមសេដ្ឋកិច្ចខ្លួន ប្រទេសកំពុងអភិវឌ្ឍមួយចំនួនបានក្លាយទៅជាប្រទេសនាគឬកូននាគទៅហើយ ។ ទន្ទឹមនឹងនេះ ប្រទេសមួយចំនួនទៀតកំពុងស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្ររាំរាមកំហែងដោយការបរិភោគខ្វះខាត គ្រោះទុរ្ភិក្ស និងជំងឺរាតត្បាតផ្សេងៗ ។

## 1. ស្ថានភាពប្រជាជន

### 1.1. ជីវភាពប្រជាជន



*ភាពក្រីក្រនៅប្រទេសនីសេរីយ៉ា*

មនុស្សប្រហែល 1 200 លាននាក់ រស់នៅជាមួយប្រាក់កម្រៃតិចជាងមួយដុល្លារក្នុងមួយថ្ងៃ ។ ភាពក្រីក្រជាកង្វល់មួយរ៉ាំរ៉ៃរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍ ។ ចំនួនប្រជាជនក្រីក្របំផុតក្នុងពិភពលោក បានចុះថយពី 40% មកនៅត្រឹម 21% (ពីឆ្នាំ 1981 មកឆ្នាំ 2001) ជាពិសេសដោយសារកំណើនសេដ្ឋកិច្ច នៅប្រទេសអាស៊ី ។ កង្វះខាតការប្រមើលទុកជាមុនទៅលើការអភិវឌ្ឍនៅប្រទេសក្រីក្រ បណ្ដាលឱ្យប្រជាជនចំនួនជាងពាក់កណ្ដាលរស់នៅក្នុងទុគ៌តភាព ។

នៅដើមសតវត្សទី 21 ភាពអត់ឃ្លាននៅតែបន្ដនក់យកជីវិតមនុស្សហើយមនុស្សចំនួន 800 លាននាក់រងនូវកង្វះអាហារហូបចុក ។ តំបន់ដែលទទួលផលប៉ះពាល់ខ្លាំងបំផុតពីបញ្ហាស្បៀង គឺប្រទេសមួយចំនួននៅអាហ្វ្រិកក្បែរសាហារ៉ា ។ ជំនួយស្បៀងអាហារនៃពិភពលោកសំដៅជាបឋមឆ្ពោះទៅទីនោះ តាមពិតទោះបីមានការរីកចម្រើនក្ដី ក៏មានប្រជាជនចំនួន 30% នៅឡើយ ដែលទទួលបានការហូបចុកខ្វះខាតយ៉ាងរ៉ាំរ៉ៃ ។ ការបរិភោគមិនគ្រប់គ្រាន់ ប៉ះពាល់មុនគេដល់កុមារ 42% នៃកុមារអាយុក្រោម 5 ឆ្នាំទទួលបានការផ្គត់ផ្គង់អាហារមិនត្រឹមត្រូវ ។ អសុវត្ថិភាពស្បៀងនៅអាហ្វ្រិកកាន់តែធ្ងន់ធ្ងរ ។

នៅពេលដែលគោលដៅនៃសហស្សវត្សត្រូវបានប្រកាសយ៉ាងឱឡារិកជាថ្មី ដោយអង្គការសហប្រជាជាតិនៅឆ្នាំ 2000 ដែលគ្រោងកាត់បន្ថយចំនួនអ្នកបរិភោគមិនគ្រប់គ្រាន់ឱ្យបានពាក់កណ្ដាលពីពេលនេះដល់ឆ្នាំ 2015 នោះ គឺផ្ទុយស្រឡះ ភាពអត់ឃ្លានមិនបានធូរស្រាលឡើយ ។ ភាពអត់ឃ្លានកើនឡើងដូចគ្នានៅទ្វីបអាហ្វ្រិក ។ ហេតុអ្វីបានជាមានស្ថានភាពដ៏អាក្រក់បែបនេះ នៅពេលដែលចំណីអាហារក្នុងពិភពលោកអាចមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ចិញ្ចឹមមនុស្ស 6 500 លាននាក់ ដែលមានសព្វថ្ងៃនៅលើភពផែនដី និងមានដល់ 9 000 លាននាក់ នៅពេលខាងមុខ ។

បញ្ហាស្បៀងនៅតែជាបច្ចុប្បន្នភាពជានិច្ច បង្កើតឱ្យមានមតិចម្លែកបីគួរឱ្យឆ្ងល់គឺ

- នៅពេលដែលភាពធាត់ដុះពោះក្លាយជាបញ្ហាសុខភាពសាធារណៈមួយ នៅក្នុងប្រទេសអ្នកមានក៏ដូចជានៅប្រទេសក្រីក្រខ្លះដែរ មនុស្សជាង 800 លាននាក់នៅតែរស់នៅក្នុងភាពអត់ឃ្លាន ។ ទាំងនេះបង្ហាញថា កង្វះអាហារបណ្ដាលមកពីបញ្ហារបាយស្បៀង ច្រើនជាងបញ្ហាផលិតកម្ម ។
- កាលណាប្រទេសមួយមានចំនួនកសិករកាន់តែច្រើន ប្រទេសនោះស្ថិតក្នុងភាពអត់ឃ្លានកាន់តែខ្លាំង អាស្រ័យដោយហេតុថា ស្បៀងអាហារដែលផលិតបានក្នុងពិភពលោក ទាក់ទងទៅនឹងចំនួនប្រាក់កាសដែលប្រទេសនានាបានខ្ចីសម្រាប់ធ្វើវិនិយោគលើវិស័យកសិកម្មច្រើនជាងឥទ្ធិពលនៃធម្មជាតិ ។ កង្វះស្បៀងកើតមាន ជាពិសេសក្នុងប្រទេសក្រីក្រដែលមានកសិករច្រើន និងមិនបានយកចិត្តទុកដាក់លើនយោបាយសាធារណៈ ។

• ប៉ុន្តែភាពអត់ឃ្លានដែលខ្លាំងក្លាបំផុតគឺទុរ្ភិក្ស បញ្ហានេះមិនដែលកើតមានទេនៅក្នុងប្រទេសដែលមានភាពអត់ឃ្លានជាប្រពៃណីដូចជា តំបន់សាហែល ភាគឦសានប្រេស៊ីល ប្រទេសតំបន់ជួរភ្នំអង់ អាស៊ីខាងត្បូង តែទុរ្ភិក្សបែរជាកើតមាននៅក្នុងប្រទេសដែលគេមិនជឿសោះថានឹងមានភាពអត់ឃ្លាន ដោយសារកត្តាធម្មជាតិដូចជា ប្រទេសកុងគោ ស៊ិមបាវេ ស៊ូដង់ កូរ៉េខាងជើង បើការបរិភោគមិនគ្រប់គ្រាន់បណ្តាលមកពីភាពក្រីក្រ និងភាពទន់ខ្សោយនោះទុរ្ភិក្សមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងវិបត្តិនយោបាយ និងសង្គ្រាមដោយផ្ទាល់។



*គ្រោះរាំងស្ងួត និងភាពអត់ឃ្លាន (ប៉ាគីស្ថាន)*

ការបរិភោគមិនគ្រប់ ជាផលបានមកពីភាពទន់ខ្សោយ និងភាពក្រីក្រ។ ការបរិភោគមិនគ្រប់គឺជាភាពអត់ឃ្លានដ៏ស្ងប់ស្ងាត់មួយដែលឆក់យកជីវិតមនុស្សម្តងមួយៗ ព្រោះថាគេមិនអាចអនុវត្តការងារបានពេញលេញ ហើយនឹងអាចរងគ្រោះបាន។ ចំពោះលោក អាម៉ាស្យាសិន(អ្នកសេដ្ឋកិច្ចឥណ្ឌា) ជ័យលាភីរង្វាន់ណូបែលសេដ្ឋកិច្ចឆ្នាំ 1998 ពិសេសសម្រាប់ការងាររបស់គាត់លើផ្នែកទុរ្ភិក្សបានកំណត់ថា អ្នកបរិភោគមិនគ្រប់ គឺជាអ្នកទាំងឡាយណាដែលមិនអាចអនុវត្ត "សិទ្ធិទទួលបាន" ការផ្គត់ផ្គង់អាហារ ព្រោះថាពួកគេទទួលបានការផ្តល់រង្វាល់មិនជិតដល់ មិនមានសិទ្ធិចាត់ចែងមរតករួម និងមិនទទួលបានជំនួយទ្រទ្រង់ពីរដ្ឋអំណាចសាធារណៈ។ អ្នកបរិភោគមិនគ្រប់គឺដូច្នេះ ជាបឋម និងមុនអ្វីៗទាំងអស់ ពួកគេសុទ្ធតែជាអ្នកក្រីក្រ។

បីភាគបួននៃអ្នកបរិភោគមិនគ្រប់ជាអ្នកជនបទ ។ ក្នុងចំណោមកសិករចំនួន 1 300 លាននាក់ ដែលមាននៅក្នុងពិភពលោក (45%ជាប្រជាជនសកម្ម) មាន 515 លាននាក់ជាជនជាតិចិន 340 លាននាក់ជាឥណ្ឌា ។ អ្នកបរិភោគមិនគ្រប់មាន 500 លាននាក់រស់នៅទ្វីបអាស៊ី ជាពិសេសឥណ្ឌា បង់ក្លាដែស ប៉ាគីស្ថាន ... 200 លាននាក់នៅទ្វីបអាហ្វ្រិក ជាទ្វីបតែមួយគត់ដែលការបរិភោគមិនគ្រប់មិនមានការធូរស្រាលសោះ ហើយដែលមួយចំនួនធំត្រូវការស្បៀងអាហារជាបន្ទាន់ផង ។ ផ្ទុយទៅវិញនៅអាស៊ីភាគរយមានការថយចុះនៅឆ្នាំ 1970 ចំនួនអ្នកបរិភោគមិនគ្រប់តាងមួយភាគបី សព្វថ្ងៃមានតិចជាងមួយភាគប្រាំ(16%) ។ ការចុះថយនេះគេសង្កេតឃើញមាននៅក្នុងពិភពលោកផងដែរ អ្នកបរិភោគមិនគ្រប់មាន 1 000 លាននាក់នៅឆ្នាំ 1970 តាងបានមួយភាគបីនៃប្រជាជនប្រទេសកំពុងអភិវឌ្ឍ ។ ចំនួននេះមានត្រឹមតែ 800 លាននាក់នៅដើមសតវត្សទី 21 គឺតិចជាងមួយភាគប្រាំ ។

អ្នកបរិភោគមិនគ្រប់ទាំងនោះ ហាក់ដូចជាមិនដឹងទាល់តែសោះអំពីអារម្មណ៍នៃភាពអត់ឃ្លាន តែរបបអាហាររបស់ពួកគេមានលក្ខណៈដដែលៗ មិនទៀងទាត់ និងខ្វះខាតជីវជាតិជាពិសេស ។ ម្យ៉ាងទៀតពួកគេច្រើនតែជួបភាពរងគ្រោះដូចគ្នា ។ អសុវត្ថិភាពស្បៀងបង្ហាញថា ពួកគេនឹងត្រូវប្រឈមមុខចំពោះគ្រោះចង្រៃជាច្រើនមានដូចជា

- **គ្រោះបណ្ដាលមកពីធម្មជាតិ :** អ្នកជនបទដែលទទួលបានការហូបចុកខ្វះខាត ច្រើនតែជាគ្រួសារដែលមានដីមិនគ្រប់គ្រាន់ សម្រាប់ប្រកបរបរដាំដុះចិញ្ចឹមជីវិត ។ ពួកគេប្រើប្រាស់មធ្យោបាយផលិតកម្មបែបបុរាណទទួលបានទិន្នផលទាប(1 តោន ទៅ 1.5 តោនក្នុងមួយហិកតា) អនុវត្ត កសិកម្មចិញ្ចឹមពោះ ប្រវាស់មេឃ (សង្ឃឹមលើទឹកភ្លៀង គ្មានការបញ្ចូលទឹក) កាលណាភ្លៀងធ្លាក់យឺតក្រមកដល់ កត្តាចង្រៃ(កណ្ដូប កណ្ដូបដើរទេស ជំងឺផ្សិត បរាសិត ...) ក៏បំផ្លិចបំផ្លាញផលដំណាំ និងធ្វើឱ្យពួកគេធ្លាក់ទៅក្នុងភាពអត់ឃ្លាន ។ នៅអាមេរិកកណ្ដាល ព្យុះមួយឈ្មោះ មីត (Mitch) កាលពីខែ តុលា ឆ្នាំ 1998 បានធ្វើឱ្យគ្រួសារក្រីក្របំផុតរងគ្រោះមហន្តរាយ ។ ក្រោយពេលបាត់បង់នូវអ្វីៗទាំងអស់ គេក៏សម្រេចចិត្តភៀសខ្លួនមកកាន់ទីក្រុង ។ តាមពិត កាលណាគេប្រឈមមុខនឹងការលំបាកផ្ទួនៗពេកទៅ (ភាពរាំងស្ងួតជាបន្តបន្ទាប់ជាឧទាហរណ៍) អ្នកជនបទតែងធ្លាក់ទៅក្នុង "ស្ថានភាពមួយដែលខ្វះខុន" នាំឆ្ពោះទៅរកការជំពាក់បំណុលរើខ្លួនមិនរួច បន្ទាប់មកក៏ធ្វើចំណោលស្រុកស្រែ ។ អត្តឃាតកម្មនៃកសិករឥណ្ឌា និងការបះបោរនៃកសិករចិនកាន់តែកើតមានច្រើនឡើងៗ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1990 ដោយសារតែបំណុលរបស់ពួកគេ ។



*កសិករកំពុងស្ទូងស្រូវ (កម្ពុជា)*

- **ភយន្តរាយផ្នែកសេដ្ឋកិច្ច :** ដោយទទួលបានការរៀបចំផ្នែកនយោបាយតិចតួច កសិករក្រីក្រទាំងនោះមិនអាចការពារផលប្រយោជន៍ខ្លួនបានទេ។ ពួកគេមានទីផ្សារមិនគ្រប់គ្រាន់ ឬតិចតួចសម្រាប់លក់ផលិតផលរបស់ខ្លួន ... ។
- **ភយន្តរាយផ្នែកសុខភាព :** នៅអាមេរិកកណ្ដាល(ទីក្រុងម៉ិកស៊ីកូ តេគូស៊ីកាល់ប៉ា ម៉ាណាកា ...) និងអាមេរិកខាងត្បូង(ទីក្រុងឡាប៉ាស បូគោតា រីយ៉ូដឺសាណេរ៉ូ ប៊ុយអេណូស៊ែ ...)នៅអាហ្វ្រិក (ទីក្រុងគែ ឡាកូស ខាទូម ...) នៅអាស៊ី (ទីក្រុងមុមបៃ កាល់កត្តា ម៉ានីល ...) ជាមេត្រូប៉ូលធំៗ ដែលគេឃើញមានលំហូរចូលនៃអ្នកជនបទ ដែលរងគ្រោះដោយទុគ៌តភាព។ អ្នកទាំងនោះមកប្រមូលផ្ដុំគ្នារស់នៅក្នុងសង្កាត់លំនៅស្ថានកកើតឡើងភ្លាមៗ និងថ្មីៗហៅថាសំណង់អនាធិបតេយ្យដែលពួកគេរស់នៅដោយឆក់កណ្ដៀតក្នុងលក្ខខណ្ឌសុខភាពប្រកបដោយគ្រោះថ្នាក់។ ការលំបាកក្នុងការទទួលបានការប្រើប្រាស់ទឹកស្អាត គំនរសំរាម និងទឹកសំអុយកង្វះខាតបណ្ដាញលូបង្ហូរទឹកកខ្វក់ និងបង្គន់ ជាពិសេសនៅរដូវភ្លៀងបណ្ដាលឱ្យមាននូវជំងឺឆ្លងដូចជា រាករូស អាសន្នរោគ (បង់ក្លាដែស ឆ្នាំ 2004) ។ ដោយភាពក្រីក្រខ្លាំងពេក ឆ្នាំ 1990

កសិករនៅបណ្ដាខេត្តរបស់ប្រទេសចិន បានលក់ឈាមរបស់ខ្លួនដែលនាំមកនូវទុក្ខភ័យផ្នែកសុខភាពយ៉ាងធំធេង (អេដស៍ រលេង និងជំងឺរលាកថ្លើម) 10% នៃប្រជាជនចិន គឺប្រមាណជា 130 លាននាក់បានឆ្លងជំងឺថ្លើមប្រភេទ B ក្នុងប្រទេសមួយដែលស្ថិតនៅជួរទី 144 ក្នុងពិភពលោកសម្រាប់ប្រព័ន្ធសុខភាព ។ នៅអាហ្វ្រិកខាងត្បូងវិញ តាមការសង្កេតរបស់អង្គការចំណីអាហារ និងកសិកម្មពិភពលោក FAO បង្ហាញថា ជំងឺអេដស៍នាំឱ្យប៉ះពាល់អាជីវកម្មកសិកម្មដល់ទៅ 70% សម្លាប់មនុស្សអស់ 1/5 នៃប្រជាជនសកម្មផ្នែកកសិកម្មពីពេលនេះដល់ឆ្នាំ 2020 ។ នៅអាមេរិកឡាទីន ការលេចឡើងវិញនៃជំងឺសាកាស (Chagas) ដែលបណ្ដាលមកពីការធ្លាក់ចុះរចនាសម្ព័ន្ធសុខាភិបាលសាធារណៈ បន្ទាប់ពីវិបត្តិបំណុល បានក្លាយទៅជាបញ្ហាសុខភាពជាក់ស្ដែងមួយ ។ ដូចគ្នានេះដែរ នៅក្នុងពិភពលោកទាំងមូល ជំងឺគ្រុនចាញ់ ជំងឺបង្កឡើងដោយបរាសិត និងផ្លូវដង្ហើម និងពិសេសជំងឺអេដស៍ បង្កឱ្យមានការស្រុតចុះផ្នែកសេដ្ឋកិច្ច និងសង្គមក្នុងគ្រួសារដែលប៉ះពាល់នាំឱ្យមានការបរិភោគមិនគ្រប់ ចោទជាបញ្ហាដល់សុខភាព រំខានដល់ការងារចិញ្ចឹមជីវិត បណ្ដាលឱ្យបាត់បង់ផលទុន បង្ខំចិត្តធ្វើចំណាកស្រុកឆ្ពោះទៅរកសំណង់អនាធិបតេយ្យ... ។



*សំណង់អនាធិបតេយ្យនៅមុមបៃ (ឥណ្ឌា)*

## 1.2. របបអាហារ

អាហារដែលយើងបរិភោគប្រចាំថ្ងៃ ត្រូវបានប្លែងទៅជាថាមពលសម្រាប់ទ្រទ្រង់រាងកាយ និងបំពេញការងារ ។ អ្នកជំនាញផ្នែករបបអាហារបានប៉ាន់ប្រមាណថា មនុស្សយើងម្នាក់ត្រូវការថាមពល 2 300 កាឡូរីជាមធ្យមក្នុងមួយថ្ងៃសម្រាប់ទ្រទ្រង់រាងកាយ ។ ប៉ុន្តែអង្គការចំណីអាហារ និងកសិកម្មពិភពលោក FAO បានគណនាថា យ៉ាងតិចក៏ 2 700 កាឡូរីដែរសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ។ អ្នកក្រីក្រគ្មានប្រាក់កាសគ្រប់គ្រាន់សម្រាប់ទិញចំណីអាហារផ្គត់ផ្គង់ជីវិតបានឡើយ ។ ដូច្នេះអ្នកបរិភោគមិនគ្រប់គ្រាន់តាមពិតទៅ គឺអ្នកគ្មានប្រាក់សម្រាប់ទិញស្បៀងអាហារ ទោះបីផលិតផលអាហារមានលក់នៅឯទីផ្សារក៏ដោយ ដូចជានៅទ្វីបអាហ្វ្រិកជាឧទាហរណ៍ស្រាប់ ដែលគ្មានចំណីអាហារគ្រប់គ្រាន់ចិញ្ចឹម ប្រជាជន ។ ទោះបីជាទទួលបានការរីកចម្រើនចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ 1990 ក៏ដោយ ជាទូទៅនៅប្រទេសកំពុងអភិវឌ្ឍ កង្វះអាហារនៅតែជាបញ្ហាចំពោះមុខនៅឡើយ ដោយហេតុថា ថាមពលដែលទទួលបានមានកម្រិតទាបជាងការកំណត់របស់អង្គការ FAO គឺ 2 700 កាឡូរីសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ។

## 1.3. សុខាភិបាល



*មន្ទីរពេទ្យក្នុងប្រទេសកំពុងអភិវឌ្ឍ*

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ សេវាសុខាភិបាលទទួលបានការរីកលូតលាស់មិនស្មើគ្នាទេ ។ ហើយនៅក្នុងផ្ទៃនៃប្រទេសនីមួយៗទៀតសោត ក៏មានវិសមភាពចំពោះសុខភាពខ្លាំងក្លាណាស់ដែរ ដូចជារបាយមណ្ឌលសុខភាព របាយភ្នាក់ងារសុខាភិបាល គិលានុបដ្ឋាក គិលានុបដ្ឋាយិកា គ្រូពេទ្យ ឆ្មប ... ។

កំណើនប្រជាជនតែងមានទំនាក់ទំនងមួយផ្ទែកយ៉ាងសំខាន់ទៅនឹងសេវាសុខាភិបាល ដែលអាចកាត់បន្ថយអត្រាមរណប្រមាណ (ពិសេសអត្រាមរណៈកុមារ) អត្រាជាតិប្រមាណ និងអត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រី ។ អត្រាកំណើនប្រជាជន ជាផលសងរវាងអត្រាជាតិប្រមាណ និងអត្រាមរណប្រមាណ

- បើអត្រាជាតិប្រមាណទាប ហើយអត្រាមរណប្រមាណទាប ពេលនោះកំណើនប្រជាជនយឺត ។
- បើអត្រាជាតិប្រមាណខ្ពស់ ហើយអត្រាមរណប្រមាណខ្ពស់ កំណើនប្រជាជនក៏យឺតដែរ ។
- បើអត្រាជាតិប្រមាណខ្ពស់ហើយអត្រាមរណប្រមាណទាប ពេលនោះកំណើនប្រជាជនលឿន ។
- បើអត្រាជាតិប្រមាណទាប ហើយអត្រាមរណប្រមាណខ្ពស់ យើងបានកំណើនអវិជ្ជមាន ។
- បើអត្រាជាតិប្រមាណស្មើនិងអត្រាមរណប្រមាណ យើងបានកំណើនប្រជាជនថេរ ។

ជាមធ្យមនៅប្រទេសកំពុងអភិវឌ្ឍ លទ្ធភាពបង្កកំណើតរបស់ស្ត្រីមាន 4.24 នាក់ គឺស្ថិតនៅក្នុងកម្រិតមួយខ្ពស់នៅឡើយ ។ ដូចនេះគ្រួសារនីមួយៗអាចមានកូនច្រើនដែលចោទខ្លាំងដល់បញ្ហានៃការរស់នៅ (ហូបចុក ស្លៀកពាក់ ថ្នាំសង្កូវ រៀនសូត្រ ...) ។ ចំណែកអត្រាមរណៈកុមារវិញ គឺមាន 6.992% ហើយដែលនៅប្រទេសអភិវឌ្ឍមានមិនដល់ 0.5% ផង ។ អត្រាមរណៈកុមារមានកម្រិតខ្ពស់ជះឥទ្ធិពលទៅលើ "សង្ឃឹមរស់ពីកំណើត" របស់ប្រជាជននៃប្រទេសកំពុងអភិវឌ្ឍ (PED = Pays En Développement) គឺមានត្រឹមតែ 58.44 ឆ្នាំប៉ុណ្ណោះ ។ រីឯចំនួនគ្រូពេទ្យវិញក៏នៅខ្វះខាតច្រើន គឺមានប្រហែល 0.0485% មានន័យថា គ្រូពេទ្យ 485 នាក់ត្រូវព្យាបាលប្រជាជន 1 000 000 នាក់ ឬ 1 នាក់សម្រាប់ប្រជាជន 2 062 នាក់(នៅប្រទេសអភិវឌ្ឍគ្រូពេទ្យ 1 នាក់សម្រាប់ប្រជាជន 405 នាក់) ។

ទាំងនេះ វាជាសូចនាករមួយចំនួនដែលអាចឱ្យគេសម្គាល់បានថា សង្គមមួយ ឬប្រជាជាតិមួយទទួលបានការអភិវឌ្ឍហើយឬនៅ ហើយការអភិវឌ្ឍនោះបានដល់កម្រិតណាហើយ ។

### 1.4. វិស័យអប់រំ

ដូចគ្នានឹងវិស័យសុខាភិបាលដែរ វិស័យអប់រំនៅបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាគន្លឹះមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក៏ទទួលបានការរីកចម្រើនផ្សេងៗគ្នា ។ សូម្បីតែនៅក្នុងប្រទេសនីមួយៗ វិសមភាពចំពោះការអប់រំតែងកើតមានឡើងជាប្រាកដដូចជា វិសមភាពអប់រំតាមតំបន់ និងវិសមភាពភេទចំពោះការអប់រំ ។

• វិសមភាពតំបន់ចំពោះការអប់រំសង្កត់ធ្ងន់ទៅលើរបាយគ្រឹះស្ថានសិក្សា កម្រិតថ្នាក់សិក្សា និងបុគ្គលិកសិក្សា ។ ភាពខុសគ្នារវាងទីក្រុងនិងជនបទ ទីក្រុងទទួលបានការរីកលូតលាស់ខ្លាំងចំណែកជនបទ ពិសេសជនបទដាច់ស្រយាលខ្វះសព្វខ្វះគ្រប់ ទាំងអគារសិក្សា ទាំងកម្រិតថ្នាក់ និងគ្រូបង្រៀន ។



*សាលារៀននៅប្រទេសកំពុងអភិវឌ្ឍ(កម្ពុជា)*

• វិសមភាពភេទចំពោះការអប់រំ គឺស្ត្រីទទួលការសិក្សាអប់រំបានចំនួនតិចជាងបុរស ។ បញ្ហានេះភាគច្រើនបណ្តាលមកពីទំនៀមទម្លាប់ប្រពៃណីដែលនិយមថា កូនស្រីមិនត្រូវការរៀនសូត្រអ្វីច្រើននោះទេ និងសាសនាខ្លះដែលបិទសិទ្ធិមិនឱ្យកូនស្រីចូលសាលារៀន ម្ល៉ោះហើយពួកគេតែងរៀនសូត្របានតិចតួច ។ ទន្ទឹមនឹងនេះ គេឃើញប្រទេស PED មួយចំនួនធំនៅមានអត្រាអនក្ខរភាពខ្ពស់នៅឡើយដូចជា នៅអាហ្វ្រិកក្បែរសាហារ៉ា អាស៊ីខាងត្បូងជាដើម ។ អត្រាអនក្ខរភាពក្នុងក្រុមប្រទេសកំពុងអភិវឌ្ឍមានប្រហែល 43.23% (ឆ្នាំ 2000-2005) ។

អនក្ខរភាព និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច តែងមានទំនាក់ទំនងគ្នាទៅវិញទៅមក អនក្ខរភាពជាកត្តារាំងស្ទះដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ភាពយឺតយ៉ាវនៃការអភិវឌ្ឍនេះ ជាកត្តារាំងស្ទះវិញដែរដល់ការអភិវឌ្ឍវិស័យអប់រំ ។ ភាពក្រីក្រជាកត្តានាំឱ្យគេអាក់ខានមិនបានរៀនសូត្រ អនក្ខរជនអាចជាពលករខ្លាំងខាងកម្លាំងបាយ តែជាទូទៅខ្សោយខាងកម្លាំងប្រាជ្ញា ពួកគេត្រូវចាត់ទុកនៅក្នុងក្រុមពលករកម្លាំងរុញច្រានការអភិវឌ្ឍសង្គមសេដ្ឋកិច្ចដ៏ទន់ខ្សោយ ។

## 1.5. ការគោរពច្បាប់




*ការតវ៉ាក្នុងប្រទេសកំពុងអភិវឌ្ឍ*

នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ គេឃើញមានការតាក់តែងបង្កើតច្បាប់ជាច្រើន ដោយផ្អែកលើមូលដ្ឋានទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនា ផលប្រយោជន៍សង្គមជាតិ និងលើច្បាប់អន្តរជាតិផងដែរដោយការតម្រឹមតម្រង់ច្បាប់រដ្ឋ។ ច្បាប់ដែលបង្កើតឡើងនោះ ជួនកាលមិនគ្រប់គ្រាន់ទេ គួបផ្សំនឹងការអនុវត្តច្បាប់មានការឆកល្វែងផងនោះ ជាហេតុនាំឱ្យចំណោទបញ្ហាមួយចំនួនមិនអាចដោះស្រាយបានងាយនិងសមស្របផងទេ។ និយាយរួមប្រជាជាតិនីមួយៗតែងមានច្បាប់កំពូលរបស់ខ្លួនផ្ទាល់ហៅថា ច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់ពិសិដ្ឋមិនអាចអ្នកណារំលោភបានឡើយ។

នៅប្រទេសកំពុងអភិវឌ្ឍខ្លះ អ្នកនយោបាយអាចបកស្រាយច្បាប់បានសមហេតុសមផលរៀងៗខ្លួន ពិសេសច្បាប់រដ្ឋធម្មនុញ្ញក្នុងការដណ្តើមប្រជាប្រិយភាព ឆ្ពោះទៅឈោងកាន់កាប់អំណាចរដ្ឋ ដែលជាហេតុនាំឱ្យប្រជាជនដែលមានកម្រិតវប្បធម៌ទាបស្រាប់ មានការភាន់ច្រឡំក្នុងការសម្រេចចិត្តធ្វើជម្រើសត្រូវ។ មេដឹកនាំនយោបាយខ្លះ រំលោភច្បាប់រដ្ឋធម្មនុញ្ញ បង្ក្រាបនិងចាប់អ្នកប្រជាធិបតេយ្យដាក់គុកច្រវាក់ក្លាយទៅជាជនផ្តាច់ការដែលនៅប្រទេសប្រជាធិបតេយ្យសេរីជឿនលឿនខ្លះមិនមានករណីនេះឡើយ។

ការរំលោភច្បាប់អន្តរជាតិក៏អាចកើតមានរវាងប្រទេសកំពុងអភិវឌ្ឍដែរ ជាពិសេសប្រទេសដែលមានព្រំដែនជាប់គ្នានាំឆ្ពោះទៅរកជម្លោះដោយអាវុធ ។ ការរំលោភមួយទៀត គឺការលូកដៃរបស់ប្រទេសមួយចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសមួយទៀត អាចបង្កឱ្យមានជម្លោះផ្ទៃក្នុង សង្គ្រាមបង្ហូរឈាមរវាងគ្នាឯងផងដែរ ។ វិបត្តិទាំងនេះ ជួនកាលទាល់តែមានអន្តរាគមន៍ពីអង្គការសហប្រជាជាតិ ទើបអាចរំងាប់ ឬដោះស្រាយបានរួចរាល់ ទើបសុខសន្តិភាពអាចកើតមានឡើងវិញ ។

ក្រៅពីនេះនៅប្រទេសកំពុងអភិវឌ្ឍមួយចំនួន គេឃើញមានការរំលោភច្បាប់ និងសិទ្ធិមនុស្សពីសំណាក់ក្រុមសង្គមងងឹត ដែលបានប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃដូចជា អំពើឆក់ប្លន់ ការចាប់ជំរិត ការជួញដូរមនុស្ស ការជួញដូរផ្លូវភេទ ការជួញដូរគ្រឿងញៀន ការរំលោភសិទ្ធិកុមារជាដើម ។ ករណីទាំងនេះនាំឱ្យសង្គមបាត់បង់សុវត្ថិភាព សុខសន្តិភាព និងមោទនភាពបាន បើគ្មានវិធានការទប់ទល់ឱ្យបានប្រកបដោយប្រសិទ្ធភាពទេ ។ ម្យ៉ាងទៀតដោយមានកម្រិតវប្បធម៌ទាបជីវភាពយ៉ាប់យ៉ឺន ការសេពគ្រឿងស្រវឹង គ្រឿងញៀន និងការមិនយល់ដឹងអំពីសិទ្ធិមនុស្ស អំពើហិង្សាក្នុងគ្រួសារតែងកើតមានជាញឹកញយ បង្កការលំបាកជាច្រើនដល់សង្គម ។ ដូចនេះការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាត្រូវតែធ្វើឱ្យបានខ្លាំងក្លា ទើបអាចកាត់បន្ថយ ឬបោសសម្អាតអំពើឆ្គួតលីលាទាំងនោះបាន ។

ផ្ទុយទៅវិញ នៅប្រទេស PED ផ្សេងទៀតដែលអនុវត្តច្បាប់បានត្រឹមត្រូវ គោរពសិទ្ធិប្រជាធិបតេយ្យបានល្អ ស្ថាប័នប្រជាធិបតេយ្យទាំងបីមានភាពឯករាជ្យបរិបូរ ច្បាប់រដ្ឋធម្មនុញ្ញត្រូវបានលើកស្ទួយគ្មានការរំលោភ ប្រទេសទាំងនោះតែងទទួលបានការរីកចម្រើនប្រកបដោយសុខសន្តិភាព សុវត្ថិភាព គ្មានរដ្ឋប្រហារ គ្មានការបង្ហូរឈាម និងរស់នៅក្នុងមោទនភាពជាតិខ្ពស់ ។

## 2. តួនាទីនៃការអភិវឌ្ឍក្នុងប្រទេសកំពុងអភិវឌ្ឍ

សង្គមមនុស្ស ពិសេសនៅប្រទេសកំពុងអភិវឌ្ឍ ត្រូវការជាចាំបាច់នូវការអភិវឌ្ឍ ។ ដូចនេះការអភិវឌ្ឍមានតួនាទីសំខាន់ណាស់សម្រាប់សង្គមជាតិនីមួយៗ ទោះបីជាស្ថិតក្នុងកម្រិតណាមួយក៏ដោយ ។ បើគ្មានការអភិវឌ្ឍ សង្គមជាតិនោះនឹងមិនអាចរីកលូតលាស់ គឺស្ថិតនៅទ្រឹង ឬដើរថយក្រោយ ។ ប៉ុន្តែការអភិវឌ្ឍក៏មិនមែនជាការងារងាយស្រួលនោះទេ វាទាមទារនូវលក្ខខណ្ឌចាំបាច់ផ្សេងៗជាច្រើនដូចជា ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ការរៀបចំផែនការអភិវឌ្ឍជាដើម ។ សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ លក្ខខណ្ឌទាំងនេះជាបញ្ហាដ៏ធំធ្ងន់ធ្ងរដែលចាំបាច់ត្រូវតែជំនះ ទើបលទ្ធភាពអភិវឌ្ឍអាចកើតមានទៅបាន ។ ការអភិវឌ្ឍមានតួនាទីដោះស្រាយបញ្ហាទាំងអម្បាលមាណដែលមាននៅក្នុងសង្គមកំពុងអភិវឌ្ឍដូចដែលបានរៀបរាប់ខាងលើ ។

- ការអភិវឌ្ឍមានតួនាទីលើកកម្ពស់ជីវភាពប្រជាជន សំដៅធ្វើឱ្យប្រជាជនមានហូបចុកគ្រប់គ្រាន់ រស់នៅសមរម្យ ។ ចំពោះបញ្ហានេះរដ្ឋាភិបាលនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍតែងរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយ ។ រដ្ឋាភិបាលប្រទេសប្រេស៊ីលបានអនុវត្តផែនការ "គ្មានការស្រេកឃ្លាន" ដោយការចែកដីដល់ "អ្នកមានដីថ្មី" និងផ្ដល់ប្រាក់កម្ចីច្រើនជាងពេលណាៗទាំងអស់ សម្រាប់កសិកម្មគ្រួសារ សំដៅធ្វើឱ្យប្រជាជនប្រេស៊ីលមានអាហារហូបចុកបីពេលក្នុងមួយថ្ងៃ ។ នៅកម្ពុជា រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ខ្លាំងក្លាណាស់ដែរទៅលើបញ្ហានេះ ដោយអនុវត្តយុទ្ធសាស្ត្រចតុកោណ ដើម្បីកាត់បន្ថយភាពក្រីក្រនិងគម្លាតជីវភាពរវាងទីក្រុងនិងជនបទ ។



ការរៀបចំក្នុងប្រទេសកំពុងអភិវឌ្ឍ

- ការអភិវឌ្ឍមានតួនាទីលើកកម្ពស់សុខភាពប្រជាជន សំដៅធ្វើឱ្យសេវាសុខាភិបាលកាន់តែមានលក្ខណៈល្អប្រសើរឡើង ដោយបង្កើនចំនួនគ្រូពេទ្យព្យាបាល មន្ទីរពេទ្យ គិលានដ្ឋាន ... ឱ្យបានគ្រប់គ្រាន់ ។ នៅចន្លោះឆ្នាំ( 2000-2005 )ប្រទេសកម្ពុជាមានចំនួនគ្រូពេទ្យត្រឹមតែ 0.016% មានន័យថា កម្ពុជាមានគ្រូពេទ្យព្យាបាលចំនួន 16 នាក់សម្រាប់ប្រជាជន 100 000 នាក់ ឬគ្រូពេទ្យមួយនាក់សម្រាប់ប្រជាជន 6250 នាក់ ប៉ុណ្ណោះ ។ នៅអាមេរិកឡាទីនមានគ្រូពេទ្យ 0.085% ឬ

85 នាក់សម្រាប់ប្រជាជន 100 000 នាក់ ឬ 1 នាក់សម្រាប់ 1 176 នាក់ ។ នៅទ្វីបអាហ្វ្រិក មានគ្រូពេទ្យចំនួន 0.0044% ឬ 44 នាក់សម្រាប់ព្យាបាលមនុស្ស 1 000 000 នាក់ ឬមួយនាក់សម្រាប់ 22 727 នាក់ ។ តួលេខទាំងនេះបង្ហាញឱ្យឃើញថា បណ្តាប្រទេសកំពុងអភិវឌ្ឍនៅខ្វះខាតច្រើនណាស់ក្នុងវិស័យសុខាភិបាល ។ ដូចនេះ ការអភិវឌ្ឍត្រូវយកចិត្តទុកដាក់ឱ្យបានច្រើនលើផ្នែកសេវាសុខាភិបាល ។



*ការគោរពសិទ្ធិនៅក្នុងប្រទេសកំពុងអភិវឌ្ឍ*

- ការអភិវឌ្ឍមានតួនាទីលើកកម្ពស់ការសិក្សាអប់រំ សំដៅបណ្តុះបណ្តាលក្របខ័ណ្ឌជំនាញ (កម្មករជំនាញ អ្នកឯកទេស អ្នកបច្ចេកទេស វិស្វករ ...) ឱ្យបានគ្រប់គ្រាន់និងគ្រប់ផ្នែកជំនាញ កាត់បន្ថយអត្រាអនក្ខរភាព ដែលសព្វថ្ងៃមានកំណែលម្អច្រើនដែរ តែនៅតែស្ថិតក្នុងកម្រិតមួយខ្ពស់នៅឡើយ ។ នៅចន្លោះឆ្នាំ (2000-2005) ប្រទេសកំពុងអភិវឌ្ឍមានអត្រាអនក្ខរភាព 43.23% កាត់បន្ថយវិសមភាពចំពោះការអប់រំ មានវិសមភាពភេទ និងវិសមភាពតំបន់ចំពោះការអប់រំ(បុរសរៀនសូត្របានច្រើនជាងស្ត្រី ទីក្រុងទីប្រជុំជនមានអត្រាអក្ខរភាពខ្ពស់ជាងទីជនបទ ...) ។
- ការអភិវឌ្ឍនៅមានតួនាទីផ្សេងៗទៀតដូចជា បង្កើនការយល់ដឹងអំពីច្បាប់ សិទ្ធិប្រជាធិបតេយ្យ ការប្រើប្រាស់ច្បាប់ ការអនុវត្តសិទ្ធិសេរីភាពក្នុងក្របខ័ណ្ឌច្បាប់ សំដៅកាត់បន្ថយការរំលោភបំពាន អំពើហិង្សា ភាពអនាធិបតេយ្យ ... ក្នុងសង្គមជាតិនិងក្នុងក្រុមគ្រួសារ ។

និយាយរួម ការអភិវឌ្ឍមានតួនាទីសំខាន់ណាស់ ទោះក្នុងសង្គមអភិវឌ្ឍក្តី ឬកំពុងអភិវឌ្ឍក្តី ព្រោះវាជាគន្លឹះសម្រាប់ទ្រទ្រង់ស្ថិរភាពសង្គម និងសម្រាប់រុញច្រានសង្គមឱ្យចេញផុតពីភាពទន់ខ្សោយអន់ថយ ឆ្ពោះទៅកាន់ភាពរីកចម្រើនថ្កុំថ្កើងរុងរឿងបាន ។

## ? សំណួរ

1. ចូរនិយាយអំពីបញ្ហាស្បៀងនៅបណ្តាប្រទេសអាហ្វ្រិកក្បែរសាហារ៉ា ។
2. តាមទ្រឹស្តីផលិតកម្មស្បៀងអាហារក្នុងពិភពលោកអាចគ្រប់គ្រាន់សម្រាប់ចិញ្ចឹមមនុស្សលោក ហេតុអ្វីបានជាបញ្ហាស្បៀងនៅតែជាកង្វល់ដ៏ចម្បងនិងរ៉ាំរ៉ៃសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួនធំ ?
3. តាមទ្រឹស្តី តើមនុស្សម្នាក់ក្នុងមួយថ្ងៃត្រូវការរបបអាហារប៉ុន្មានកាឡូរីសម្រាប់ទ្រទ្រង់រាងកាយ ? តើអ្វីទៅដែលហៅថា កាឡូរី ?
4. តើសេវាសុខាភិបាលនៅបណ្តាប្រទេសកំពុងអភិវឌ្ឍស្ថិតក្នុងស្ថានភាពដូចម្តេច ?
5. ប្រទេសកម្ពុជាយើងមានគ្រូពេទ្យព្យាបាលចំនួន 0.016% ។ ចូរបកស្រាយតួលេខនេះ ។
6. តើអនក្ខរភាពនាំមកនូវផលវិបាកអ្វីខ្លះចំពោះសង្គមជាតិ ?
7. ចូរនិយាយអំពីការប្រព្រឹត្តល្មើសច្បាប់នៅក្នុងសង្គមកំពុងអភិវឌ្ឍមួយចំនួន ។
8. តើតួនាទីសំខាន់នៃការអភិវឌ្ឍនៅក្នុងសង្គមកំពុងអភិវឌ្ឍមានដូចម្តេចខ្លះ ?

មេរៀនទី

# 2 ប្រទេសអភិវឌ្ឍ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីស្ថានភាពប្រជាជន : ជីវភាព របបអាហារ សុខាភិបាល អប់រំ ការគោរពច្បាប់ និងតួនាទីនៃការអភិវឌ្ឍក្នុងប្រទេសអភិវឌ្ឍ ។

ប្រទេសអភិវឌ្ឍ គឺជាក្រុមប្រទេសដែលមានឿនសង្គមសេដ្ឋកិច្ចលូតលាស់ខ្លាំង ។ ប្រទេសទាំងនេះខ្លះមានជាយូរយារមកហើយ ខ្លះទៀតទើបតែមានថ្មីៗ (ប្រទេសនាគ ឬកូននាគ) ។ គេសង្កេតឃើញថា ប្រជាជននៃប្រទេសអភិវឌ្ឍតែងរស់នៅក្នុងលក្ខខណ្ឌល្អប្រសើរ ជាសង្គមទំនើប ប្រកបដោយសុខភាពមាំមួន ការអប់រំខ្ពស់ ការគោរពច្បាប់ទម្លាប់ត្រឹមត្រូវ ... ។ តើសង្គមអភិវឌ្ឍទាំងនោះ លែងមានចំណោទបញ្ហាទៀតហើយឬ ? ការអភិវឌ្ឍសង្គម លែងជាភាពចាំបាច់ទៀតហើយមែនទេ ?

## 1. ស្ថានភាពប្រជាជន

### 1.1. កម្ពស់ជីវភាព

នៅបណ្តាប្រទេសអភិវឌ្ឍ ប្រជាជនរមែងមានកម្រិតជីវភាពខ្ពស់ ដែលអាចដឹងបានតាមរយៈសន្ទស្សន៍នានា ដូចជាផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ៗក្នុងមួយឆ្នាំ(RNB = Revenue Nationale Brupte) ឬលទ្ធភាពទិញដូរខ្ពស់របស់ប្រជាជនជាដើម ។



*គ្រួសារមួយក្នុងប្រទេសអភិវឌ្ឍ*

ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ៗ នៅឆ្នាំ 2002 របស់ប្រទេសចំនួន 20 ដែលមានកម្រិតខ្ពស់ជាងគេ ។

| ល.រ | ប្រទេស | R.N.B ជាដុល្លារ | ល.រ | ប្រទេស | R.N.B ជាដុល្លារ |
|---|---|---|---|---|---|
| 1 | លុចសំបួ | 39 470 | 11 | ហ្វាំងឡង់ | 23 890 |
| 2 | ន័រវែស | 38 730 | 12 | អូទ្រីស | 23 860 |
| 3 | ស៊ុីស | 36 170 | 13 | ពេអ៊ីបា(ហូឡង់) | 23 390 |
| 4 | សហរដ្ឋអាមេរិក | 35 400 | 14 | អៀរឡង់ | 23 030 |
| 5 | ជប៉ុន | 34 010 | 15 | បែលហ្ស៊ិច | 22 940 |
| 6 | ដាណឺម៉ាក | 30 260 | 16 | អាល្លឺម៉ង់ | 22 740 |
| 7 | អ៊ីស្លង់ | 27 960 | 17 | កាណាដា | 22 390 |
| 8 | ស៊ុយអែត | 25 970 | 18 | បារាំង | 22 240 |
| 9 | រាជាណាចក្ររួម | 25 510 | 19 | សិង្ហបុរី | 20 690 |
| 10 | ហុងកុង-ចិន | 24 690 | 20 | អូស្ត្រាលី | 19 530 |

នៅបណ្តាប្រទេសអភិវឌ្ឍ ប្រជាជនមានកម្រិតជីវភាពខ្ពស់ ភាពអត់ឃ្លាន ឬការបរិភោគមិនគ្រប់ មិនចោទជាបញ្ហាដូចនៅបណ្តាប្រទេសកំពុងអភិវឌ្ឍឡើយ ។ ប៉ុន្តែជាវិបាក គេសង្កេតឃើញភាពធាត់ដុះពោះច្រើនកើតមាននៅប្រទេសទាំងនោះដែលក្លាយទៅជាបញ្ហាសុខភាពសាធារណៈមួយ ។



សង្កាត់ក្រីក្រស្បែកខ្មៅនៅញូយ៉ក

បើនិយាយពីការប្រើប្រាស់គ្រឿងឧបភោគបរិភោគវិញ ប្រជាជនចំនួន 20% ដែលរស់នៅក្នុងតំបន់ដែលមានផលទន់ខ្ពស់(អឺរ៉ុបខាងលិច ជប៉ុន អាមេរិកខាងជើង និងអូស្ត្រាលី) ប្រើប្រាស់អស់ 4/5 នៃគ្រឿងហូបចុកនិងគ្រឿងសម្ភារៈសរុប ។

ទោះបីជាមានកម្រិតជីវភាពខ្ពស់ក៏ដោយ ក៏នៅបណ្តាប្រទេសអ្នកមាន(ប្រទេសអភិវឌ្ឍ) ភាពក្រីក្រតែងតែកើតមាន និងញាំញីប្រជាជនមួយចំនួនផងដែរ ។ ប៉ុន្តែអ្នកក្រទាំងនោះមានផលទុនច្រើនជាងអ្នកក្រនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ។ នៅសហរដ្ឋអាមេរិកមានប្រជាជនជិត 15% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ អ្នកគ្មានជម្រក សង្កាត់អ្នកក្រីក្រស្បែកខ្មៅនៅសហរដ្ឋអាមេរិក (Ghetto) ... ។ នៅប្រទេសជប៉ុននិងប្រទេសអភិវឌ្ឍដទៃទៀត ក៏គេឃើញមានប្រជាជនក្រីក្រដូចគ្នានេះដែរ ។

ភាពក្រីក្រមានភាពកំណត់មិនដាច់ខាត ។ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ UNDP បានកំណត់ខ្សែបន្ទាត់នៃភាពក្រីក្រត្រឹម 2 ដុល្លារក្នុងមួយថ្ងៃ សម្រាប់ទ្វីបអាមេរិកឡាទីន និង 14 ដុល្លារសម្រាប់ប្រទេសឧស្សាហកម្ម ។ អ្នកក្រនៅក្នុងប្រទេសអ្នកមាន ដែលទទួលបានការផ្គត់ផ្គង់មិនគ្រប់គ្រាន់ តែងមានដំបូលជ្រកមួយ ទូទឹកកកមួយ និងទូរទស្សន៍មួយ ទោះបីក្នុងសភាព ឬគុណភាពណាក៏ដោយ ។ ទម្លាប់នៃការប្រើប្រាស់ តម្រូវការដែលកើតមាន



អ្នកគ្មានជម្រកនៅញូយ៉ក

មានភាពខុសៗគ្នា គេស្ថិតក្នុងភាពក្រីក្រក្នុងពេលមួយ និងនៅទីកន្លែងមួយ ។

## 1.2. របបអាហារ

របបអាហារ ត្រូវបានគិតជាកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ ។ របបអាហារប្រចាំថ្ងៃនៅប្រទេសអភិវឌ្ឍមាន 3 330 កាឡូរី (1990) 3 459 កាឡូរី (2000) ។ តាមតួលេខនេះគេអាចនិយាយបានថា របបអាហារនៅបណ្តាប្រទេសអភិវឌ្ឍ ឧស្សាហកម្មមានលក្ខណៈល្អប្រសើរទាំងបរិមាណ និងគុណភាព ផលិតកម្មអាហារស្រស់ក្តី ក្រៀមក្តី វេចខ្ចប់ក្តី ដាក់កំប៉ុងក្តី តែងមានការត្រួតពិនិត្យត្រឹមត្រូវនិងមានការកំណត់រយៈពេល



ជម្រកអ្នកក្រីក្របំផុតនៅស្ថានីយរថភ្លើងស៊ីនជូគូ (ជប៉ុន)

ឱ្យប្រើប្រាស់ ។ ទំនិញហួសកំណត់ពេលប្រើប្រាស់ ជាពិសេសគ្រឿងហូបចុក មិនមានលក់ ឬក្លែងបន្លំលក់នៅលើទីផ្សារទៀតឡើយ ព្រោះវាជារឿងខុសច្បាប់និងនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ។ អ្នកប្រើប្រាស់មានសិទ្ធិប្តឹងក្រុមហ៊ុនណាផលិតមុខទំនិញដែលនាំឱ្យខូចសុខភាព ដែលលក់របស់របរក្លែងក្លាយ ហៅថា "អំណាចអ្នកប្រើប្រាស់" ។ ម្យ៉ាងទៀតទោះបីមានបញ្ហាខ្វះខាតផលិតផលអាហារដូចករណីប្រទេសជប៉ុន ក៏រដ្ឋាភិបាលនៃប្រទេសទាំងនោះ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការនាំស្បៀងអាហារចូលមកពីប្រទេសក្រៅ ដើម្បីបំពេញតម្រូវការជូនប្រជាជនខ្លួនបាន ។ ទន្ទឹមនិងនេះកាលពីឆ្នាំ

2000 គេក៏ឃើញមានករណីអ្នកបរិភោគមិនគ្រប់ចំនួន 10 លាននាក់នៅក្នុងប្រទេសអភិវឌ្ឍ ដែលអនុវត្តរបបសេដ្ឋកិច្ចទីផ្សារ និងចំនួន 34 លាននាក់នៅបណ្តាប្រទេសដែលស្ថិតនៅក្នុងអន្តរភាពសេដ្ឋកិច្ចផងដែរ ។ ប្រទេសអាមេនីមានអ្នកបរិភោគខ្វះខាតជាង 50% តាហ្ស៊ីគីស្ថានមានជាង 70% ។




*ថាមពលគិតជាកាឡូរីសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ*

## 1.3. វិស័យសុខាភិបាល

នៅប្រទេសអភិវឌ្ឍ វិស័យសុខាភិបាលមានការរីកចម្រើនលូតលាស់គួរឱ្យស្ងប់ស្ងែង មន្ទីរពេទ្យ ឧបករណ៍ពេទ្យ គ្រូពេទ្យ បុគ្គលិកពេទ្យ រួមទាំងរបៀបរបបគ្រប់គ្រងសុទ្ធតែប្រកបទៅដោយលក្ខណៈបច្ចេកទេសវិទ្យាសាស្ត្រ និងប្រសិទ្ធភាពខ្ពស់ ។ ការព្យាបាលប្រព្រឹត្តទៅតាមមុខជំនាញពិតប្រាកដរៀងៗខ្លួន ដូចជាគ្រូពេទ្យជំនាញខាងបេះដូង សួត ថ្លើម ប្រមាត់ ត្រចៀក ច្រមុះ មាត់ ធ្មេញ ភ្នែក សរសៃឈាម សរសៃវិញ្ញាណជាដើម ។ សេវាសុខាភិបាលល្អប្រសើរ តែងជះឥទ្ធិពលធំធេងទៅលើអត្រាមរណប្រមាណ ពិសេសកាត់បន្ថយមរណភាពមាតា និងទារក ដែលជាកត្តាបង្កើនសង្ឃឹមរស់ពីកំណើតក្នុងប្រទេសអភិវឌ្ឍ ។ កុមារីជប៉ុនម្នាក់មានសង្ឃឹមរស់ប្រហែល 85 ឆ្នាំ ហើយដែលកុមារីសៀរ៉ាលេអូនម្នាក់មានតែ 36 ឆ្នាំប៉ុណ្ណោះ នៅឆ្នាំ 2002 ។ នៅអាមេរិកខាងជើង សង្ឃឹមរស់មាន 80 ឆ្នាំសម្រាប់ស្ត្រី និង 75 ឆ្នាំសម្រាប់បុរស ។ នៅទ្វីបអឺរ៉ុបមាន 78 ឆ្នាំសម្រាប់ស្ត្រីនិង 70 ឆ្នាំសម្រាប់បុរស នៅឆ្នាំ 2002 ។ នៅប្រទេសអភិវឌ្ឍ គ្រូពេទ្យមានកម្រិតជំនាញខ្ពស់និងមានចំនួនច្រើនគ្រប់គ្រាន់ គ្រូពេទ្យម្នាក់ទទួលបន្ទុកព្យាបាលប្រជាជនតែប្រមាណ 400 នាក់ប៉ុណ្ណោះ ។ នៅប្រទេសកំពុងអភិវឌ្ឍវិញ គ្រូពេទ្យម្នាក់សម្រាប់ប្រជាជនប្រមាណ 2000 នាក់ឯណោះ ។

## 1.4. វិស័យអប់រំ




*ការសិក្សានៅប្រទេសអភិវឌ្ឍ*

នៅប្រទេសអភិវឌ្ឍ ប្រព័ន្ធអប់រំមានប្លែកៗគ្នា តែការសិក្សាអប់រំមានប្រសិទ្ធភាពខ្ពស់ សាលារៀន គឺជាអាណាចក្រនៃការប្រកួតប្រជែង សញ្ញាបត្រមានតម្លៃជាសកល ។ នៅប្រទេសជប៉ុនការចូលរៀននៅសកលវិទ្យាល័យប្រព្រឹត្តទៅតាមការប្រកួតប្រជែងយ៉ាងស្វិតស្វាញ ហើយមានតែសិស្សឆ្នើមទេ ទើបអាចចូលរៀននៅសកលវិទ្យាល័យបាន ។ ដោយយល់អំពីតម្លៃនៃសញ្ញាបត្រ មាតាបិតាសុខចិត្តចំណាយប្រាក់កាសយ៉ាងច្រើន ដើម្បីឱ្យកូនខ្លួនអាចចូលរៀននៅសកលវិទ្យាល័យល្បីៗ ដូចជាសកលវិទ្យាល័យតូដាយនៅតូក្យូជាដើម ។ នៅសហរដ្ឋអាមេរិក វិស័យអប់រំពុំមានប្រព័ន្ធឯកភាពគ្នាទេ ពោលគឺ សកលវិទ្យាល័យនៅតាមរដ្ឋនីមួយៗ មានកម្មវិធីសិក្សាដាច់ដោយឡែកពីគ្នា វិស័យអប់រំជាសិទ្ធិរបស់រដ្ឋនីមួយៗ ។ មន្ទីរពិសោធន៍នៃសកលវិទ្យាល័យជាកន្លែងសិក្សាស្រាវជ្រាវរកវិធីបង្កើតថ្មី មានរូបមន្តផលិត ការពិនិត្យទៅលើគុណភាពផលិតផល ... ។ ប្រទេសអភិវឌ្ឍដទៃទៀត ក៏មានសកលវិទ្យាល័យល្បីៗជាច្រើនដែរ ដូចជាសកលវិទ្យាល័យប៉ារីស សកលវិទ្យាល័យអុកស្វូត ... ។ យុវជនបានចូលរៀននៅសកលវិទ្យាល័យមាន 52.1% នៅជប៉ុន 74% នៅអូស្ត្រាលី 82.6% នៅសហរដ្ឋអាមេរិក 65.2% នៅរាជាណាចក្ររួម 55.3% ... ។ រីឯបញ្ហាអនក្ខរភាពមិនមានចោទឡើងឡើយនៅប្រទេសអភិវឌ្ឍ ។ សាលារៀនបានបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយជំនាញ និងសីលធម៌ខ្ពស់ ដែលជាកម្លាំងដ៏រឹងមាំក្នុងការរុញច្រានសង្គមសេដ្ឋកិច្ចឱ្យរីកចម្រើនឡើង ។

## 1.5. ការគោរពច្បាប់



*ការតវ៉ារបស់ប្រជាជននៅប្រទេសអភិវឌ្ឍ*

នៅប្រទេសប្រជាធិបតេយ្យសេរីជឿនលឿន គេឃើញមានការបង្កើតច្បាប់ដ៏សម្បូរបែប ។ លទ្ធិប្រជាធិបតេយ្យមានភាពចាស់ទុំ ប្រជាជនទទួលបានការសិក្សាអប់រំល្អ នាំឱ្យការយល់ដឹងច្បាប់ទម្លាប់ និងការអនុវត្តច្បាប់ទទួលបានលទ្ធផលគួរឱ្យកោតសរសើរ ពោលគឺសង្គមជាតិ មានសណ្ដាប់ធ្នាប់ សុវត្ថិភាព និងសុខសន្តិភាព ។

ការបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងសភាជាតិ តែងអនុលោមទៅតាមច្បាប់បោះឆ្នោត ។ ការឃោសនារកសំឡេងឆ្នោតប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌច្បាប់ ដោយសន្តិវិធី គ្មានការបកអាក្រាត ហែកហួរ ស៊ីសាច់ហុតឈាមគ្នានោះទេ ។ គេច្រើនលើកឡើងបង្ហាញពីកម្មវិធីនយោបាយដល់សាធារណជនតែរៀងៗខ្លួន ។ ទោះបីមានការលើកឡើងដោយចំៗពីកំហុសឆ្គង ការឆកល្បែងរបស់អ្នកនយោបាយណាមួយក៏ដោយ ក៏ការលើកឡើងនោះសមស្របទៅតាមលក្ខណៈប្រជាធិបតេយ្យ ហើយក៏មានការឆ្លើយតបវិញយ៉ាងថ្លៃថ្នូរដែរ ។ ជារឿយៗគេក៏ឃើញផងដែរ អ្នកកាន់អំណាចខ្លះ បានលាលែងពីតំណែងដោយសារការសរសេររិះគន់របស់អំណាចទី 4 គឺអំណាចសារព័ត៌មានដូចជា ករណីលោកប្រធានាធិបតីសហរដ្ឋអាមេរិក (លោកនិចសុន លោករីហ្គេន) ។ នៅ

ប្រទេសបារាំង នៅប្រទេសជប៉ុន ...ក៏មានករណីលាឈប់ពីតំណែងដូចគ្នានេះដែរ ។ ប្រទេសអភិវឌ្ឍខ្លះបានចូលធ្វើអន្តរាគមន៍ក្នុងរឿងវិវាទអន្តរជាតិ ក្រោយពីបានទទួលការយល់ព្រមពីសភាជាតិរបស់ខ្លួន ។

ទន្ទឹមនឹងភាពសម្បូរច្បាប់ និងអ្វីៗសុទ្ធតែប្រព្រឹត្តទៅតាមផ្លូវច្បាប់ នៅក្នុងសង្គមអភិវឌ្ឍគេឃើញមានការប្រព្រឹត្តិល្មើសច្បាប់ផងដែរ ដូចជាអំពើរចាប់ជំរិត ការប្លន់ធនាគារ ការជួញដូរគ្រឿងញៀន ការជួញដូរផ្លូវភេទ ។ ដើម្បីទប់ទល់នឹងក្រុមសង្គមងងឹតទាំងនោះ ,រដ្ឋាភិបាលប្រទេសនីមួយៗបានបង្កើតក្រុមប៉ូលិសជំនាញដូចជាអេហ្វប៊ីអាយ ( FBI = Federal Bureau of Investigation ) របស់សហរដ្ឋអាមេរិក ឬក្រុមប៉ូលិសអន្តរជាតិជាដើម ។

## 2. តួនាទីនៃការអភិវឌ្ឍក្នុងប្រទេសអភិវឌ្ឍ

សង្គមជាតិមួយដែលមានឈ្មោះថា ជាសង្គមអភិវឌ្ឍហើយ តើសង្គមនោះលែងត្រូវការអភិវឌ្ឍទៀតហើយ ឬដូចម្តេច ?

មិនថាសង្គមជាតិណាជាសង្គមជាតិណាទេ ទោះបីកំពុងអភិវឌ្ឍក្តី ទើបអភិវឌ្ឍក្តី អភិវឌ្ឍយូរមកហើយក្តី ត្រូវការជានិច្ចនូវការអភិវឌ្ឍ ពោលគឺការអភិវឌ្ឍនៅតែមានតួនាទីសំខាន់សម្រាប់គ្រប់សង្គមនិងគ្រប់សម័យកាល ។ ការអភិវឌ្ឍមានតួនាទីបន្តដោះស្រាយបញ្ហាដែលនៅសេសសល់ក្នុងសង្គមជាតិផង បន្តរុញច្រានការវិវត្តសង្គមលើគ្រប់វិស័យ និងបន្តស្រាវជ្រាវផ្នែកសង្គមសេដ្ឋកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ សំដៅស្វែងរកផាសុខភាព និងសុភមង្គលជូនសង្គមជាតិនិងមនុស្សជាតិ ពោលគឺ មិនមែនសង្គ្រាម អំពើភេរវកម្ម ឬអាវុធប្រល័យលោកឡើយ ។

- ការអភិវឌ្ឍមានតួនាទី បន្តលើកកម្ពស់ជីវភាពប្រជាជន បំបាត់ភាពក្រីក្រដែលនៅសេសសល់ (អ្នកគ្មានជម្រក អ្នកហូបចុកខ្វះខាត អ្នកគ្មានការងារធ្វើ... ) ។
- ការអភិវឌ្ឍមានតួនាទី បន្តលើកកម្ពស់សុខភាពប្រជាជន តាមរយៈការសិក្សាស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ សំដៅបង្កើនប្រសិទ្ធភាពសេវាព្យាបាលជំងឺ ទាំងប្រភេទជំងឺដែលកើតមានតាំងពីយូរមកហើយ និងប្រភេទជំងឺដែលទើបតែកើតមានថ្មីៗ ព្រោះថាមានតែប្រទេសអភិវឌ្ឍន៍ទេ ទើបមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារនេះ ។
- ការអភិវឌ្ឍមានតួនាទី បន្តលើកកម្ពស់ការសិក្សាអប់រំ តាមការសិក្សាស្រាវជ្រាវបង្កើតកម្មវិធីសិក្សាថ្មី ឱ្យកាន់តែមានភាពសុក្រិតខ្លាំងឡើង ។ ព័ត៌មានវិទ្យា (កុំព្យូទ័រ អិនធឺណេត...) ជាជំនួយមួយដ៏រឹងមាំក្នុងការសិក្សាអប់រំបច្ចុប្បន្ន ព្រោះវាជាប្រភពផ្តល់និងប្តូរព័ត៌មាន ឬឯកសារ

សព្វបែបយ៉ាងជាប្រចាំ ។ សកលវិទ្យាល័យនៃបណ្ដាប្រទេសរីកចម្រើនមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស ។ មន្ទីរពិសោធន៍នៃសកលវិទ្យាល័យ ជាកន្លែងស្រាវជ្រាវរករូបមន្តវិទ្យាសាស្ត្រសម្រាប់ផលិតគ្រឿងសម្ភារៈផ្សេងៗដែលកាន់តែប្រណីតឡើងៗនិងជាកន្លែងពិនិត្យឡើងវិញនូវគុណភាពផលិតផលដើម្បីប្រកួតប្រជែងលើទីផ្សារពិភពលោក ។

*ឧទាហរណ៍ :* សកលវិទ្យាល័យដ៏ល្បីឈ្មោះបោះសំឡេងទាំង 20របស់សហរដ្ឋអាមេរិក បានបំពេញតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ ។

- ការអភិវឌ្ឍមានតួនាទី បន្តលើកកម្ពស់ប្រសិទ្ធភាពច្បាប់ ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិសំដៅធ្វើឱ្យសង្គមមានសណ្ដាប់ធ្នាប់ របៀបរៀបរយ មានសុខសុវត្ថិភាពកាន់តែប្រសើរឡើង សំដៅធ្វើឱ្យមានកិច្ចសហការជាអន្តរជាតិ ក្នុងការបង្កើនការគោរពសិទ្ធិប្រជាធិបតេយ្យ គ្មានការសម្លាប់រង្គាល គ្មានបទឧក្រិដ្ឋសង្គ្រាម គ្មានអំពើភេរវកម្ម ... ក្នុងពិភពលោក ។

ទាំងនេះបង្ហាញឱ្យឃើញថា បើគ្មានការអភិវឌ្ឍទេ សង្គមជាតិមិនអាចវិវត្តទៅមុខទាន់សម័យកាលឡើយ ព្រោះថាបច្ចុប្បន្ននេះជាសតវត្សទី 21 ឬដើមសហស្សវត្សទី 3 អ្វីៗមានការប្រែប្រួលផ្លាស់ប្ដូរមិនឈប់ឈរតាមបែបវិជ្ជមានផងនិងអវិជ្ជមានផង ។ ទាំងពីរបែបនេះហើយដែលមនុស្សលោកត្រូវតែយកចិត្តទុកដាក់ស្វែងយល់ ដើម្បីនិរន្តរភាពនៃការអភិវឌ្ឍ ។

## ? សំណួរ

1. ដូចម្ដេចហៅថា ប្រទេសអភិវឌ្ឍ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។
2. តើប្រជាជនប្រទេសអភិវឌ្ឍមានជីវភាពបែបណា ? គេអាចដឹងបានតាមរយៈអ្វី ?
3. នៅប្រទេសអ្នកមាន តើមានជនក្រីក្រដែរឬទេ ? តើគេកំណត់ខ្សែបន្ទាត់នៃភាពក្រីក្រយ៉ាងដូចម្ដេច ?
4. តើនៅប្រទេសអ្នកមាន មានការខ្វះខាតស្បៀងដែរឬទេ ? ចូរបញ្ជាក់ ដោយឧទាហរណ៍ ?
5. ហេតុអ្វីបានជាប្រជាជនជប៉ុនខ្វះខាតស្បៀងអាហារ ?
6. តើវិស័យសុខាភិបាលនិងវិស័យអប់រំនៃបណ្ដាប្រទេសអភិវឌ្ឍមានការរីកចម្រើនដូចម្ដេចខ្លះ ?
7. តើនៅប្រទេសប្រជាធិបតេយ្យសេរីជឿនលឿន មានជនសង្គមងងឹតដែរឬទេ ? តើគេបានចាត់វិធានការទប់ទល់យ៉ាងដូចម្ដេចខ្លះ ?
8. តើសង្គមអភិវឌ្ឍមួយលែងត្រូវការអភិវឌ្ឍហើយ ឬយ៉ាងណា ? ព្រោះអ្វី ? ចូរពន្យល់ ។

## ? សំណួរបញ្ចប់ជំពូកទី២

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់**

1. បញ្ហាខ្វះខាតស្បៀងប៉ះពាល់ខ្លាំងក្លាបំផុតដល់តំបន់ ៖

☐ក. អាស៊ីខាងត្បូង ☐ខ. អាស៊ីអាគ្នេយ៍

☐គ. អាហ្វ្រិកខាងត្បូង ☐ឃ. អាហ្វ្រិកក្បែរសាហារ៉ា ។

2. លោកប្រធានាធិបតីសហរដ្ឋអាមេរិកនិចសុននិងរីហ្គេនលាលែងពីតំណែងដោយសារ ៖

☐ក. អំណាចនីតិប្បញ្ញត្តិ ☐ខ. អំណាចនីតិប្រតិបត្តិ

☐គ. អំណាចតុលាការ ☐ឃ. អំណាចសារព័ត៌មាន ។

**II. ចូរផ្គូផ្គងផ្នែក A និង B រួចសរសេរចម្លើយត្រូវក្នុងផ្នែក C**

| A (អក្សរកាត់) | B (ន័យពេញលេញ) | C (ចម្លើយ) |
|---|---|---|
| 1. PED | ក. ប្រទេសអភិវឌ្ឍ ។ | 1. → ..... |
| 2. UNDP | ខ. ប្រទេសកំពុងអភិវឌ្ឍ ។ | 2. → ..... |
| 3. FAO | គ. អង្គការកសិកម្មនិងចំណីអាហារ ។ | 3 → ..... |
| | ឃ. កម្មវិធីអភិវឌ្ឍន៍របស់ អង្គការសហប្រជាជាតិ ។ | |

**III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. នៅបណ្តាប្រទេសសេរីជឿនលឿន លទ្ធិប្រជាធិបតេយ្យមានភាព ...................... ។
2. នៅប្រទេសកំពុងអភិវឌ្ឍ អត្រាគ្រូពេទ្យព្យាបាលមាន 0.0485% មានន័យថាគ្រូពេទ្យ 485 នាក់ត្រូវព្យាបាលប្រជាជនចំនួន ...................... នាក់ ។

**IV. ចូរឆ្លើយសំណួរខាងក្រោម**

1. តើអនក្ខរភាពនាំមកនូវផលវិបាកអ្វីខ្លះចំពោះសង្គមជាតិ ?
2. ហេតុអ្វីបានជាបញ្ហាស្បៀង នៅតែជាកង្វល់ដ៏ចម្បងនិងរ៉ាំរ៉ៃសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួន ?
3. តើសង្គមមួយដែលមានឈ្មោះថា "ជាសង្គមអភិវឌ្ឍ" លែងត្រូវការការអភិវឌ្ឍហើយ ឬយ៉ាងណា ? ចូរពន្យល់ ។